## ឆ្នាំ ក


| | |
|---|---|
| រដូវរង់ចាំ ឬ រដូវរអបអរសាទរ ព្រះគ្រីស្តយាងមក | ២ |
| រដូវបុណ្យព្រះយេស៊ូប្រសូត | ៨ |
| រដូវសែសិបថ្ងៃ ឬ រដូវរអប់រំពិសេស | ១៩ |
| សប្តាហ៍ពិសិដ្ឋ | ៣២ |
| រដូវបុណ្យចម្លង | ៥៥ |
| រដូវធម្មតា | ៧០ |

# ឆ្នាំ ក

# វដ្ដវង់ចាំ

# ឬ

# វដ្ដរង់ចាំការយាងមក ព្រះគ្រីស្ដយាងមក

# ថ្ងៃអាទិត្យទី ១ ក្នុងរដូវរង់ចាំ ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម ទន ៨៥,៨**

**អាលេលូយ៉ា! អាលេលូយ៉ា!** ឱព្រះអម្ចាស់អើយ! សូមសម្តែងព្រះហឫទ័យមេត្តាករុណាចំពោះយើងខ្ញុំ! សូមយាងមកសង្គ្រោះយើងខ្ញុំផង! **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **២៤,៣៧-៤៤**

ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ក្រុមសាវ័ក អំពីដំណើរនិវត្តន៍របស់ព្រះអង្គដូចតទៅ៖ [៣៧]«នៅគ្រា
បុត្រមនុស្សមកដល់ ក៏ដូចកាលនៅសម័យលោកណូអេដែរ [៣៨]គឺមុនពេលទឹកជំនន់ធំ មនុស្សម្នាតែងតែ
នាំគ្នា ស៊ីផឹករៀបការប្ដីប្រពន្ធ រហូតដល់ថ្ងៃដែលលោកណូអេចូលក្នុងសំពៅធំ ។ [៣៩]គេមិនបានចាប់
អារម្មណ៍អ្វីសោះ ទាល់តែទឹកជំនន់បំផ្លាញគេអស់ ។ នៅគ្រាដែលបុត្រមនុស្សមកដល់ ក៏កើតមានដូច្នោះ
ដែរ ។ [៤០]បើមានមនុស្សពីរនាក់ធ្វើការក្នុងចម្ការជាមួយគ្នា ព្រះជាម្ចាស់នឹងយកម្នាក់ទៅ ទុកម្នាក់ទៀត
ឲ្យនៅ ។ [៤១]បើមានស្ត្រីពីរនាក់កិនស្រូវជាមួយគ្នា ព្រះជាម្ចាស់នឹងយកម្នាក់ទៅ ទុកម្នាក់ទៀតឲ្យនៅ ។
[៤២]ដូច្នេះ ចូរប្រុងស្មារតីឲ្យមែនទែន ដ្បិតអ្នករាល់គ្នាពុំដឹងថា ព្រះអម្ចាស់របស់អ្នករាល់គ្នានឹងមកដល់
នៅពេលណាឡើយ ។ [៤៣]អ្នករាល់គ្នាដឹងហើយថា បើម្ចាស់ផ្ទះដឹងចោរចូលមកប្លន់ថ្មើរណា គាត់មុខជា
ប្រុងស្មារតីពុំខាន មិនបណ្ដោយឲ្យចោរចូលមកប្លន់ផ្ទះគាត់បានឡើយ ។ [៤៤]ដូច្នេះ អ្នករាល់គ្នាត្រូវត្រៀម
ខ្លួនជានិច្ច ដ្បិតបុត្រមនុស្សនឹងមកដល់ នៅវេលា ដែលអ្នករាល់គ្នាពុំបានគិត» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២ ក្នុងរដូវរង់ចាំ ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **លក ៣,៤.៦**

**អាលេលូយ៉ា! អាលេលូយ៉ា!** ចូររៀបចំផ្លូវរបស់ព្រះអម្ចាស់ ចូរតម្រង់ផ្លូវថ្វាយព្រះអង្គ
នោះមនុស្សទាំងអស់នឹងឃើញការសង្គ្រោះរបស់ព្រះជាម្ចាស់ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **៣,១-១២**

១នៅគ្រានោះ លោកយ៉ូហានបាទីស្ដមកដល់ ។ លោកប្រកាសនៅវាលរហោស្ថានក្នុងស្រុកយូដា
ថា៖ ២«ចូរប្រែចិត្តគំនិត ដ្បិតព្រះរាជ្យនៃស្ថានបរមសុខមកជិតបង្កើយហើយ!» ។ ៣ព្យាការីអេសាយ
បានថ្លែងទុក អំពីលោកយ៉ូហាននេះថា៖ «មានសំឡេងបុរសម្នាក់ស្រែកឡើងនៅវាលរហោស្ថានថា "ចូរ
រៀបចំផ្លូវរបស់ព្រះអម្ចាស់! ចូរតម្រង់ផ្លូវថ្វាយព្រះអង្គ!"» ។ ៤លោកយ៉ូហានមានសម្លៀកបំពាក់ធ្វើអំពី
រោមអូដ្ឋ ហើយពាក់ខ្សែក្រវាត់ធ្វើអំពីស្បែក ។ លោកបរិភោគកណ្ដូប និងទឹកឃ្មុំ ។ ៥អ្នកក្រុងយេរូសា
ឡឹម អ្នកស្រុកយូដា និងអ្នកស្រុកនៅតំបន់ទន្លេយ័រដាន់ទាំងមូល នាំគ្នាចេញទៅរកលោក ។ ៦គេទទួល
សារភាពអំពើបាបរបស់ខ្លួន ហើយលោកក៏ធ្វើពិធីជ្រមុជទឹកឲ្យគេក្នុងទន្លេយ័រដាន់ ។

៧កាលលោកឃើញពួកខាងគណៈផារីស៊ី និងពួកខាងគណៈសាឌូស៊ីជាច្រើន មកទទួលពិធីជ្រមុជទឹក
ពីលោក លោកមានប្រសាសន៍ទៅគេថា៖ «នែ៎ពូជពស់វែកអើយ! តើនរណាប្រាប់អ្នករាល់គ្នាឲ្យរត់
គេចពីព្រះពិរោធរបស់ព្រះជាម្ចាស់ ដែលជិតមកដល់ដូច្នេះ? ។ ៨ចូរប្រព្រឹត្តអំពើល្អដើម្បីបញ្ជាក់ថា
អ្នករាល់គ្នាបានកែប្រែចិត្តគំនិតមែន ។ ៩កុំនឹកស្មានថា ខ្លួនមានលោកអប្រាហាំជាបុព្វបុរសនោះឡើយ
ដ្បិតខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ព្រះជាម្ចាស់ក៏អាចធ្វើឲ្យថ្មទាំងនេះ ទៅជាកូនចៅលោកអប្រាហាំបាន
ដែរ ។ ១០ពូថៅនៅជិតគល់ឈើជាស្រេច ដើមណាមិនផ្ដល់ផ្លែល្អទេនឹងត្រូវកាប់រំលំ ហើយបោះទៅក្នុង
ភ្លើង ។ ១១ខ្ញុំធ្វើពិធីជ្រមុជអ្នករាល់គ្នាក្នុងទឹក ដើម្បីឲ្យអ្នករាល់គ្នាបានប្រែចិត្តគំនិត ប៉ុន្តែ លោកដែលមក
ក្រោយខ្ញុំ លោកមានកម្លាំងខ្លាំងជាងខ្ញុំ ។ ខ្ញុំមានឋានៈទាប សូម្បីតែដោះស្បែកជើងជូនលោក ក៏មិនសម
នឹងឋានៈដ៏ខ្ពង់ខ្ពស់របស់លោកផង ។ លោកនឹងធ្វើពិធីជ្រមុជឲ្យអ្នករាល់គ្នាក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ និង
ដោយភ្លើងវិញ ។ ១២លោកកាន់ចង្អេរ លោកសម្អាតលានបោកស្រូវ អុំស្រូវយកគ្រាប់ល្អរបស់លោក
ប្រមូលដាក់ជង្រុក រីឯសំដីវិញ លោកនឹងដុតក្នុងភ្លើងដែលឆេះពុំចេះរលត់ឡើយ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃទី ៨ ខែធ្នូ៖ បុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារីមិនជំពាក់បាប

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម លក ១,២៨**

**អាលេលូយ៉ា! អាលេលូយ៉ា!** បពិត្រព្រះនាងព្រហ្មចារិនីម៉ារី! សូមនាងមានអំណរសប្បាយ!
ព្រះអម្ចាស់គង់ជាមួយនាង! ព្រះអង្គប្រទានពរមកនាងលើសស្ត្រីទាំងឡាយ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត លូកា** **១,២៦-២៨**

២៦ព្រះជាម្ចាស់បានចាត់ទេវទូតកាព្រីអែល ឲ្យទៅភូមិណាសារ៉ែត ក្នុងស្រុកកាលីឡេ ២៧ដើម្បីជួបនឹង
ស្ត្រីក្រមុំព្រហ្មចារីម្នាក់ ជាគូដណ្ដឹងរបស់កំឡោះម្នាក់ ឈ្មោះយ៉ូសែប ដែលត្រូវជាញាតិវង្សព្រះបាទ
ដាវីឌ ។ ស្ត្រីក្រមុំនោះឈ្មោះនាងម៉ារី ។ ២៨ទេវទូតចូលទៅក្នុងផ្ទះនាងម៉ារី ហើយពោលទៅកាន់នាង
ថា៖ «នាងជាទីគាប់ព្រះហឫទ័យព្រះអម្ចាស់អើយ! ចូរមានអំណរសប្បាយឡើង! ព្រះអង្គគង់ជាមួយ
នាង» ។ ២៩ពេលឮពាក្យនេះ នាងម៉ារីរន្ធត់យ៉ាងខ្លាំង ហើយនឹករិះគិតថា តើពាក្យជម្រាបសួរនេះមាន
ន័យដូចម្ដេច ។ ៣០ទេវទូតពោលទៅកាន់នាងថា៖ «កុំខ្លាចអី ម៉ារីអើយ! ដ្បិតព្រះជាម្ចាស់គាប់ព្រះហឫ
ទ័យនឹងនាងហើយ ។ ៣១នាងនឹងមានគភ៌ ហើយសម្រាលបានបុត្រមួយ ដែលនាងត្រូវថ្វាយព្រះនាមថា
“យេស៊ូ” ។ ៣២បុត្រនោះនឹងមានឋានៈដ៏ប្រសើរឧត្ដម ហើយគេនឹងថ្វាយព្រះនាមថា “ព្រះបុត្រានៃព្រះ
ដ៏ខ្ពង់ខ្ពស់បំផុត” ។ ព្រះជាម្ចាស់នឹងតាំងបុត្រនោះឲ្យគ្រងរាជ្យលើបល្ល័ង្ករបស់ព្រះបាទដាវីឌ ជាព្រះ
អយ្យកោរបស់ព្រះអង្គ ៣៣ទ្រង់នឹងគ្រងរាជ្យលើប្រជារាស្ត្រអ៊ីស្រាអែលអស់កល្បជានិច្ច ហើយរាជ្យរបស់
ព្រះអង្គនឹងនៅស្ថិតស្ថេរ ឥតមានទីបញ្ចប់ឡើយ» ។ ៣៤នាងម៉ារីសួរទៅទេវទូតថា៖ «តើធ្វើដូចម្ដេចនឹង
ឲ្យការនេះកើតឡើងបាន បើនាងខ្ញុំមិនរួមរស់ជាមួយបុរសណាផងដូច្នេះ?» ។ ៣៥ទេវទូតឆ្លើយទៅនាង
វិញថា៖ «ព្រះវិញ្ញាណដ៏វិសុទ្ធនឹងយាងមកសណ្ឋិតលើនាង គឺឫទ្ធានុភាពរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុតនឹង
គ្របបាំងនាង ។ ហេតុនេះ គេនឹងថ្វាយព្រះនាមដល់បុត្រដ៏វិសុទ្ធ ដែលត្រូវប្រសូតមកនោះថា “ព្រះ
បុត្រារបស់ព្រះជាម្ចាស់” ។ ៣៦ម្យ៉ាងទៀត នាងអេលីសាបិតជាញាតិរបស់នាង មានផ្ទៃពោះប្រាំមួយខែ
ហើយ ថ្វីដ្បិតតែគាត់មានវ័យចាស់ថែមទាំងជាស្ត្រីអារទៀតផងក៏ដោយ ៣៧ព្រោះគ្មានការអ្វីដែលព្រះជា
ម្ចាស់ធ្វើមិនកើតនោះឡើយ» ។ ៣៨នាងម៉ារីពោលទៅទេវទូតថា៖ «នាងខ្ញុំជាអ្នកបម្រើរបស់ព្រះអម្ចាស់
សូមឲ្យបានសម្រេចតាមពាក្យរបស់លោកចុះ!» ។ បន្ទាប់មក ទេវទូតចាកចេញពីនាងទៅ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៣ ក្នុងរដូវរង់ចាំ ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម លក ២,៧៦**

**អាលេលូយ៉ា! អាលេលូយ៉ា!** លោកយ៉ូហានជាព្យាការីរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុត លោកដើរ
ខាងមុខ ដើម្បីរៀបចំផ្លូវថ្វាយព្រះអម្ចាស់ និងធ្វើជាសាក្សីថ្វាយព្រះពន្លឺ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **១១,២-១១**

២ពេលនោះ លោកយ៉ូហានជាប់ក្នុងមន្ទីរឃុំឃាំង ហើយឮគេនិយាយអំពីកិច្ចការទាំងប៉ុន្មាន ដែល
ព្រះគ្រីស្តធ្វើ ។ លោកចាត់សិស្សឲ្យទៅទូលសួរព្រះយេស៊ូថា៖ ៣«តើលោកជាព្រះគ្រីស្តដែលត្រូវយាង
មក ឬមួយយើងខ្ញុំត្រូវរង់ចាំម្នាក់ផ្សេងទៀត?» ។ ៤ព្រះយេស៊ូមានព្រះបន្ទូលទៅសិស្សទាំងនោះថា៖
«ចូរទៅជម្រាបលោកយ៉ូហាន នូវហេតុការណ៍ដែលអ្នករាល់គ្នាបានឮ និងបានឃើញនេះទៅ ៥គឺមនុស្ស
ខ្វាក់មើលឃើញ មនុស្សខ្វិនដើរបាន មនុស្សឃ្លង់ជាស្អាតបរិសុទ្ធ មនុស្សថ្លង់ស្ដាប់ឮ មនុស្សស្លាប់បានរស់
ឡើងវិញ ហើយមានគេនាំដំណឹងល្អទៅប្រាប់ជនក្រីក្រ ។ ៦អ្នកណាមិនរវាតចិត្តចេញពីជំនឿដោយ
សារខ្ញុំ អ្នកនោះពិតជាមានសុភមង្គលហើយ!» ។

៧ពេលពួកសិស្សរបស់លោកយ៉ូហានចេញផុតទៅ ព្រះយេស៊ូមានព្រះបន្ទូលទៅមហាជន អំពីលោក
យ៉ូហានថា៖ «តើអ្នករាល់គ្នាទៅវាលរហោស្ថានរកមើលអ្វី? រកមើលដើមត្រែងដែលត្រូវខ្យល់បក់
នោះឬ? ។ ៨តើអ្នករាល់គ្នាទៅរកមើលអ្វី? រកមើលមនុស្សស្លៀកពាក់ល្អរុងរឿងឬ? តាមធម្មតា អស់
អ្នកដែលស្លៀកពាក់ល្អរុងរឿង គេរស់នៅក្នុងដំណាក់ស្ដេចឯណោះ! ។ ៩បើដូច្នេះ តើអ្នករាល់គ្នាទៅរក
មើលអ្វី? រកមើលព្យាការីម្នាក់ឬ? ។ ត្រូវហើយ! ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងថា លោកនោះប្រសើរ
ជាងព្យាការីទៅទៀត ១០ដ្បិតក្នុងគម្ពីរមានចែងអំពីលោកយ៉ូហានថា “យើងចាត់ទូតយើងឲ្យទៅមុន
ព្រះអង្គ ដើម្បីរៀបចំផ្លូវរបស់ព្រះអង្គ” ។ ១១ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា បណ្ដាមនុស្សដែល
កើតមកក្នុងលោកនេះ គ្មាននរណាមានឋានៈធំជាងលោកយ៉ូហានបាទីស្ដឡើយ ។ ប៉ុន្តែ អ្នកណាតូចជាង
គេ នៅក្នុងព្រះរាជ្យនៃស្ថានបរមសុខ អ្នកនោះប្រសើរលើសលោកយ៉ូហានទៅទៀត ។»

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៤ ក្នុងរដូវរង់ចាំ ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** មថ ១,២៣

**អាលេលូយ៉ា! អាលេលូយ៉ា!** ស្ត្រីព្រហ្មចារីនឹងមានផ្ទៃពោះ នាងនឹងសម្រាលបានបុត្រមួយ ដែលគេនឹងថ្វាយព្រះនាមថា "អេម៉ានូអែល" គឺព្រះជាម្ចាស់គង់ជាមួយយើង ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** ១,១៨-២៤

១៨ព្រះយេស៊ូគ្រីស្តប្រសូតដូចតទៅ ។ នាងម៉ារី មាតារបស់ព្រះអង្គ ត្រូវជាគូដណ្តឹងរបស់លោក យ៉ូសែប ។ មុនពេលអ្នកទាំងពីររួមរស់ជាមួយគ្នា នាងម៉ារីមានផ្ទៃពោះដោយសារព្រះវិញ្ញាណដ៏វិសុទ្ធរួច ទៅហើយ ។
១៩លោកយ៉ូសែប ជាស្វាមីរបស់នាង និងជាមនុស្សសុចរិត លោកមិនចង់បំបាក់មុខនាងទេ គឺលោកសម្រេចចិត្តថា នឹងផ្តាច់ពាក្យដោយស្ងាត់ៗវិញ ។
២០ពេលលោកកំពុងគិតដូច្នេះ ស្រាប់តែមាន ទេវទូតរបស់ព្រះអម្ចាស់មកប្រាប់លោកក្នុងសុបិននិមិត្តថា៖ «លោកយ៉ូសែប ជារាជវង្សរបស់ព្រះបាទ ដាវីឌអើយ! សូមកុំខ្លាចនឹងទទួលនាងម៉ារីមកធ្វើជាភរិយាឡើយ! ទោះបីបុត្រដែលនៅក្នុងផ្ទៃនាង កើតមកពីព្រះវិញ្ញាណដ៏វិសុទ្ធ
២១ហើយនាងនឹងសម្រាលបានបុត្រមួយអង្គក្តី ក៏លោកត្រូវថ្វាយព្រះនាម ថា "យេស៊ូ" ដ្បិតបុត្រនោះនឹងសង្គ្រោះប្រជារាស្ត្រព្រះអង្គឲ្យរួចពីបាប» ។

២២ ហេតុការណ៍នេះកើតឡើង ដើម្បីឲ្យសេចក្តីដែលព្រះអម្ចាស់មានព្រះបន្ទូលតាមរយៈព្យាការី បាន សម្រេចជារូបរាងថា៖
២៣«ស្ត្រីព្រហ្មចារីនឹងមានផ្ទៃពោះ នាងនឹងសម្រាលបានបុត្រមួយ ដែលគេនឹង ថ្វាយព្រះនាមថា "ព្រះអេម៉ានូអែល" (ឈ្មោះនេះប្រែថា "ព្រះជាម្ចាស់គង់ជាមួយយើង")» ។

២៤លុះលោកយ៉ូសែប ភ្ញាក់ឡើងលោក ក៏ធ្វើតាមបង្គាប់ទេវទូតរបស់ព្រះអម្ចាស់ គឺលោកទទួលនាង ម៉ារីមកធ្វើជាភរិយា ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# រដូវបុណ្យព្រះយេស៊ូប្រសូត

# បុណ្យព្រះអម្ចាស់យេស៊ូប្រសូត
# អភិបូជានៅពេលយប់

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម លក ២,១០-១១**

**អាលេលូយ៉ា! អាលេលូយ៉ា!** ខ្ញុំនាំដំណឹងល្អមួយមកប្រាប់អ្នករាល់គ្នា ។ ដំណឹងនេះនឹងធ្វើឲ្យប្រជារាស្ត្រទាំងមូលមានអំណរដ៏លើសលប់ គឺយប់នេះព្រះសង្គ្រោះរបស់អ្នករាល់គ្នាបានប្រសូតហើយ ទ្រង់ជាព្រះគ្រីស្ត ជាព្រះអម្ចាស់ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត លូកា** **២,១-១៤**

[១]នៅគ្រានោះ ព្រះចៅអធិរាជរ៉ូម៉ាំង ព្រះនាមអូគូស្ត មានព្រះរាជបញ្ជាឲ្យជំរឿនចំនួនប្រជាជនទាំង
អស់ ក្នុងចក្រភពរ៉ូម៉ាំងទាំងមូល ។ [២]ការជំរឿនប្រជាជនលើកដំបូងនេះ បានធ្វើឡើងក្នុងអំឡុងពេល
ដែលលោកគីរីញ៉ូស ធ្វើជាទេសាភិបាលនៅស្រុកស៊ីរី ។ [៣]អ្នកស្រុកទាំងអស់ត្រូវទៅចុះឈ្មោះក្នុងបញ្ជី
តាមស្រុកកំណើតរៀងៗខ្លួន ។ [៤]រីឯលោកយ៉ូសែបក៏ចេញដំណើរពីភូមិណាសារ៉ែត ក្នុងស្រុកកាលីឡេ
ឆ្ពោះទៅភូមិបេថ្លេហិម ក្នុងស្រុកយូដា ជាភូមិកំណើតរបស់ព្រះបាទដាវីឌ ព្រោះលោកជាព្រះញាតិវង្ស
នឹងព្រះបាទដាវីឌ ។ [៥]លោកទៅចុះឈ្មោះជាមួយនាងម៉ារីជាភរិយាដែលមានផ្ទៃពោះ ។ [៦]ពេលអ្នកទាំង
ពីរនៅឯភូមិបេថ្លេហិម នាងម៉ារីគ្រប់ខែហើយ ។ [៧]នាងសម្រាលបានបុត្រមួយ ជាបុត្រច្បង ។ នាងរុំ
បុត្រនោះនឹងសំពត់ រួចដាក់ឲ្យផ្ទំក្នុងស្នូកសត្វ ដ្បិតពុំមានសល់កន្លែងសំណាក់ក្នុងផ្ទះ ។

[៨]ក្នុងស្រុកនោះ ពេលយប់មានពួកគង្វាលនៅមើលហ្វូងសត្វរបស់គេតាមវាលស្មៅ ។ [៩]ពេលនោះ
ទេវទូតរបស់ព្រះអម្ចាស់ មកឈរនៅក្បែរពួកគេ សិរីរុងរឿងរបស់ព្រះអម្ចាស់បានភ្លឺចិញ្ចែងចិញ្ចាចនៅ
ជុំវិញគេ នាំឲ្យគេភ័យខ្លាចយ៉ាងខ្លាំង ។ [១០]ទេវទូតពោលទៅគេថា៖ «កុំខ្លាចអ្វីឡើយ! ខ្ញុំនាំដំណឹងល្អ
មួយមកប្រាប់អ្នករាល់គ្នា ។ ដំណឹងនេះនឹងធ្វើឲ្យប្រជារាស្ត្រទាំងមូលមានអំណរដ៏លើសលប់ ។ [១១]គឺយប់
នេះនៅក្នុងភូមិកំណើតរបស់ព្រះបាទដាវីឌ ព្រះសង្គ្រោះរបស់អ្នករាល់គ្នាប្រសូតហើយ ទ្រង់ជាព្រះគ្រីស្ត
ជាអម្ចាស់ ។ [១២]នេះជាសញ្ញាសម្គាល់ឲ្យអ្នករាល់គ្នាដឹង គឺអ្នករាល់គ្នានឹងឃើញទារកមួយទើបនឹងកើត
មក រុំដោយសំពត់ នៅក្នុងស្នូកសត្វ» ។

[១៣]រំពេចនោះ មានទេវទូតច្រើនកុះករចុះពីស្ថានបរមសុខមក រួមជាមួយទេវទូតនោះ ច្រៀងសរសើរ
ព្រះជាម្ចាស់ថា៖ [១៤]«សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពស់បំផុត ហើយសូមឲ្យ
មនុស្សលោកដ៏ជាទីស្រឡាញ់របស់ព្រះអង្គ បានប្រកបដោយសេចក្តីសុខសាន្តនៅលើផែនដី!» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# បុណ្យព្រះអម្ចាស់យេស៊ូប្រសូត
# អភិបូជានៅពេលព្រឹកព្រលឹម

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **លក ២,១៤**

**អាលេលូយ៉ា! អាលេលូយ៉ា!** សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពស់បំផុត ហើយសូមឲ្យមនុស្សលោកដ៏ជាទីស្រឡាញ់របស់ព្រះអង្គ បានប្រកបដោយសេចក្ដីសុខសាន្តនៅលើផែនដី ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត លូកា** **២,១៥-២០**

[១៥]ពេលពួកទេវទូតត្រឡប់ទៅស្ថានបរមសុខវិញអស់ទៅ ពួកគង្វាលបបួលគ្នាថា៖ «ទៅ! យើងនាំ
គ្នាទៅបេថ្លេហិម មើលហេតុការណ៍ដែលកើតមាន ដូចព្រះអម្ចាស់បានសម្ដែងឲ្យយើងដឹងនោះមើល៍» ។
[១៦]ពួកគេប្រញាប់ប្រញាល់នាំគ្នាធ្វើដំណើរទៅ ឃើញនាងម៉ារី លោកយ៉ូសែប ព្រមទាំងព្រះឱរសផ្ទំក្នុង
ស្នូកសត្វ ។ [១៧]ពេលពួកគង្វាលឃើញព្រះឱរសហើយ គេក៏រៀបរាប់អំពីសេចក្ដីដែលទេវទូតបានប្រាប់
អំពីព្រះឱរសនេះ ។ [១៨]អស់អ្នកដែលបានឮពួកគង្វាលនិយាយនឹកឆ្ងល់យ៉ាងខ្លាំង ។ [១៩]រីឯនាងម៉ារីវិញ
នាងចងចាំហេតុការណ៍ទាំងនេះទុកក្នុងចិត្ត ព្រមទាំងត្រិះរិះពិចារណាថែមទៀតផង ។ [២០]បន្ទាប់មក ពួក
គង្វាលត្រឡប់ទៅវិញ ទាំងច្រៀងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ព្រោះហេតុការណ៍ទាំងអស់
ដែលគេបានឃើញបានឮ ស្របតាមសេចក្ដីដែលទេវទូតបានប្រាប់គេ ឥតមានខ្វះត្រង់ណាឡើយ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# បុណ្យព្រះអម្ចាស់យេស៊ូប្រសូត
# អភិបូជានៅពេលថ្ងៃ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ**

**អាលេលូយ៉ា! អាលេលូយ៉ា!** នៅថ្ងៃនេះ ព្រះពន្លឺបានបំភ្លឺមនុស្សលោក ។
ប្រជាជនទាំងឡាយនៅលើផែនដីអើយ! សូមអញ្ជើញចូលមកក្នុងពន្លឺរបស់ព្រះជាម្ចាស់!
សូមអញ្ជើញមកក្រាបថ្វាយបង្គំព្រះអម្ចាស់! **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** **១,១-១៨ (ឬយ៉ាងខ្លី ១,១-៥.៩-១៤)**

១កាលពីដើមដំបូងបង្អស់ ព្រះបន្ទូលមានព្រះជន្មគង់នៅ ។ ព្រះបន្ទូលបែរទៅរកព្រះជាម្ចាស់ ហើយ
ព្រះបន្ទូលជាព្រះជាម្ចាស់ ។ ២ព្រះបន្ទូលបែរទៅរកព្រះជាម្ចាស់ កាលពីដើមដំបូងបង្អស់ ។ ៣អ្វីៗសព្វ
សារពើ សុទ្ធតែកើតឡើងដោយសារព្រះបន្ទូល គឺក្នុងបណ្ដាអ្វីៗដែលកើតមក គ្មានអ្វីមួយកើតមកក្រៅពី
ព្រះអង្គបង្កើតនោះឡើយ ។ ៤ព្រះបន្ទូលជាប្រភពនៃជីវិត ហើយជីវិតនោះជាពន្លឺបំភ្លឺមនុស្សលោក ។
៥ពន្លឺភ្លឺក្នុងសេចក្ដីងងឹត តែសេចក្ដីងងឹតពុំបានទទួលពន្លឺទេ ។

៦ព្រះជាម្ចាស់បានចាត់បុរសម្នាក់ ឈ្មោះយ៉ូហានឲ្យមក ។ ៧លោកមកធ្វើជាបន្ទាល់ផ្ដល់សក្ខីភាពអំពី
ពន្លឺ ដើម្បីឲ្យមនុស្សទាំងអស់ជឿដោយសារលោក ។ ៨លោកយ៉ូហានមិនមែនជាពន្លឺទេ គឺលោកគ្រាន់តែ
មកផ្ដល់សក្ខីភាពអំពីពន្លឺប៉ុណ្ណោះ ។

៩ព្រះបន្ទូលជាពន្លឺដ៏ពិតប្រាកដតែមួយ ដែលមកក្នុងពិភពលោក ហើយបំភ្លឺមនុស្សគ្រប់ៗរូប ។
១០ព្រះបន្ទូលបានគង់ក្នុងពិភពលោក ហើយពិភពលោកកើតឡើងដោយសារព្រះអង្គ ប៉ុន្តែ ពិភពលោក
ពុំបានទទួលស្គាល់ព្រះអង្គទេ ។ ១១ព្រះបន្ទូលបានយាងមក គង់ជាមួយប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់ តែ
ប្រជារាស្ត្រនោះពុំបានទទួលព្រះអង្គឡើយ ។ ១២រីឯអស់អ្នកដែលបានទទួលព្រះអង្គ គឺអស់អ្នកដែលជឿ
លើព្រះនាមព្រះអង្គ ព្រះអង្គប្រទានឲ្យគេអាចទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ។ ១៣អ្នកទាំងនោះពុំ
មែនកើតពីលោហិត ពីចំណង់តណ្ហា ឬពីការប៉ងប្រាថ្នារបស់មនុស្សទេ គឺកើតពីព្រះជាម្ចាស់វិញ ។ ១៤ព្រះ
បន្ទូលកើតមកជាមនុស្ស ហើយគង់នៅក្នុងចំណោមយើងរាល់គ្នា យើងបានឃើញសិរីរុងរឿងរបស់ព្រះ
អង្គ ជាសិរីរុងរឿងនៃព្រះបុត្រាតែមួយគត់ ដែលមកពីព្រះបិតាព្រះអង្គពោរពេញទៅដោយព្រះហឫទ័
យប្រណីសន្ដោស និងសេចក្ដីពិត ។

[15]លោកយ៉ូហានបានផ្ដល់សក្ខីភាពអំពីព្រះអង្គ ដោយប្រកាសថា៖ «គឺលោកនេះហើយ ដែលខ្ញុំនិយាយថា “អ្នកមកក្រោយខ្ញុំ ប្រសើរជាងខ្ញុំ ដ្បិតលោកមានជីវិតមុនខ្ញុំ”» ។ [16]យើងទាំងអស់គ្នាទទួលព្រះហឫទ័យប្រណីសន្ដោស មិនចេះអស់មិនចេះហើយ ពីគ្រប់លក្ខណសម្បត្តិរបស់ព្រះអង្គ [17]ដ្បិតព្រះជាម្ចាស់ប្រទានធម្មវិន័យដោយសារលោកម៉ូសេ តែទ្រង់បានសម្ដែងព្រះហឫទ័យប្រណីសន្ដោស និងសេចក្ដីពិត ដោយសារព្រះយេស៊ូគ្រីស្ដ ។ [18]ពុំដែលមាននរណាម្នាក់បានឃើញព្រះជាម្ចាស់ទេ មានតែព្រះបុត្រាមួយព្រះអង្គប៉ុណ្ណោះ ដែលបាននាំយើងឲ្យស្គាល់ព្រះអង្គ ដ្បិតព្រះបុត្រាមានព្រះជន្មរួមជាមួយព្រះបិតា ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# បុណ្យគ្រួសារដ៏វិសុទ្ធរបស់ព្រះយេស៊ូ ឆ្នាំ ក

ថ្ងៃអាទិត្យក្រោយបុណ្យព្រះអម្ចាស់យេស៊ូប្រសូត

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ**

**អាលេលូយ៉ា! អាលេលូយ៉ា!** បពិត្រព្រះអម្ចាស់! ព្រះអង្គពិតជាលាក់កំបាំងមែន! បពិត្រព្រះយេស៊ូជាព្រះសង្គ្រោះ! ព្រះអង្គពិតជាព្រះជាម្ចាស់ដែលគង់នៅជាមួយមនុស្សលោក! ។ **អ.!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **២,១៣-១៥.១៩-២៣**

[១៣]កាលពួកហោរាចារ្យចាកចេញផុតទៅ ទេវទូតរបស់ព្រះអម្ចាស់មកប្រាប់លោកយ៉ូសែប ក្នុងសុបិននិមិត្តថា៖ «ចូរក្រោកឡើង! នាំព្រះឱរសនិងមាតារបស់ព្រះអង្គ រត់ទៅស្រុកអេស៊ីបទៅ ។ ចូរស្នាក់នៅស្រុកនោះ រហូតដល់យើងប្រាប់ម្ដងទៀត ដ្បិតស្ដេចហេរ៉ូដរកធ្វើគុតព្រះឱរស» ។ [១៤]លោកយ៉ូសែបក្រោកឡើង នាំព្រះឱរសនិងមាតារបស់ព្រះអង្គ រត់ភៀសខ្លួនទៅស្រុកអេស៊ីបទាំងយប់ ។ [១៥]គាត់ស្នាក់នៅទីនោះ រហូតដល់ព្រះបាទហេរ៉ូដសោយទិវង្គត ដើម្បីឲ្យសេចក្ដីដែលព្រះអម្ចាស់មានព្រះបន្ទូលដោយសារព្យាការីបានសម្រេចជារូបរាងថា៖ «យើងបានហៅបុត្រយើងចេញពីស្រុកអេស៊ីបមក» ។

[១៩]កាលព្រះបាទហេរ៉ូដសោយទិវង្គតផុតទៅ ទេវទូតរបស់ព្រះអម្ចាស់មកប្រាប់លោកយ៉ូសែបនៅស្រុកអេស៊ីប ក្នុងសុបិនថា៖ [២០]«ចូរក្រោកឡើង នាំព្រះកុមារ និងមាតារបស់ព្រះអង្គវិលត្រឡប់ទៅស្រុកអ៊ីស្រាអែលវិញទៅ ដ្បិតពួកអ្នកដែលប៉ុនប៉ងធ្វើគុតព្រះកុមារស្លាប់បាត់អស់ទៅហើយ» ។

[២១]លោកយ៉ូសែបក្រោកឡើងនាំព្រះកុមារ និងមាតារបស់ព្រះអង្គ វិលត្រឡប់មកស្រុកអ៊ីស្រាអែលវិញ ។ [២២]ប៉ុន្តែ កាលលោកដឹងថា ព្រះបាទអកេឡោស ឡើងគ្រងរាជ្យនៅស្រុកយូដា ស្នងព្រះបាទហេរ៉ូដជាព្រះបិតា លោកខ្លាចមិនហ៊ានទៅស្រុកនោះទេ លោកភៀសខ្លួនទៅស្រុកកាលីឡេ ដោយព្រះជាម្ចាស់មានព្រះបន្ទូលឲ្យដឹង ។ [២៣]លោកតាំងទីលំនៅក្នុងភូមិមួយឈ្មោះណាសារ៉ែត ដើម្បីឲ្យស្របតាមសេចក្ដីដែលពួកព្យាការីបានថ្លែងទុក សម្រេចជារូបរាងថា៖ «គេនឹងហៅព្រះអង្គថា "ជាអ្នកភូមិណាសារ៉ែត"» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃទី ១ ខែមករា៖ បុណ្យគោរពព្រះនាងម៉ារី ជាមាតារបស់ព្រះជាម្ចាស់

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម ហប ១,១-២**

**អាលេលូយ៉ា! អាលេលូយ៉ា!** នៅជំនាន់ដើម ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់បុព្វបុរស
ដោយសារអស់លោកព្យាការី ។ តែឥឡូវនេះ ព្រះអង្គមានព្រះបន្ទូលមកយើង
ដោយសារព្រះបុត្រា! ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត លូកា** **២,១៦-២១**

[១៦]កាលពួកគង្វាលនាំគ្នាធ្វើដំណើរទៅដល់ភូមិបេថ្លេហិមហើយ គេឃើញនាងម៉ារី លោកយ៉ូសែប
ព្រមទាំងព្រះឱរសផ្ទំក្នុងស្នូកសត្វ ។ [១៧]ពេលពួកគង្វាលឃើញព្រះឱរសហើយ គេក៏រៀបរាប់អំពីសេចក្ដី
ដែលទេវទូតបានប្រាប់អំពីព្រះឱរសនេះ ។ [១៨]អស់អ្នកដែលបានឮពួកគង្វាលនិយាយនឹកឆ្ងល់យ៉ាងខ្លាំង ។
[១៩]រីឯនាងម៉ារីវិញ នាងចងចាំហេតុការណ៍ទាំងនេះទុកក្នុងចិត្ត ព្រមទាំងត្រិះរិះពិចារណាថែមទៀតផង ។
[២០]បន្ទាប់មក ពួកគង្វាលត្រឡប់ទៅវិញ ទាំងច្រៀងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ព្រោះ
ហេតុការណ៍ទាំងអស់ដែលគេបានឃើញ និងបានឮ ស្របតាមសេចក្ដីដែលទេវទូតបានប្រាប់គេ ឥតមាន
ខ្វះត្រង់ណាឡើយ ។

[២១]ប្រាំបីថ្ងៃក្រោយមក ដល់ពេលកំណត់ធ្វើពិធីកាត់ស្បែកថ្វាយព្រះឱរស គេថ្វាយព្រះនាមថា
"យេស៊ូ" ជាព្រះនាមដែលទេវទូតបានប្រាប់នាងម៉ារី មុនពេលមានផ្ទៃពោះ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២ ក្រោយបុណ្យព្រះយេស៊ូប្រសូត

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ**

**អាលេលូយ៉ា! អាលេលូយ៉ា!** នៅថ្ងៃនេះ ព្រះពន្លឺបានបំភ្លឺមនុស្សលោក ។
ប្រជាជនទាំងឡាយនៅលើផែនដីអើយ! សូមអញ្ជើញចូលមកក្នុងពន្លឺរបស់ព្រះជាម្ចាស់!
សូមអញ្ជើញមកក្រាបថ្វាយបង្គំព្រះអម្ចាស់! **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** **១,១-១៨ (ឬយ៉ាងខ្លី ១,១-៥.៩-១៤)**

[១]កាលពីដើមដំបូងបង្អស់ ព្រះបន្ទូលមានព្រះជន្មគង់នៅ ។ ព្រះបន្ទូលបែរទៅរកព្រះជាម្ចាស់ ហើយ
ព្រះបន្ទូលជាព្រះជាម្ចាស់ ។ [២]ព្រះបន្ទូលបែរទៅរកព្រះជាម្ចាស់ កាលពីដើមដំបូងបង្អស់ ។ [៣]អ្វីៗសព្វ
សារពើ សុទ្ធតែកើតឡើងដោយសារព្រះបន្ទូល គឺក្នុងបណ្ដាអ្វីៗដែលកើតមក គ្មានអ្វីមួយកើតមកក្រៅពី
ព្រះអង្គបង្កើតនោះឡើយ ។ [៤]ព្រះបន្ទូលជាប្រភពនៃជីវិត ហើយជីវិតនោះជាពន្លឺបំភ្លឺមនុស្សលោក ។
[៥]ពន្លឺភ្លឺក្នុងសេចក្ដីងងឹត តែសេចក្ដីងងឹតពុំបានទទួលពន្លឺទេ ។

[៦]ព្រះជាម្ចាស់បានចាត់បុរសម្នាក់ ឈ្មោះយ៉ូហានឲ្យមក ។ [៧]លោកមកធ្វើជាបន្ទាល់ផ្ដល់សក្ខីភាពអំពី
ពន្លឺ ដើម្បីឲ្យមនុស្សទាំងអស់ជឿដោយសារលោក ។ [៨]លោកយ៉ូហានមិនមែនជាពន្លឺទេ គឺលោកគ្រាន់តែ
មកផ្ដល់សក្ខីភាពអំពីពន្លឺប៉ុណ្ណោះ ។

[៩]ព្រះបន្ទូលជាពន្លឺដ៏ពិតប្រាកដតែមួយ ដែលមកក្នុងពិភពលោក ហើយបំភ្លឺមនុស្សគ្រប់ៗរូប ។
[១០]ព្រះបន្ទូលបានគង់ក្នុងពិភពលោក ហើយពិភពលោកកើតឡើងដោយសារព្រះអង្គ ប៉ុន្តែ ពិភពលោក
ពុំបានទទួលស្គាល់ព្រះអង្គទេ ។ [១១]ព្រះបន្ទូលបានយាងមក គង់ជាមួយប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់ តែ
ប្រជារាស្ត្រនោះពុំបានទទួលព្រះអង្គឡើយ ។ [១២]រីឯអស់អ្នកដែលបានទទួលព្រះអង្គ គឺអស់អ្នកដែលជឿ
លើព្រះនាមព្រះអង្គ ព្រះអង្គប្រទានឲ្យគេអាចទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ។ [១៣]អ្នកទាំងនោះពុំ
មែនកើតពីលោហិត ពីចំណង់តណ្ហា ឬពីការប៉ងប្រាថ្នារបស់មនុស្សទេ គឺកើតពីព្រះជាម្ចាស់វិញ ។ [១៤]ព្រះ
បន្ទូលកើតមកជាមនុស្ស ហើយគង់នៅក្នុងចំណោមយើងរាល់គ្នា យើងបានឃើញសិរីរុងរឿងរបស់ព្រះ
អង្គ ជាសិរីរុងរឿងនៃព្រះបុត្រាតែមួយគត់ ដែលមកពីព្រះបិតាព្រះអង្គពោរពេញទៅដោយព្រះហឫទ័
យប្រណីសន្ដោស និងសេចក្ដីពិត ។

[១៥]លោកយ៉ូហានបានផ្ដល់សក្ខីភាពអំពីព្រះអង្គ ដោយប្រកាសថា៖ «គឺលោកនេះហើយ ដែលខ្ញុំ

និយាយថា “អ្នកមកក្រោយខ្ញុំ ប្រសើរជាងខ្ញុំ ដ្បិតលោកមានជីវិតមុនខ្ញុំ” » ។ [១៦]យើងទាំងអស់គ្នាទទួល
ព្រះហឫទ័យប្រណីសន្ដោស មិនចេះអស់មិនចេះហើយ ពីគ្រប់លក្ខណសម្បត្តិរបស់ព្រះអង្គ [១៧]ដ្បិតព្រះជា
ម្ចាស់ប្រទានធម្មវិន័យដោយសារលោកម៉ូសេ តែទ្រង់បានសម្តែងព្រះហឫទ័យប្រណីសន្ដោស និងសេចក្ដី
ពិត ដោយសារព្រះយេស៊ូគ្រីស្ដ ។ [១៨]ពុំដែលមាននរណាម្នាក់បានឃើញព្រះជាម្ចាស់ទេ មានតែព្រះបុត្រា
មួយព្រះអង្គប៉ុណ្ណោះ ដែលបាននាំយើងឲ្យស្គាល់ព្រះអង្គ ដ្បិតព្រះបុត្រាមានព្រះជន្មរួមជាមួយ
ព្រះបិតា ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# បុណ្យព្រះយេស៊ូសម្ដែងព្រះអង្គ

ថ្ងៃអាទិត្យរវាងថ្ងៃទី ២ និងថ្ងៃទី ៨ ខែមករា

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **មថ ២,២**

**អាលេលូយ៉ា! អាលេលូយ៉ា!** យើងខ្ញុំបានឃើញផ្កាយរបស់ព្រះអង្គរះនៅទិសខាងកើត ហើយយើងខ្ញុំមកថ្វាយបង្គំព្រះអង្គ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **២,១-១២**

១ព្រះយេស៊ូប្រសូតនៅភូមិបេថ្លេហិម ក្នុងស្រុកយូដា នារជ្ជកាលព្រះបាទហេរ៉ូដ ។ មានពួក
ហោរាចារ្យនាំគ្នាធ្វើដំណើរពីទិសខាងកើត មកដល់ក្រុងយេរូសាឡឹម ២សួរថា៖ «ព្រះមហាក្សត្ររបស់
ជនជាតិយូដាដែលទើបនឹងប្រសូតគង់នៅឯណា? យើងខ្ញុំបានឃើញផ្កាយរបស់ព្រះអង្គរះនៅទិសខាង
កើត ហើយយើងខ្ញុំមកថ្វាយបង្គំព្រះអង្គ» ។ ៣កាលព្រះបាទហេរ៉ូដឮដំណឹងនេះ ទ្រង់រន្ធត់ព្រះហឫទ័យ
យ៉ាងខ្លាំង ហើយអ្នកក្រុងយេរូសាឡឹមទាំងអស់ ក៏រន្ធត់ចិត្តជាមួយព្រះអង្គដែរ ។ ៤ព្រះរាជាត្រាស់ហៅ
ពួកនាយកបូជាចារ្យ និងពួកធម្មាចារ្យទាំងប៉ុន្មានរបស់ប្រជាជនមក ដើម្បីសួរគេពីទីកន្លែងដែលព្រះគ្រី
ស្តត្រូវប្រសូត ។ ៥គេទូលស្ដេចថា ព្រះគ្រីស្តត្រូវប្រសូតនៅភូមិបេថ្លេហិម ក្នុងស្រុកយូដា ដ្បិតមាន
សេចក្ដីចែងទុកមកដោយសារព្យាការីថា៖ ៦«ភូមិបេថ្លេហិមជាដែនដីយូដាអើយ! ក្នុងបណ្ដាក្រុង
សំខាន់ៗនៃស្រុកយូដា អ្នកមិនមែនតូចជាងគេទេ ដ្បិតនឹងមានគង្វាលម្នាក់កើតចេញពីអ្នក លោកនឹង
ថែរក្សាជនជាតិអ៊ីស្រាអែលជាប្រជារាស្ត្ររបស់យើង» ។ ៧ពេលនោះ ព្រះបាទហេរ៉ូដហៅពួក
ហោរាចារ្យមកជាសម្ងាត់ សួរបញ្ជាក់អំពីពេលដែលផ្កាយរះឡើង ។ ៨បន្ទាប់មក ទ្រង់ចាត់ហោរាចារ្យ
ទាំងនោះឲ្យទៅភូមិបេថ្លេហិម ដោយមានរាជឱង្ការថា៖ «សុំអស់លោកនាំគ្នាទៅចុះ ហើយស៊ើបសួរ
ដំណឹងអំពីព្រះឱរសនោះឲ្យបានច្បាស់លាស់ ។ កាលបានឃើញហើយ ចូរមកប្រាប់យើងវិញផង ដើម្បី
ឲ្យយើងទៅថ្វាយបង្គំព្រះអង្គដែរ» ។ ៩ក្រោយពីបានទទួលរាជឱង្ការហើយ គេក៏នាំគ្នាចេញទៅ ។ ពេល
នោះ ផ្កាយដែលគេឃើញនៅទិសខាងកើត នាំមុខគេរហូតដល់កន្លែងដែលព្រះឱរសគង់ទើបឈប់ ។
១០កាលហោរាចារ្យទាំងនោះឃើញផ្កាយ គេសប្បាយចិត្តពន់ប្រមាណ ។ ១១គេចូលទៅក្នុងផ្ទះ ឃើញព្រះ
ឱរសគង់នៅជាមួយនាងម៉ារីជាមាតា គេក៏នាំគ្នាក្រាបថ្វាយបង្គំព្រះអង្គ រួចបើកហិបយកទ្រព្យរបស់ខ្លួន
គឺមាស គ្រឿងក្រអូប និងជ័រល្វីងទេសមកថ្វាយព្រះអង្គ ។ ១២បន្ទាប់មក គេវិលត្រឡប់ទៅស្រុករបស់ខ្លួន
វិញ តាមផ្លូវមួយផ្សេងទៀត ដ្បិតព្រះជាម្ចាស់មានព្រះបន្ទូលប្រាប់គេ ក្នុងសុបិននិមិត្ត មិនឲ្យវិលទៅ
គាល់ព្រះបាទហេរ៉ូដវិញឡើយ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# បុណ្យព្រះអម្ចាស់យេស៊ូទទួលពិធីជ្រមុជទឹក ឆ្នាំ ក

ថ្ងៃអាទិត្យ ឬ ថ្ងៃចន្ទក្រោយបុណ្យព្រះយេស៊ូសម្ដែងព្រះអង្គ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **មថ ៣,១៦-១៧ ; ទន ២៨,៣**

**អាលេលូយ៉ា! អាលេលូយ៉ា!** នៅថ្ងៃនេះ ផ្ទៃមេឃបក់ចំហ ព្រះវិញ្ញាណយាងចុះមក សណ្ឋិតលើព្រះយេស៊ូ ហើយព្រះសូរសៀងរបស់ព្រះបិតាលាន់ឮនៅលើទឹកថា៖ «លោកនេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង!» ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **៣,១៣-១៧**

[១៣]ព្រះយេស៊ូយាងពីស្រុកកាលីឡេ មករកលោកយ៉ូហាននៅត្រង់ទន្លេយ័រដាន់ ដើម្បីឲ្យលោកធ្វើពិធីជ្រមុជទឹកថ្វាយព្រះអង្គ ។ [១៤]ប៉ុន្តែ លោកយ៉ូហានប្រកែកថា៖ «ខ្ញុំទេតើដែលត្រូវទទួលពិធីជ្រមុជទឹកពីលោក ម្ដេចក៏លោកមករកខ្ញុំវិញ!» ។ [១៥]ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ឥឡូវនេះសុំធ្វើសិនចុះ ធ្វើដូច្នេះ ទើបស្របតាមគ្រប់សេចក្ដីដែលព្រះជាម្ចាស់បានបង្គាប់ទុកមក» ។ លោកយ៉ូហានក៏យល់ព្រម ។ [១៦]ពេលព្រះយេស៊ូទទួលពិធីជ្រមុជទឹករួចហើយ ទ្រង់យាងឡើងពីទឹក ស្រាប់តែផ្ទៃមេឃបើកចំហ ព្រះអង្គទតឃើញព្រះវិញ្ញាណរបស់ព្រះជាម្ចាស់យាងចុះ ដូចសត្វព្រាបមកសណ្ឋិតលើព្រះអង្គ ។ [១៧]ពេលនោះ មានព្រះសូរសៀងពីលើមេឃមកថា៖ «លោកនេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង! យើងគាប់ចិត្តនឹងព្រះអង្គណាស់!» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# វដ្ដសែសិបថ្ងៃ

# ឬ

# វដ្ដអប់រំពិសេស

# ថ្ងៃពុធរោយផេះ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម ទន ៨០,៨.១៩-២០

**បន្ទរ-** បពិត្រព្រះអម្ចាស់! ព្រះបន្ទូលព្រះអង្គ ជាសេចក្ដីពិត!
ធម្មវិន័យរបស់ព្រះអង្គរំដោះយើងខ្ញុំ!

**អត្ថបទ-** ឱ! ព្រះអម្ចាស់អើយ! សូមនាំយើងខ្ញុំមកវិញ យើងខ្ញុំនឹងមិនបែកចិត្តពីព្រះអង្គ
ទៀតឡើយ ។ សូមនាំយើងខ្ញុំមកវិញ! នោះយើងខ្ញុំនឹងបានរួចជីវិត! **បន្ទរ-** ...

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** ៦,១-៦.១៦-១៨

នៅគ្រានោះ ក្រុមសាវ័កជួបជុំជាមួយព្រះយេស៊ូនៅលើភ្នំ ។ ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ ១«កុំ
ធ្វើបុណ្យទាននៅមុខមនុស្សម្នា ដើម្បីឲ្យតែគេឃើញនោះឡើយ ។ ធ្វើបែបនេះអ្នករាល់គ្នាពុំបានទទួល
រង្វាន់អ្វី ពីព្រះបិតារបស់អ្នករាល់គ្នា ដែលគង់នៅស្ថានបរមសុខទេ ។ ២ពេលណាអ្នកធ្វើទានដល់ជនក្រី
ក្រ កុំស្រែកប្រកាសខ្លែងៗ ដូចពួកមានពុតតែងធ្វើនៅក្នុងធម្មសាលា ឬនៅតាមផងផ្លូវ ដើម្បីឲ្យមនុស្ស
ម្នាកោតសរសើរនោះឡើយ ។ ខ្ញុំសុំប្រាប់អ្នករាល់គ្នាឲ្យដឹងច្បាស់ថា អ្នកទាំងនោះបានទទួលរង្វាន់របស់
គេហើយ ។ ៣រីឯអ្នកវិញ កាលណាដៃស្ដាំអ្នកធ្វើទានមិនបាច់ឲ្យដៃឆ្វេងដឹងឡើយ ៤ដើម្បីឲ្យទានរបស់
អ្នកនៅស្ងាត់កំបាំង ។ ព្រះបិតារបស់អ្នកទតឃើញអំពើដែលអ្នកធ្វើនៅក្នុងទីស្ងាត់កំបាំង ទ្រង់នឹង
ប្រទានរង្វាន់មកអ្នកវិញ ។ ៥កាលណាអ្នករាល់គ្នាអធិស្ឋាន កុំធ្វើដូចពួកអ្នកមានពុត ដែលចូលចិត្តឈរ
អធិស្ឋាននៅក្នុងធម្មសាលានិងនៅត្រង់ថ្នល់កែង ដើម្បីឲ្យមនុស្សម្នាឃើញនោះឡើយ ។ ខ្ញុំសុំប្រាប់ឲ្យអ្នក
រាល់គ្នាដឹងច្បាស់ថា ពួកទាំងនោះបានទទួលរង្វាន់របស់គេហើយ ។ ៦រីឯអ្នកវិញ កាលណាអ្នកអធិស្ឋាន
ត្រូវចូលទៅក្នុងបន្ទប់ បិទទ្វារឲ្យជិត ហើយទូលទៅកាន់ព្រះបិតារបស់អ្នក ដែលគង់នៅក្នុងទីស្ងាត់
កំបាំង ។ ព្រះបិតារបស់អ្នកដែលទតឃើញ នៅក្នុងទីស្ងាត់កំបាំង ទ្រង់នឹងប្រទានរង្វាន់មកអ្នកជាពុំខា
ន ។ ១៦កាលណាអ្នករាល់គ្នាតមអាហារ កុំធ្វើមុខក្រៀមដូចពួកអ្នកមានពុតនោះឡើយ ។ ពួកគេបង្ហាញ
ទឹកមុខឲ្យអ្នកដទៃឃើញថា ខ្លួនតមអាហារ ។ ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នកទាំងនោះបាន
ទទួលរង្វាន់របស់គេហើយ ។ ១៧រីឯអ្នកវិញ កាលណាអ្នកតមអាហារ ត្រូវលាបទឹកអប់លើក្បាលហើយ
លុបមុខផង ១៨កុំឲ្យមនុស្សម្នាឃើញថា អ្នកតមឡើយ គឺឲ្យតែព្រះបិតារបស់អ្នកដែលគង់នៅក្នុងទីស្ងាត់
កំបាំង ទតឃើញប៉ុណ្ណោះ ពេលនោះព្រះបិតារបស់អ្នក ដែលទតឃើញនៅក្នុងទីស្ងាត់កំបាំងនឹងប្រទាន
រង្វាន់មកអ្នកជាមិនខាន» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១ ក្នុងរដូវសែសិបថ្ងៃ ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **មថ ៤,៤**

**ប-** បពិត្រព្រះអម្ចាស់! ព្រះបន្ទូលព្រះអង្គ ជាសេចក្តីពិត!
ហើយធម្មវិន័យរបស់ព្រះអង្គ រំដោះមនុស្សលោកដែរ!

**គ-** មនុស្សមិនមែនរស់ដោយសារតែអាហារប៉ុណ្ណោះទេ
គឺរស់ដោយសារគ្រប់ព្រះបន្ទូល ដែលចេញមកពីព្រះឱស្ឋ របស់ព្រះជាម្ចាស់ ។ **ប-** ...

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **៤,១-១១**

ក្រោយពីព្រះយេស៊ូទទួលពិធីជ្រមុជទឹក ១ព្រះវិញ្ញាណនាំព្រះអង្គទៅវាលរហោស្ថាន ឲ្យមារសាតាំង
ល្បួង ។ ២បន្ទាប់ពីបានតមអាហារ អស់រយៈពេលសែសិបថ្ងៃសែសិបយប់មក ព្រះអង្គក៏ឃ្លាន ។

៣មេល្បួងចូលមកជិតព្រះអង្គ ហើយពោលថា៖ «ដោយលោកជាព្រះបុត្រារបស់ព្រះជាម្ចាស់ ដូច្នេះ
សូមធ្វើឲ្យដុំថ្មទាំងនេះទៅជានំប៉័ងមើល៍!» ។ ៤ប៉ុន្តែ ព្រះយេស៊ូមានព្រះបន្ទូលតបទៅវិញថា៖ «ក្នុង
គម្ពីរមានចែងថា "មនុស្សមិនរស់ដោយសារអាហារតែប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ព្រះបន្ទូល
ដែលចេញមកពីព្រះឱស្ឋរបស់ព្រះជាម្ចាស់"» ។

៥ពេលនោះ មារនាំព្រះអង្គទៅក្រុងយេរូសាឡឹមជាក្រុងដ៏វិសុទ្ធ ដាក់ព្រះអង្គលើកំពូលព្រះវិហារ ៦
ហើយពោលថា៖ «ដោយលោកជាព្រះបុត្រារបស់ព្រះជាម្ចាស់ ដូច្នេះ សូមលោតទម្លាក់ខ្លួនចុះទៅ
ក្រោមមើល៍ ដ្បិតក្នុងគម្ពីរមានចែងថា "ព្រះជាម្ចាស់នឹងបញ្ជាឲ្យទេវទូតលាតដៃចាំទ្រលោក មិនឲ្យ
ជើងលោកប៉ះទង្គិចនឹងថ្មឡើយ"» ។ ៧ព្រះយេស៊ូមានព្រះបន្ទូលទៅមារថា៖ «ក្នុងគម្ពីរមានចែងទៀត
ថា "កុំល្បងលព្រះជាម្ចាស់ជាព្រះរបស់អ្នកឡើយ"» ។

៨មារក៏នាំព្រះអង្គទៅលើកំពូលភ្នំមួយយ៉ាងខ្ពស់ ហើយបង្ហាញនគរទាំងប៉ុន្មាន ក្នុងពិភពលោក ឲ្យ
ព្រះអង្គឃើញភោគទ្រព្យរបស់នគរទាំងនោះផង ។ ៩មារទូលព្រះអង្គថា៖ «ប្រសិនបើលោកក្រាប
ថ្វាយបង្គំខ្ញុំ ខ្ញុំនឹងប្រគល់អ្វីៗទាំងនេះឲ្យ!» ។ ១០ព្រះយេស៊ូមានព្រះបន្ទូលទៅមារថា៖ «សាតាំង! ចូរ
ថយចេញទៅ ដ្បិតក្នុងគម្ពីរមានចែងថា "អ្នកត្រូវថ្វាយបង្គំព្រះអម្ចាស់ជាព្រះរបស់អ្នក និងគោរព
បម្រើតែព្រះអង្គប៉ុណ្ណោះ"» ។

១១ពេលនោះ មារចាកចេញពីព្រះអង្គទៅ ហើយមានពួកទេវទូតនាំគ្នាមកបម្រើព្រះអង្គ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២ ក្នុងរដូវសែសិបថ្ងៃ ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម មថ ១៧,៥**

**ប-** សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះគ្រីស្ត ជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលមានព្រះជន្មគង់នៅ ។

**គ-** មានព្រះសូរសៀងបន្លឺពីក្នុងពពកមកថា៖ “អ្នកនេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង ចូរស្ដាប់ព្រះអង្គចុះ!” ។ **ប-** ...

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **១៧,១-៩**

[១]ព្រះយេស៊ូនាំលោកសិលា លោកយ៉ាកុប និង លោកយ៉ូហានជាប្អូន ឡើងទៅលើភ្នំដាច់ឡែកពីគេ ។
[២]ពេលនោះ ព្រះអង្គប្រែជាមានទ្រង់ទ្រាយប្លែកពីមុន នៅមុខសាវ័កទាំងបីនាក់ គឺព្រះភ័ក្ត្ររបស់ព្រះអង្គ
បញ្ចេញរស្មីចែងចាំងដូចពន្លឺថ្ងៃ ហើយព្រះពស្ត្ររបស់ព្រះអង្គ ត្រឡប់ជាមានពណ៌សដូចពន្លឺ ។ [៣]សាវ័ក
ទាំងបីបានឃើញលោកម៉ូសេ និងព្យាការីអេលី សន្ទនាជាមួយព្រះយេស៊ូ ។ [៤]លោកសិលាទូលព្រះអង្គ
ថា៖ «ព្រះអម្ចាស់! យើងខ្ញុំបាននៅទីនេះ ប្រសើរណាស់ បើព្រះអង្គសព្វព្រះហឫទ័យ ទូលបង្គំនឹងសង់
ពន្លាបី គឺមួយសម្រាប់ព្រះអង្គ មួយសម្រាប់លោកម៉ូសេ និងមួយទៀតសម្រាប់ព្យាការីអេលី» ។ [៥]កាល
លោកសិលាកំពុងតែមានប្រសាសន៍នៅឡើយ ស្រាប់តែមានពពកដ៏ភ្លឺមកគ្របបាំងគេទាំងអស់គ្នា ហើយ
មានព្រះសូរសៀងបន្លឺពីក្នុងពពកមកថា៖ «អ្នកនេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង យើងគាប់ចិត្ត
នឹងព្រះអង្គណាស់ ចូរស្ដាប់ព្រះអង្គចុះ!» ។ [៦]ក្រុមសាវ័កឮដូច្នោះ ក៏នាំគ្នាក្រាបចុះ ដាក់មុខដល់ដី ព្រោះ
គេភ័យខ្លាចជាខ្លាំង ។ [៧]ព្រះយេស៊ូយាងចូលទៅជិតដាក់ព្រះហស្ដលើគេ ទាំងមានព្រះបន្ទូលថា៖ «ចូរនាំ
គ្នាក្រោកឡើង កុំខ្លាចអី!» ។ [៨]កាលក្រុមសាវ័កងើបមុខឡើង គេឃើញតែព្រះយេស៊ូមួយព្រះអង្គ
ប៉ុណ្ណោះពុំឃើញមាននរណាទៀតឡើយ ។

[៩]ពេលព្រះអង្គយាងចុះពីលើភ្នំជាមួយសាវ័កទាំងបី ព្រះយេស៊ូហាមប្រាមគេថា៖ «កុំនិយាយប្រាប់
នរណា អំពីហេតុការណ៍ដែលអ្នករាល់គ្នាបានឃើញនេះឲ្យសោះ ត្រូវចាំរហូតដល់បុត្រមនុស្សមានជីវិតថ្មី
សិន» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៣ ក្នុងរដូវសែសិបថ្ងៃ ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **យហ ៤,៤២.១៥**

**ប-** សូមលើកតម្កើងសិរីរុងរឿងព្រះគ្រីស្ត! ព្រះអង្គជាព្រះប្រាជ្ញាញាណនៃព្រះជាម្ចាស់ ដ៏មានព្រះជន្មគង់នៅអស់កល្បជានិច្ច ។ សូមលើកតម្កើងសិរីរុងរឿងព្រះអម្ចាស់ ។

**គ-** បពិត្រព្រះអម្ចាស់! ព្រះអង្គពិតជាព្រះសង្គ្រោះរបស់មនុស្សលោកមែន! ។ សូមព្រះមេត្តាប្រទានទឹកដែលផ្តល់ជីវិតមកយើងខ្ញុំផង កុំឲ្យយើងខ្ញុំស្រេកទៀតឡើយ ។ **ប-** ...

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** **៤,៥-៤២ (ឬយ៉ាងខ្លី ៤,៥-១៥.១៩ខ-២៦.៣៩ក.៤០-៤២)**

៥ព្រះយេស៊ូយាងមកដល់ភូមិមួយរបស់ជនជាតិសាម៉ារី ឈ្មោះភូមិស៊ីខា នៅជិតចំការដែលលោក
យ៉ាកុបបានចែកឲ្យលោកយ៉ូសែបជាកូន ។ ៦នៅទីនោះ មានអណ្តូងទឹកមួយ ឈ្មោះ "អណ្តូងលោក
យ៉ាកុប" ។ ព្រះយេស៊ូអស់កម្លាំងក្នុងការធ្វើដំណើរ ក៏គង់នៅមាត់អណ្តូង ។ ពេលនោះ ប្រហែលជាថ្ងៃ
ត្រង់ ។ ៧មានស្ត្រីសាសន៍សាម៉ារីម្នាក់មកដងទឹក ។ ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «ខ្ញុំសុំទឹកទទួល
ទានបន្តិច» ។ ៨(សាវ័កនាំគ្នាទៅរកទិញស្បៀងអាហារនៅឯភូមិ) ។ ៩ស្ត្រីសាម៉ារីទូលព្រះអង្គថា៖
«លោកជាសាសន៍យូដា ម្តេចក៏លោកមកសុំទឹកនាងខ្ញុំជាស្ត្រីសាសន៍សាម៉ារីពិសាដូច្នេះ?» (ដ្បិតសាសន៍
យូដា និងសាសន៍សាម៉ារីមិនត្រូវគ្នាទេ) ។ ១០ព្រះយេស៊ូមានព្រះបន្ទូលតបទៅនាងថា៖ «ប្រសិនបើនាង
ស្គាល់ព្រះអំណោយទានរបស់ព្រះជាម្ចាស់ និងស្គាល់អ្នកដែលនិយាយទៅកាន់នាងថា "ខ្ញុំសុំទឹកទទួលទាន
បន្តិច" នោះនាងមុខជាសុំទឹកពីលោកវិញពុំខាន ហើយលោកនឹងឲ្យទឹកដល់នាង គឺជាទឹកដែលផ្តល់
ជីវិត» ។ ១១នាងទូលព្រះអង្គថា៖ «លោកម្ចាស់! លោកគ្មានអ្វីដងទឹកសោះ រីឯអណ្តូងសោតក៏ជ្រៅ
ទៀតផង តើលោកបានទឹកដែលផ្តល់ជីវិតនោះពីណាមក? ។ [១២តើលោកមានឋានៈធំជាងលោកយ៉ា
កុប ជាបុព្វបុរសរបស់យើង ដែលបានទុកអណ្តូងនេះឲ្យយើងឬ? ។ លោកយ៉ាកុបនិងកូនចៅរបស់
លោកបានពិសាទឹកអណ្តូងនេះ ហើយសត្វរបស់លោក ក៏បានផឹកទឹកអណ្តូងនេះដែរ» ។ ១៣ព្រះយេស៊ូមាន
ព្រះបន្ទូលទៅនាងថា៖ «អស់អ្នកដែលពិសាទឹកនេះនៅតែស្រេកតទៅមុខទៀត ១៤រីឯអ្នកដែលពិសា
ទឹកខ្ញុំឲ្យនោះ នឹងមិនស្រេកទៀតសោះឡើយ ដ្បិតទឹកខ្ញុំឲ្យនឹងបានទៅជាប្រភពទឹកដែលផុសឡើងក្នុង
អ្នកនោះ ផ្តល់ជីវិតអស់កល្បជានិច្ច» ។ ១៥ស្ត្រីនោះទូលព្រះអង្គថា៖ «លោកម្ចាស់! សូមមេត្តាផ្តល់ទឹក
នោះមកនាងខ្ញុំផង! កុំឲ្យនាងខ្ញុំស្រេក និងកុំឲ្យរវល់មកដងទឹកអណ្តូងនេះទៀត» ។

១៦ព្រះអង្គមានព្រះបន្ទូលទៅនាងថា៖ «សុំអញ្ជើញទៅហៅប្ដីនាង រួចត្រឡប់មកវិញ» ។ ១៧ស្ដ្រីនោះ
ទូលព្រះអង្គថា៖ «នាងខ្ញុំគ្មានប្ដីទេ» ។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ «នាងនិយាយថា នាងគ្មានប្ដី
ដូច្នេះ ត្រូវមែន ១៨ព្រោះនាងធ្លាប់មានប្ដីប្រាំមកហើយ រីឯបុរសដែលនៅជាមួយនាងសព្វថ្ងៃ មិនមែនជា
ប្ដីរបស់នាងទេ! នាងនិយាយត្រង់មែន!» ។ ១៩នាងទូលព្រះអង្គថា៖ ]

«លោកម្ចាស់! នាងខ្ញុំយល់ថា លោកពិតជាព្យាការីមែន ។ ២០បុព្វបុរសរបស់យើងនាំគ្នាថ្វាយបង្គំព្រះ
ជាម្ចាស់នៅលើភ្នំនេះ តែពួកលោកជាសាសន៍យូដាតែងនិយាយថា ត្រូវថ្វាយបង្គំព្រះអង្គនៅក្រុងយេរូ
សាឡឹមវិញ» ។ ២១ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «នាងអើយ! ជឿខ្ញុំចុះ! ដល់ពេលកំណត់ មិន
មែននៅលើភ្នំនេះ ឬនៅក្រុងយេរូសាឡឹមទៀតទេ ដែលអ្នករាល់គ្នានឹងថ្វាយបង្គំព្រះបិតា ។ ២២អ្នករាល់
គ្នាមិនស្គាល់ព្រះអង្គដែលអ្នករាល់គ្នាថ្វាយបង្គំទេ រីឯយើងវិញ យើងស្គាល់ព្រះអង្គដែលយើងថ្វាយបង្គំ
ដ្បិតការសង្គ្រោះ ចេញមកពីជនជាតិយូដា ។ ២៣ប៉ុន្តែ ដល់ពេលកំណត់ គឺឥឡូវហ្នឹងហើយ អ្នកថ្វាយបង្គំ
ដ៏ពិតប្រាកដនឹងថ្វាយបង្គំព្រះបិតាតាមព្រះវិញ្ញាណនិងសេចក្ដីពិត ដ្បិតព្រះបិតាសព្វព្រះហឫទ័យនឹងអ្នក
ថ្វាយបង្គំបែបនេះឯង ។ ២៤ព្រះជាម្ចាស់ជាវិញ្ញាណ ហេតុនេះ អស់អ្នកដែលថ្វាយបង្គំព្រះអង្គ ត្រូវតែ
ថ្វាយបង្គំតាមវិញ្ញាណនិងតាមសេចក្ដីពិត» ។ ២៥ស្ដ្រីនោះទូលព្រះអង្គថា៖ «នាងខ្ញុំដឹងហើយថា ព្រះមេ
ស្ស៊ីហៅ “ព្រះគ្រីស្ដ” នឹងយាងមក ។ កាលណាព្រះអង្គយាងមកដល់ ទ្រង់នឹងប្រទានឲ្យយើងដឹងសព្វ
គ្រប់ទាំងអស់» ។ ២៦ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «ខ្ញុំនេះហើយ គឺខ្ញុំដែលកំពុងតែនិយាយ
ជាមួយនាង» ។

២៧ពេលនោះ ពួកសាវ័កត្រឡប់មកដល់ ឃើញព្រះអង្គកំពុងនិយាយជាមួយស្ដ្រីដូច្នេះ គេងឿងឆ្ងល់
ជាខ្លាំង តែគ្មាននរណាទូលសួរព្រះអង្គថា ព្រះអង្គសួររកអ្វី ឬហេតុដូចម្ដេចក៏មានព្រះបន្ទូលជាមួយនាង
ឡើយ ។ ២៨ស្ដ្រីនោះទុកក្អមចោល រត់ចូលទៅក្នុងភូមិ ប្រាប់អ្នកស្រុកថា៖ ២៩«សុំមកមើលបុរសម្នាក់
លោកមានប្រសាសន៍ប្រាប់ខ្ញុំ នូវអំពើទាំងប៉ុន្មានដែលខ្ញុំបានប្រព្រឹត្ត ។ លោកនោះជាព្រះគ្រីស្ដហើយ
មើលទៅ!» ។ ៣០អ្នកស្រុកនាំគ្នាចេញពីភូមិទៅរកព្រះយេស៊ូ ។ ៣១ក្នុងពេលជាមួយគ្នានោះ ក្រុមសាវ័ក
ទូលព្រះអង្គថា៖ «លោកគ្រូ! សូមអញ្ជើញពិសា!» ។ ៣២ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំមាន
អាហារបរិភោគហើយ ជាអាហារដែលអ្នករាល់គ្នាពុំស្គាល់!» ។ ៣៣ក្រុមសាវ័កក៏និយាយគ្នាថា៖
«ប្រហែលជាមាននរណាម្នាក់ យកអាហារមកជូនលោកហើយទេដឹង?» ។ ៣៤ព្រះយេស៊ូមានព្រះបន្ទូល

ទៅគេថា៖ «អាហាររបស់ខ្ញុំ គឺធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ ដែលបានចាត់ខ្ញុំឲ្យមក ព្រមទាំង
បង្ហើយកិច្ចការរបស់ព្រះអង្គឲ្យបានសម្រេច ។ [៣៥] អ្នករាល់គ្នាតែងពោលថា “បួនខែទៀតដល់រដូវ
ចម្រូត” ។ រីឯខ្ញុំវិញ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា ចូរមើលទៅវាលស្រែមើល៍ស្រូវទុំល្មមច្រូតហើយ ។ [៣៦]អ្នក
ច្រូតបានប្រាក់ឈ្នួលរបស់ខ្លួន ហើយកំពុងប្រមូលផលទុកសម្រាប់ជីវិតអស់កល្បជានិច្ច ។ ដូច្នេះ អ្នក
សាបព្រោះ និងអ្នកច្រូតកាត់ បានសប្បាយរួមជាមួយគ្នា [៣៧]ស្របតាមពាក្យចាស់លោកថា៖ “ម្នាក់
ព្រោះ ម្នាក់ទៀតច្រូត” ។ [៣៨]ខ្ញុំបានចាត់អ្នករាល់គ្នា ឲ្យទៅច្រូតនៅក្នុងស្រែដែលអ្នករាល់គ្នាពុំបានធ្វើ
ការនឿយហត់ គឺអ្នកផ្សេងទៀតបានធ្វើការនឿយហត់ ហើយអ្នករាល់គ្នាទទួលផលពីការនឿយហត់
របស់អ្នកទាំងនោះ» ។

[៣៩]ក្នុងភូមិនោះ មានអ្នកស្រុកសាម៉ារីជាច្រើនបានជឿលើព្រះយេស៊ូ ដោយសារពាក្យដែលស្ត្រីនោះ
បានបញ្ជាក់ប្រាប់ថា “លោកមានប្រសាសន៍ប្រាប់ខ្ញុំនូវអំពើទាំងប៉ុន្មាន ដែលខ្ញុំបានប្រព្រឹត្ត” ។ [៤០]ហេតុ
នេះហើយ បានជាកាលជនជាតិសាម៉ារីទៅគាល់ព្រះអង្គ គេអង្វរសូមព្រះអង្គគង់នៅជាមួយគេ ព្រះអង្គ
យល់ព្រមគង់នៅទីនោះពីរថ្ងៃ ។ [៤១]មានមនុស្សច្រើនជាងនោះទៅទៀត បានជឿលើព្រះអង្គ ដោយបាន
ឮព្រះបន្ទូលព្រះអង្គផ្ទាល់ ។ [៤២]ពួកគេនិយាយទៅកាន់ស្ត្រីនោះថា៖ «ឥឡូវនេះ យើងជឿ មិនមែនត្រឹម
តែដោយបានឮពាក្យនាងប៉ុណ្ណោះទេ គឺមកពីយើងបានឮព្រះអង្គមានព្រះបន្ទូលផ្ទាល់នឹងត្រចៀកថែម
ទៀតផង ហើយយើងដឹងថា ព្រះអង្គពិតជាព្រះសង្គ្រោះរបស់មនុស្សលោកមែន» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៤ ក្នុងរដូវសែសិបថ្ងៃ ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** យហ ៨,១២

**ប-** បពិត្រព្រះយេស៊ូជាអម្ចាស់! សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ។

**គ-** បពិត្តព្រះយេស៊ូគ្រីស្ត! ព្រះអង្គពិតជាពន្លឺបំភ្លឺពិភពលោក ។ អ្នកណាទៅតាមព្រះអង្គ
អ្នកនោះនឹងមិនដើរក្នុងភាពងងឹតឡើយ គឺគេមានពន្លឺនាំតែ ទៅកាន់ជីវិត ។ **ប-** ...

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** ៩,១-៤១ (ឬយ៉ាងខ្លី ១.៦-៩.១៣-១៧.៣៤-៣៨)

១ព្រះយេស៊ូយាងចេញពីព្រះវិហារ ទតឃើញមនុស្សម្នាក់ខ្វាក់តាំងពីកំណើតមក ។
២ក្រុមសាវ័កទូលសួរព្រះអង្គថា៖ «ព្រះគ្រូ! បុរសនេះកើតមកខ្វាក់ដូច្នេះ តើបណ្ដាលមកពីបាប
របស់នរណា? បាបរបស់គាត់ផ្ទាល់ ឬបាបរបស់ឪពុកម្ដាយគាត់?» ។ ៣ព្រះយេស៊ូមានព្រះបន្ទូលតប
ថា៖ «គាត់ខ្វាក់ មិនមែនមកពីបាបរបស់ឪពុកម្ដាយគាត់ ឬបាបរបស់គាត់ទេ គាត់ខ្វាក់ដូច្នេះ ដើម្បីឲ្យ
ព្រះជាម្ចាស់បង្ហាញកិច្ចការរបស់ព្រះអង្គនៅក្នុងគាត់ ។ ៤យើងត្រូវធ្វើកិច្ចការរបស់ព្រះអង្គ ដែលបាន
ចាត់ខ្ញុំឲ្យមកទាន់នៅភ្លឺនៅឡើយ ដ្បិតដល់ពេលយប់ គ្មាននរណាអាចធ្វើការបានឡើយ ។ ៥ពេលខ្ញុំស្ថិត
នៅក្នុងពិភពលោកនេះ ខ្ញុំជាពន្លឺបំភ្លឺពិភពលោក» ។ ៦កាលព្រះអង្គមានព្រះបន្ទូលដូច្នេះហើយ
ព្រះអង្គស្ដោះទឹកព្រះឱស្ឋទៅលើដី ធ្វើភក់លាបភ្នែកមនុស្សខ្វាក់នោះ ៧រួចទ្រង់មានព្រះបន្ទូលទៅ
គាត់ថា៖ «សុំអញ្ជើញទៅលុបមុខនៅស្រះស៊ីឡោមទៅ!» (ពាក្យ “ស៊ីឡោម” នេះមានន័យថា “អ្នក
ដែលគេចាត់ឲ្យទៅ”) ។ គាត់ក៏ចេញទៅលុបមុខ ពេលត្រឡប់មកវិញ គាត់មើលឃើញ ។ ៨អ្នកជិត
ខាង និងអស់អ្នកដែលធ្លាប់ឃើញគាត់សុំទានកាលពីមុន នាំគ្នាពោលថា៖ «បុរសនេះជាអ្នកដែលតែង
អង្គុយសុំទានទេតើ!» ។ ៩អ្នកខ្លះពោលថា៖ «គាត់មែន!» ។ ខ្លះទៀតថា៖ «មិនមែនទេ! អ្នកនេះ
មានមុខដូចគាត់!» ។ រីឯបុរសនោះវិញ គាត់ពោលថា៖ «គឺខ្ញុំហ្នឹងហើយ!» ។
១០គេក៏នាំគ្នាសួរគាត់ថា៖ «ម្ដេចបានជាភ្នែកអ្នកភ្លឺដូច្នេះ?» ។ ១១គាត់ឆ្លើយថា៖ «មានលោកម្នាក់
ឈ្មោះយេស៊ូ ធ្វើភក់យកមកលាបភ្នែកខ្ញុំ ហើយប្រាប់ខ្ញុំថា “សុំអញ្ជើញទៅលុបមុខនៅស្រះស៊ីឡោម
ទៅ!” ខ្ញុំក៏ទៅលុបមុខ ហើយខ្ញុំមើលឃើញ» ។ ១២គេសួរគាត់ថា៖ «លោកនោះនៅឯណា?» ។ គាត់
ឆ្លើយថា៖ «ខ្ញុំមិនដឹងទេ!» ។
១៣គេនាំអ្នកដែលខ្វាក់ពីមុននោះ ទៅជួបពួកខាងគណៈផារីស៊ី ។ ១៤ថ្ងៃដែលព្រះយេស៊ូធ្វើភក់ និង
ប្រោសអ្នកខ្វាក់ឲ្យបានភ្លឺនោះ ជាថ្ងៃសប្ប័ទ ១៥ហេតុនេះហើយ បានជាពួកខាងគណៈផារីស៊ីនាំគ្នាសួរម្ដង
ទៀតអំពីហេតុការណ៍ដែលធ្វើឲ្យភ្នែកគាត់ភ្លឺ ។ គាត់ឆ្លើយថា៖ «លោកបានយកភក់ដាក់ពីលើភ្នែកខ្ញុំ ខ្ញុំ
ទៅលុបមុខ ហើយក៏មើលឃើញ» ។ ១៦ពួកខាងគណៈផារីស៊ីខ្លះពោលថា៖ «អ្នកនោះមិនមែនមកពីព្រះ

ជាម្ចាស់ទេ ដ្បិតគាត់ពុំគោរពវិន័យសម្រាប់ថ្ងៃសប្ប័ទ» ។ អ្នកខ្លះទៀតពោលថា៖ «តើមនុស្សបាបអាច
ធ្វើទីសម្គាល់ដ៏អស្ចារ្យនេះដូចម្ដេចបាន?» ពួកគេក៏បាក់បែកគ្នា ។ [១៧]គេសួរអ្នកដែលខ្វាក់ពីមុននោះម្ដង
ទៀតថា៖ «ចុះអ្នកវិញ តើអ្នកថា លោកដែលធ្វើឲ្យអ្នកបានភ្លឺនោះជានរណា?» ។ គាត់ឆ្លើយថា៖
«លោកពិតជាព្យាការីមែន!» ។

[១៨]ប៉ុន្តែ ជនជាតិយូដានៅតែមិនជឿថា កាលពីមុន បុរសនេះខ្វាក់ ហើយឥឡូវបានមើលឃើញនោះ
ទាល់តែហៅឪពុកម្ដាយគាត់មកសួរសិន ។ [១៩]គេសួរទៅឪពុកម្ដាយគាត់ថា៖ «អ្នកនេះពិតជាកូនរបស់
អ្នក ដែលអ្នកថាខ្វាក់ពីកំណើតមែនឬ? ចុះឥឡូវម្ដេចក៏ភ្នែកគាត់ភ្លឺ?» ។ [២០]ឪពុកម្ដាយគាត់ឆ្លើយថា៖
«យើងខ្ញុំដឹងថា វាពិតជាកូនរបស់យើងខ្ញុំមែន ហើយកើតមកខ្វាក់! ។ [២១]ត្រង់ឯភ្នែកវាបានភ្លឺ ដោយ
ហេតុយ៉ាងណាៗនោះ យើងខ្ញុំមិនដឹងទេ ហើយនរណាបានធ្វើឲ្យភ្នែកវាភ្លឺនោះ ក៏យើងមិនដឹងដែរ! ។
សូមអស់លោកសួរវាទៅ វាធំហើយ វាឆ្លើយខ្លួនឯងបាន!» ។ [២២]ឪពុកម្ដាយគាត់និយាយដូច្នេះ មកពី
ខ្លាចជនជាតិយូដា ព្រោះជនជាតិយូដារួមគំនិតគ្នាបណ្ដេញអស់អ្នកដែលទទួលស្គាល់ថា ព្រះយេស៊ូជា
ព្រះគ្រីស្ដ ចេញពីធម្មសាលារបស់គេ ។ [២៣]ហេតុនេះហើយ បានជាគាត់ពោលថា “វាធំហើយ សូមសួរ
វាទៅ!” ។

[២៤]ពួកខាងគណៈផារីស៊ី បានហៅបុរសដែលខ្វាក់ពីមុននោះ មកសួរជាលើកទីពីរ ។ គេពោលទៅ
គាត់ថា៖ «ត្រូវនិយាយការពិតនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់! យើងដឹងថាអ្នកនោះ ពិតជាមនុស្ស
បាបមែន!» ។ [២៥]បុរសនោះតបថា៖ «លោកនោះជាមនុស្សបាប ឬយ៉ាងណា នោះ ខ្ញុំមិនដឹងទេ ខ្ញុំដឹង
តែម្យ៉ាង គឺពីមុនខ្ញុំខ្វាក់ ឥឡូវនេះ ខ្ញុំមើលឃើញ» ។ [២៦]ពួកគេសួរគាត់ថា៖ «តើអ្នកនោះបានធ្វើអ្វីដល់
អ្នក? គាត់បានធ្វើឲ្យភ្នែកអ្នកភ្លឺដោយវិធីណា?» ។ [២៧]គាត់ឆ្លើយទៅគេវិញថា៖ «ខ្ញុំបានជម្រាបអស់
លោករួចមកហើយ តែអស់លោកពុំស្ដាប់ខ្ញុំទេ ។ ហេតុដូចម្ដេច បានជាអស់លោកចង់ឲ្យខ្ញុំនិយាយម្ដង
ទៀតដូច្នេះ? ប្រហែល អស់លោកចង់ធ្វើជាសិស្សរបស់លោកនោះដែរហើយមើលទៅ!» ។ [២៨]ពួកខាង
គណៈផារីស៊ីក៏ជេរប្រមាថគាត់ថា៖ «ឯងទេតើជាសិស្សរបស់គាត់! រីឯយើងវិញ យើងជាសិស្សរបស់
លោកម៉ូសេ! ។ [២៩]យើងដឹងថា ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេមែន ។ រីឯអ្នកនោះវិញ
យើងមិនដឹងថាគាត់មកពីណាទេ!» ។ [៣០]បុរសនោះនិយាយតបទៅគេថា៖ «លោកនោះបានធ្វើឲ្យភ្នែក
ខ្ញុំភ្លឺ តែអស់លោកមិនដឹងថា គាត់មកពីណា ដូច្នេះគួរឲ្យឆ្ងល់ណាស់! ។ [៣១]យើងដឹងស្រាប់ហើយថា ព្រះ
ជាម្ចាស់មិនស្ដាប់ពាក្យរបស់មនុស្សបាបទេ ព្រះអង្គស្ដាប់តែពាក្យរបស់អ្នកគោរពប្រណិប័តន៍ព្រះអង្គ និង
ប្រព្រឹត្តតាមព្រះហឫទ័យព្រះអង្គប៉ុណ្ណោះ ។ [៣២]តាំងពីដើមរៀងមក យើងមិនដែលឮថា មាននរណាធ្វើ
ឲ្យភ្នែកមនុស្សខ្វាក់ពីកំណើតបានភ្លឺនោះឡើយ ។ [៣៣]ប្រសិនបើ លោកនោះមិនមកពីព្រះជាម្ចាស់ទេ
លោកមិនអាចធ្វើការអ្វីបានទាល់តែសោះ» ។

៣៤ពួកគេនាំគ្នាពោលទៅគាត់ថា៖ «ឯងជាមនុស្សជាប់បាបពេញខ្លួន តាំងពីកំណើតមកហើយឯង
ហ៊ានប្រដៅយើងទៀត!» ។ គេក៏បណ្ដេញគាត់ចេញទៅខាងក្រៅ ។

៣៥ព្រះយេស៊ូជ្រាបថា គេបានបណ្ដេញគាត់ ។ កាលព្រះអង្គជួបគាត់ ទ្រង់មានព្រះបន្ទូលសួរថា៖
«តើអ្នកជឿលើបុត្រមនុស្សឬទេ?» ។ ៣៦គាត់ទូលព្រះអង្គថា៖ «លោកម្ចាស់អើយ! តើនរណាជាបុត្រ
មនុស្ស សូមប្រាប់ខ្ញុំឲ្យដឹងផង ដើម្បីឲ្យខ្ញុំជឿលើព្រះអង្គ» ។ ៣៧ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖
«អ្នកឃើញលោកស្រាប់ គឺអ្នកដែលកំពុងតែនិយាយជាមួយអ្នកហ្នឹងហើយ ជាបុត្រមនុស្ស» ។ ៣៨គាត់
ទូលព្រះយេស៊ូថា៖ «បពិត្រព្រះអម្ចាស់! ទូលបង្គំជឿហើយ» ។ គាត់ក៏ក្រាបថ្វាយបង្គំព្រះអង្គ ។

៣៩បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ខ្ញុំមកក្នុងពិភពលោកនេះ ដើម្បីវិនិច្ឆ័យចិត្តមនុស្ស គឺ
ឲ្យមនុស្សខ្វាក់មើលឃើញ ហើយឲ្យមនុស្សមើលឃើញ ត្រឡប់ទៅជាខ្វាក់វិញ» ។ ៤០ពួកខាងគណៈផារី
ស៊ីខ្លះ ដែលនៅទីនោះជាមួយព្រះអង្គ បានឮដូច្នេះ ក៏ទូលព្រះអង្គថា៖ «ប្រហែលជាលោកចង់ថា យើង
ខ្ញុំនេះជាមនុស្សខ្វាក់ដែរហើយមើលទៅ!» ។ ៤១ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយទៅគេវិញថា៖ «ប្រសិន
បើអ្នករាល់គ្នាខ្វាក់មែន អ្នករាល់គ្នាគ្មានបាបទេ ។ ផ្ទុយទៅវិញ មកពីអ្នករាល់គ្នាថា ខ្លួនមើលឃើញ
ដូច្នេះហើយបានជាអ្នករាល់គ្នានៅតែជាប់បាបរហូត!» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៥ ក្នុងរដូវសែសិបថ្ងៃ ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **យហ ១១,២៥**

**ប-** បពិត្រព្រះអម្ចាស់! យើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងព្រះអង្គ ។

**គ-** បពិត្រព្រះអម្ចាស់! ព្រះអង្គពិតជាប្រោសមនុស្សឲ្យមានជីវិតថ្មី នឹងផ្ដល់ឲ្យគេមានជីវិតពិតមែន ។ អ្នកណាជឿលើព្រះអង្គ មិនត្រូវស្លាប់ឡើយ ។ **ប-** ...

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** **១១,១-៤៥ (ឬយ៉ាងខ្លី ១១,៣-៧.១៧.២០-២៧.៣៨-៤៥)**

[១]នៅភូមិបេតថានី មានបុរសម្នាក់ឈ្មោះឡាសារ គាត់មានជំងឺ ។ នាងម៉ាថា និងនាងម៉ារី ជាបង
ស្រីរបស់គាត់ ក៏រស់នៅក្នុងភូមិនោះដែរ ។ [២]នាងម៉ារីនេះ ជាស្ត្រីម្នាក់ ដែលបានចាក់ប្រេងក្រអូបលើព្រះ
បាទារបស់ព្រះអម្ចាស់ ព្រមទាំងបានយកសក់របស់នាងមកជូតផង ។ រីឯលោកឡាសារ ដែលឈឺនោះ
ត្រូវជាប្អូនបង្កើតរបស់នាង ។ [៣]នាងទាំងពីរនាក់បានចាត់គេឲ្យទៅទូលព្រះយេស៊ូថា៖ «លោកម្ចាស់!
អ្នកដែលលោកស្រឡាញ់ កំពុងតែមានជំងឺ» ។ [៤]កាលព្រះយេស៊ូជ្រាបដំណឹងនេះ ព្រះអង្គមានព្រះបន្ទូល
ថា៖ «ជំងឺនេះកើតឡើង មិនមែនឲ្យគាត់បាត់បង់ជីវិតទេ គឺដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជា
ម្ចាស់ ព្រមទាំងឲ្យព្រះបុត្រារបស់ព្រះអង្គសម្ដែងសិរីរុងរឿងវិញ» ។

[៥]ព្រះយេស៊ូស្រឡាញ់នាងម៉ាថា ប្អូនស្រីរបស់នាង និងលោកឡាសារណាស់ ។ [៦]កាលព្រះអង្គជ្រាប
ដំណឹងថា លោកឡាសារមានជំងឺ ព្រះអង្គគង់នៅកន្លែងដដែលនោះពីរថ្ងៃទៀត [៧]បន្ទាប់មក ព្រះអង្គ
មានព្រះបន្ទូលទៅក្រុមសាវ័កថា៖ «យើងនាំគ្នាត្រឡប់ទៅស្រុកយូដាវិញ» ។

[៨]ក្រុមសាវ័កទូលព្រះអង្គថា៖ «ព្រះគ្រូ! ជនជាតិយូដាទើបនឹងចង់យកដុំថ្មគប់ ធ្វើគុតព្រះអង្គថ្មីៗ
នេះសោះ ហេតុដូចម្ដេចបានជា ព្រះអង្គចង់វិលទៅស្រុកនោះវិញ! » ។ [៩]ព្រះយេស៊ូមានព្រះបន្ទូលតប
ថា៖ «ក្នុងមួយថ្ងៃមានដប់ពីរម៉ោង អ្នកណាដើរនៅពេលថ្ងៃ អ្នកនោះមិនជំពប់ជើងដួលឡើយ ព្រោះ
គេឃើញពន្លឺរបស់ពិភពលោកនេះ ។ [១០]ផ្ទុយទៅវិញអ្នកណាដើរនៅពេលយប់ អ្នកនោះមុខតែជំពប់ជើង
ដួលជាមិនខាន ព្រោះគេគ្មានពន្លឺនៅក្នុងខ្លួនទេ» ។ [១១]ក្រោយមក ព្រះអង្គមានព្រះបន្ទូលទៅគេថែម
ទៀតថា៖ «ឡាសារជាមិត្តសំឡាញ់របស់យើងសំរាន្តលក់ទៅហើយ ខ្ញុំត្រូវតែទៅដាស់គាត់ឲ្យភ្ញាក់ឡើង
វិញ» ។ [១២]ក្រុមសាវ័កទូលព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់ ប្រសិនបើគាត់សំរាន្តលក់ដូច្នេះ គាត់នឹងបាន
ជាវិញមិនខាន» ។ [១៣]តាមពិតព្រះយេស៊ូចង់មានព្រះបន្ទូលថា លោកឡាសារស្លាប់បាត់ទៅហើយ ប៉ុន្តែ

ក្រុមសាវ័កស្មានថាព្រះអង្គមានព្រះបន្ទូលថា គាត់សំរាន្តលក់ធម្មតា ។ [១៤]ហេតុនេះហើយ បានជាព្រះអង្គ
មានព្រះបន្ទូលបញ្ជាក់ យ៉ាងច្បាស់ថា៖ «ឡាសារស្លាប់ទៅហើយ [១៥]បើគិតពីប្រយោជន៍អ្នករាល់គ្នា ខ្ញុំ
សប្បាយចិត្តដោយខ្ញុំមិនបាននៅទីនោះ ដើម្បីឲ្យអ្នករាល់គ្នាបានជឿ ។ ឥឡូវនេះយើងនាំគ្នាទៅផ្ទះ
គាត់» ។ [១៦]ពេលនោះ សាវ័កថូម៉ាស់ ហៅឌីឌីម ពោលទៅសាវ័កឯទៀតថា៖ «មក !យើងនាំគ្នាទៅរួម
ស្លាប់ជាមួយព្រះអង្គដែរ ! » ។

[១៧]កាលព្រះយេស៊ូយាងទៅដល់ ព្រះអង្គក៏ជ្រាបថា គេបានដាក់សពលោកឡាសារ ក្នុងផ្នូរបួនថ្ងៃ
ហើយ ។

[១៨]ភូមិបេថានីមានចម្ងាយប្រមាណបីគីឡូម៉ែត្រពីក្រុងយេរូសាឡឹម ។ [១៩]មានជនជាតិយូដាជាច្រើន
នាំគ្នាមកជួយរំលែកទុក្ខនាងម៉ាថា និង នាងម៉ារីក្នុងពេលប្អូនស្លាប់ ។

[២០]កាលនាងម៉ាថាបានដឹងថា ព្រះយេស៊ូយាងមកដល់ នាងក៏ចេញទៅទទួលព្រះអង្គ រីឯនាងម៉ារីវិញ
នាងអង្គុយនៅក្នុងផ្ទះ ។ [២១]នាងម៉ាថាទូលព្រះយេស៊ូថា៖ «លោកម្ចាស់! ប្រសិនបើលោកបាននៅទីនេះ
ប្អូននាងខ្ញុំមិនស្លាប់ទេ ។ [២២]ប៉ុន្តែ ឥឡូវនេះ នាងខ្ញុំដឹងថា បើលោកសុំអ្វីពីព្រះជាម្ចាស់ក៏ដោយ ព្រះអង្គ
មុខជានឹងប្រទានឲ្យមិនខាន» ។ [២៣]ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «ប្អូននាងនឹងរស់ឡើងវិញ»
។ [២៤]នាងទូលទៅព្រះអង្គវិញថា៖ «នាងខ្ញុំដឹងហើយ នៅថ្ងៃចុងក្រោយបំផុត កាលណាមនុស្សស្លាប់នឹង
រស់ឡើងវិញ ប្អូននាងខ្ញុំក៏នឹងរស់ឡើងវិញដែរ» ។ [២៥]ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «ខ្ញុំហ្នឹង
ហើយ ដែលប្រោសមនុស្សឲ្យមានជីវិតថ្មី ខ្ញុំនឹងផ្ដល់ឲ្យគេមានជីវិត ។ អ្នកណាជឿលើខ្ញុំ ទោះបីស្លាប់ទៅ
ហើយក៏ដោយ ក៏នឹងបានរស់ជាមិនខាន ។ [២៦]រីឯអស់អ្នកដែលកំពុងតែមានជីវិតនៅរស់ហើយជឿលើខ្ញុំ
មិនស្លាប់សោះឡើយ តើនាងជឿសេចក្ដីនេះឬទេ? » ។ [២៧]នាងម៉ាថាទូលព្រះអង្គថា៖ «បពិត្រព្រះ
អម្ចាស់! ខ្ញុំម្ចាស់ជឿថា ព្រះអង្គពិតជាព្រះគ្រីស្ដ ជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយពិតជាព្រះអង្គ
ដែលត្រូវយាងមកក្នុងពិភពលោកនេះមែន! » ។

[២៨]នាងម៉ាថានិយាយដូច្នេះហើយ ក៏ចេញទៅហៅនាងម៉ារីជាប្អូនដោយស្ងាត់ៗថា៖ «ព្រះគ្រូយាង
មកដល់ហើយ ព្រះអង្គហៅប្អូនឯង» ។ [២៩]នាងម៉ារីឮហើយក៏ស្ទុះក្រោកឡើងទៅគាល់ព្រះយេស៊ូជា
ប្រញាប់ ។ [៣០]ពេលនោះព្រះអង្គពុំទាន់យាងចូលក្នុងភូមិនៅឡើយទេ គឺព្រះអង្គគង់នៅកន្លែង ដែលនាង
ម៉ាថាទៅជួប ។ [៣១]ជនជាតិយូដា ដែលមកជួយរំលែកទុក្ខ ក្នុងផ្ទះជាមួយនាងម៉ារី ឃើញនាងស្ទុះក្រោក
ឡើងប្រញាប់ប្រញាល់ចេញទៅខាងក្រៅដូច្នេះ ក៏នាំគ្នាចេញទៅតាម ព្រោះគេស្មានថានាងទៅយំ

ឯផ្នូរ ។ [៣២]លុះនាងម៉ារី ទៅដល់កន្លែងព្រះយេស៊ូគង់នៅ ហើយនាងឃើញព្រះអង្គ ក៏ក្រាបទៀបព្រះ
បាទាទូលថា៖ «លោកម្ចាស់! ប្រសិនបើលោកបាននៅទីនេះ ប្អូនប្រុសនាងខ្ញុំមិនស្លាប់ទេ» ។ [៣៣]ពេល
ព្រះយេស៊ូឃើញនាងម៉ារី និងជនជាតិយូដាដែលមកជាមួយនាងយំដូច្នេះព្រះអង្គរំជួលព្រះហឫទ័យ
ហើយរន្ធត់ជាខ្លាំងផង ។

[៣៤]ព្រះអង្គមានព្រះបន្ទូលសួរថា៖ «តើអ្នករាល់គ្នាយកសពទៅទុកនៅឯណា?» ។ គេទូលព្រះអង្គ
ថា៖ «សូមអញ្ជើញមក លោកនឹងឃើញ» ។ [៣៥]ពេលនោះ ព្រះយេស៊ូទ្រង់ព្រះកន្សែង ។ [៣៦]ជនជាតិយូ
ដានាំគ្នាពោលថា៖ «មើល៍! លោកស្រឡាញ់ឡាសារខ្លាំងណាស់!» ។ [៣៧]ប៉ុន្តែ នៅក្នុងចំណោមពួកគេ
មានអ្នកខ្លះនិយាយថា៖ «លោកអាចធ្វើឲ្យមនុស្សខ្វាក់មើលឃើញ ម្ដេចក៏លោកមិនធ្វើឲ្យឡាសារគេច
ផុតពីស្លាប់ផង!» ។

[៣៨]ព្រះយេស៊ូរំជួលព្រះហឫទ័យម្ដងទៀត រួចយាងទៅផ្នូរ ។ ផ្នូរនោះជារូងភ្នំ មានថ្មបាំងនៅមាត់
រូង ។ [៣៩]ព្រះយេស៊ូមានព្រះបន្ទូលថា៖ «សុំយកថ្មនេះចេញ!» ។ នាងម៉ាថាជាបងរបស់សព ទូលព្រះ
អង្គថា៖ «បពិត្រព្រះអម្ចាស់! សពធំក្លិនហើយ! ព្រោះគេបានយកមកដាក់តាំងពីបួនថ្ងៃម្ល៉េះ!» ។
[៤០]ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «ខ្ញុំបានប្រាប់នាងរួចមកហើយថា បើនាងជឿ នាងនឹងឃើញ
សិរីរុងរឿងរបស់ព្រះជាម្ចាស់» ។ [៤១]គេក៏យកថ្មចេញពីមាត់ផ្នូរ ។ ព្រះយេស៊ូងើបព្រះភ័ក្ត្រទតទៅលើ
ហើយមានព្រះបន្ទូលថា៖ «បពិត្រព្រះបិតា! ទូលបង្គំសូមអរព្រះគុណព្រះអង្គដែលទ្រង់ព្រះសណ្ដាប់ទូល
បង្គំ ។ [៤២]ចំពោះទូលបង្គំ ទូលបង្គំដឹងថា ព្រះអង្គទ្រង់ព្រះសណ្ដាប់ទូលបង្គំជានិច្ច ប៉ុន្តែ ទូលបង្គំទូលព្រះ
អង្គដូច្នេះ ដើម្បីឲ្យបណ្ដាជន ដែលនៅជុំវិញទូលបង្គំជឿថា ព្រះអង្គពិតជាបានចាត់ទូលបង្គំឲ្យមក
មែន» ។ [៤៣]លុះព្រះអង្គមានព្រះបន្ទូលដូច្នេះហើយ ទ្រង់បន្លឺព្រះសូរសៀងខ្លាំងៗថា៖ «ឡាសារអើយ!
ចេញមក!» ។ [៤៤]ពេលនោះ លោកឡាសារដែលបានស្លាប់ ក៏ចេញពីផ្នូរមក មានទាំងក្រណាត់រុំដៃជើង
និងកន្សែងគ្របមុខផង ។ ព្រះយេស៊ូមានព្រះបន្ទូលទៅពួកគេថា៖ «សុំស្រាយក្រណាត់ចេញពីគាត់
ហើយឲ្យគាត់ទៅចុះ» ។

[៤៥]ជនជាតិយូដាជាច្រើននាក់ ដែលមកផ្ទះនាងម៉ារី បានឃើញព្រះយេស៊ូធ្វើកិច្ចការទាំងនោះ ក៏ជឿ
លើព្រះអង្គ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# សប្តាហ៍ពិសិដ្ឋ

# ថ្ងៃអាទិត្យបុណ្យហែស្លឹក ឆ្នាំ ក

# ព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹម

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **២១,១-១១**

១ព្រះយេស៊ូយាងមកជាមួយក្រុមសាវ័ក ជិតដល់ក្រុងយេរូសាឡឹមហើយ ។ កាលមកដល់ភូមិបេតផា
សេ ដែលនៅចង្កេះភ្នំដើមអូលីវ ព្រះអង្គចាត់សាវ័កពីរនាក់អោយទៅមុន ២ទាំងមានព្រះបន្ទូលថា៖
«ចូរទៅភូមិដែលនៅមុខអ្នករាល់គ្នា ។ ពេលទៅដល់ភ្លាម អ្នកនឹងឃើញមេលាមួយដែលគេចងនៅទី
នោះ ហើយមានកូនវានៅជាមួយដែរ ។ ចូរស្រាយវាដឹកមកអោយខ្ញុំ ។ ៣ប្រសិនបើមាននរណាសួរ ចូរ
ប្រាប់គេថា ព្រះអម្ចាស់ត្រូវការវា តែព្រះអង្គនឹងឲ្យគេដឹកមកវិញភ្លាមជាមិនខាន» ។ ៤ព្រឹត្តិការណ៍នេះ
កើតឡើង ស្របនឹងសេចក្ដីដែលមានចែងទុកតាមរយៈព្យាការីថា៖ ៥«ចូរប្រាប់ប្រជាជនក្រុងស៊ីយ៉ូនថា
មើលហ្ន៎! ព្រះមហាក្សត្ររបស់អ្នក យាងមករកអ្នកហើយ ។ ទ្រង់មានព្រះហឫទ័យស្លូតបូត ទ្រង់គង់លើ
ខ្នងលា ហើយគង់លើខ្នងកូនលាផងដែរ» ។

៦សាវ័កទាំងពីរនាំគ្នាចេញទៅ ហើយធ្វើតាមបញ្ជារបស់ព្រះយេស៊ូ ៧គេដឹកមេលានិងកូនវាមក ។ គេ
យកអាវក្រាលពីលើខ្នងលា និងលើខ្នងកូនលាផង ហើយព្រះយេស៊ូឡើងគង់លើខ្នងវា ។ ៨នៅពេលនោះ
មានបណ្ដាជនជាច្រើននាំគ្នាយកអាវរបស់ខ្លួនក្រាលតាមផ្លូវ ហើយអ្នកខ្លះទៀតកាច់ធាងទន្សៃយកមក
ក្រាលលើផ្លូវដែរ ។ ៩មហាជនដែលដើរហែហមព្រះយេស៊ូពីមុខពីក្រោយ នាំគ្នាស្រែកឡើងថា៖
«ជយោ! ព្រះរាជវង្សរបស់ព្រះបាទដាវីឌ! សូមព្រះជាម្ចាស់ប្រទានពរដល់ព្រះអង្គ ដែលយាងមកក្នុង
ព្រះនាមព្រះអម្ចាស់! ជយោ! ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត!» ។

១០កាលព្រះយេស៊ូយាងទៅដល់ក្រុងយេរូសាឡឹម ប្រជាជននៅក្នុងទីក្រុងទាំងមូល នាំគ្នាជ្រួលច្របល់
សួរថា៖ «តើលោកនោះជានរណា?» ។ ១១មហាជនឆ្លើយថា៖ «លោកជា ព្យាការីយេស៊ូ មកពីភូមិ
ណាសារ៉ែត ក្នុងស្រុកកាលីឡេ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យបុណ្យហែស្លឹក ឆ្នាំ ក

# ពិធីរំលឹកទុក្ខលំបាករបស់ព្រះយេស៊ូ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ**

ប- បពិត្រព្រះអម្ចាស់យេស៊ូ! យើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងតបស់ព្រះអង្គ ។

គ- ព្រោះតែយើង ព្រះគ្រីស្តដាក់ខ្លួនធ្វើតាមព្រះបញ្ជា រហូតដល់សោយទិវង្គត គឺរហូតដល់សោយទិវង្គតលើឈើឆ្កាងថែមទៀតផង ។ ហេតុនេះហើយបានជាព្រះជាម្ចាស់លើកតម្កើងព្រះអង្គឡើងយ៉ាងខ្ពង់ខ្ពស់បំផុត ព្រមទាំងប្រោសប្រទានឱ្យព្រះអង្គមានព្រះនាមដ៏ប្រសើរលើសអ្វីៗទាំងអស់ -ប

✠ **សូមថ្លែងព្រះគម្ពីរស្តីអំពីទុក្ខលំបាករបស់ព្រះយេស៊ូជាអម្ចាស់តាមសន្ត ម៉ាថាយ** **២៦,១៤-២៧,៦៦**

**ឬ យ៉ាងខ្លី មថ ២៧,១១-៥៤**

« អ » អ្នកអានដំណើររឿង

« យ » អ្នកអានព្រះបន្ទូលព្រះយេស៊ូ

« ឆ » អ្នកអានពាក្យអ្នកដទៃទៀត

អ- [១៤]សាវ័កម្នាក់ក្នុងក្រុមសាវ័កទាំងដប់ពីរ ឈ្មោះយូដាអ៊ីស្ការីយ៉ុត បានទៅជួបក្រុមនាយកបូជាចារ្យ
[១៥]ជម្រាបថា៖

ឆ- «បើខ្ញុំប្រគល់លោកយេស៊ូជូនអស់លោក តើអស់លោកអោយអ្វីខ្ញុំ? » ។

អ- ពួកនាយកបូជាចារ្យក៏រាប់ប្រាក់ឲ្យគាត់សាមសិបស្លឹង ។ [១៦]ចាប់ពីពេលនោះមក យូដាសរកឱកាសល្អ ដើម្បីនាំគេទៅចាប់ព្រះយេស៊ូ ។

អ- [១៧]នៅថ្ងៃដំបូងនៃពិធីនំបុ័ងឥតមេ ក្រុមសាវ័កនាំគ្នាមកគាល់ព្រះយេស៊ូ ហើយទូលថា៖

ឆ- «តើព្រះអង្គសព្វព្រះហឫទ័យ ឲ្យយើងខ្ញុំរៀបចំជប់លៀងក្នុងឱកាសបុណ្យចម្លងថ្វាយព្រះអង្គ នៅកន្លែងណា? » ។

អ- [១៨]ព្រះយេស៊ូមានព្រះបន្ទូលថា៖

យ- «ចូរនាំគ្នាទៅផ្ទះបុរសម្នាក់នៅទីក្រុង ប្រាប់គាត់ថា "លោកគ្រូមានប្រសាសន៍ថា ពេលកំណត់របស់ខ្ញុំជិតមកដល់ហើយ ខ្ញុំនឹងធ្វើពិធីបុណ្យចម្លងជាមួយសិស្សខ្ញុំ នៅក្នុងផ្ទះអ្នក" » ។

អ- [១៩]សាវ័កនាំគ្នាធ្វើតាមដូចព្រះយេស៊ូបង្គាប់ ហើយរៀបចំម្ហូបអាហារ សម្រាប់បុណ្យចម្លង ។ [២០]លុះ
ដល់ល្ងាច ព្រះអង្គរួមតុជាមួយសាវ័កទាំងដប់ពីររូប ។ [២១]នៅពេលបរិភោគ ព្រះអង្គមានព្រះបន្ទូល
ថា៖

យ- «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ក្នុងចំណោមអ្នករាល់គ្នា មានម្នាក់នឹងនាំគេមកចាប់ខ្ញុំ» ។

អ- [២២]ក្រុមសាវ័កព្រួយចិត្តក្រៃលែង ម្នាក់ៗទូលសួរព្រះអង្គថា៖

ឆ- «បពិត្រព្រះអម្ចាស់! តើទូលបង្គំឬ? » ។

អ- [២៣]ព្រះអង្គមានព្រះបន្ទូលទៅគេវិញថា៖

យ- «អ្នកណាជ្រលក់នំបុ័ងក្នុងចានជាមួយខ្ញុំ គឺអ្នកនោះហើយដែលនាំគេមកចាប់ខ្ញុំ ។ [២៤]បុត្រមនុស្ស
ត្រូវតែស្លាប់ ដូចមានចែងទុកក្នុងគម្ពីរអំពីលោកស្រាប់ ។ ប៉ុន្តែ អ្នកដែលនាំគេមកចាប់បុត្រមនុស្ស
ត្រូវវេទនាជាមិនខាន ។ ចំពោះអ្នកនោះ បើមិនបានកើតមកទេ ទើបប្រសើរជាង! » ។

អ- [២៥]យូដាជាអ្នកក្បត់ព្រះអង្គ ទូលសួរថា៖

ឆ- «ព្រះគ្រូ! តើខ្ញុំឬ? » ។

អ- ព្រះអង្គមានព្រះបន្ទូលទៅគាត់ថា៖

យ- «អ្នកនិយាយ ដូច្នេះ ត្រូវហើយ! » ។

* * *

អ- [២៦]នៅពេលកំពុងបរិភោគ ព្រះយេស៊ូយកនំបុ័ងមកកាន់ ព្រះអង្គសរសើរតម្កើងព្រះជាម្ចាស់ ហើយ
កាច់ប្រទានអោយក្រុមសាវ័ក ទាំងមានព្រះបន្ទូលថា៖

យ- «នេះជារូបកាយខ្ញុំ សុំយកពិសាចុះ» ។

អ- [២៧]បន្ទាប់មក ព្រះអង្គយកពែងមកកាន់ អរព្រះគុណព្រះជាម្ចាស់ រួចប្រទានឲ្យក្រុមសាវ័ក ទាំង
មានព្រះបន្ទូលថា៖

យ- «សុំយកពិសាទាំងអស់គ្នាចុះ [២៨]នេះជាលោហិតរបស់ខ្ញុំ គឺលោហិតនៃសម្ពន្ធមេត្រីដែលត្រូវបង្ហូរ
ដើម្បីលើកលែងទោសមនុស្សទាំងអស់ឲ្យរួចពីបាប ។ [២៩]ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អំណើះតទៅ ខ្ញុំ
នឹងមិនពិសាស្រាទំពាំងបាយជូរទៀតឡើយ រហូតដល់ថ្ងៃដែលខ្ញុំនឹងពិសាស្រាទំពាំងបាយជូរថ្មី ជា
មួយអ្នករាល់គ្នា នៅក្នុងព្រះរាជ្យនៃព្រះបិតាខ្ញុំ» ។

* * *

អ- [៣០]ក្រោយពីបានច្រៀងទំនុកតម្កើងរួចហើយ ព្រះយេស៊ូយាងឆ្ពោះទៅភ្នំដើមអូលីវ ជាមួយក្រុមសា
វ័ក ។ [៣១]ពេលនោះ ព្រះយេស៊ូមានព្រះបន្ទូលថា៖

យ- «យប់នេះ អ្នកទាំងអស់គ្នានឹងឃ្លាតចាកពីជំនឿព្រោះតែខ្ញុំ ដ្បិតមានចែងទុកមកថា "យើងនឹងវាយសម្លាប់គង្វាល ហើយចៀមនៅក្នុងហ្វូងនឹងត្រូវខ្ចាត់ខ្ចាយ" ។ [៣២]ប៉ុន្តែ ក្រោយពេលខ្ញុំមានជីវិតរស់ឡើងវិញ ខ្ញុំនឹងទៅស្រុកកាលីឡេមុនអ្នករាល់គ្នា» ។

អ- [៣៣]លោកសិលាទូលព្រះអង្គថា៖

ឆ- «ទោះបីអ្នកឯទៀតបោះបង់ជំនឿព្រោះតែព្រះអង្គទាំងអស់គ្នាក៏ដោយ ក៏ទូលបង្គំមិនបោះបង់ជំនឿជាដាច់ខាត!» ។

អ- [៣៤]ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖

យ- «ខ្ញុំសុំប្រាប់ឲ្យអ្នកដឹងច្បាស់ថា នៅយប់នេះឯង មុនមាន់រងាវ អ្នកនឹងបដិសេធបីដងថា មិនស្គាល់ខ្ញុំ» ។

អ- [៣៥]លោកសិលាទូលព្រះអង្គថា៖

ឆ- «ទោះបីទូលបង្គំត្រូវស្លាប់ជាមួយព្រះអង្គក៏ដោយ ក៏ទូលបង្គំមិនបដិសេធថា មិនស្គាល់ព្រះអង្គជាដាច់ខាត» ។

អ- សាវ័កឯទៀតៗ ក៏ទូលព្រះអង្គ ដូចលោកសិលាដែរ ។ [៣៦]ពេលនោះ ព្រះយេស៊ូយាងទៅជាមួយក្រុមសាវ័កដល់កន្លែងមួយ ឈ្មោះកេតសេម៉ានី ព្រះអង្គមានព្រះបន្ទូលទៅគេថា៖

យ- «អ្នករាល់គ្នាអង្គុយនៅទីនេះសិន ចាំខ្ញុំទៅអធិស្ឋាននៅត្រង់កន្លែងនោះ» ។

អ- [៣៧]ព្រះអង្គនាំលោកសិលា និងកូនរបស់លោកសេបេដេទាំងពីរនាក់ ទៅជាមួយ ។ ពេលនោះ ព្រះអង្គចាប់ផ្ដើមព្រួយព្រះហឫទ័យ ហើយចុកចាប់អន្ទះសាពន់ប្រមាណ [៣៨]ទ្រង់មានព្រះបន្ទូលទៅកាន់អ្នកទាំងបីថា៖

យ- «ខ្ញុំព្រួយចិត្តយ៉ាងខ្លាំងស្ទើរតែស្លាប់ អ្នករាល់គ្នានៅទីនេះសិន ហើយចូរប្រុងស្មារតីជាមួយខ្ញុំ» ។

អ- [៣៩]ព្រះអង្គយាងទៅមុខបន្តិច ក្រាបព្រះភក្ត្រដល់ដី ទូលអង្វរថា៖

យ- «ឱព្រះបិតានៃទូលបង្គំអើយ! ប្រសិនបើបាន សូមអោយពែងនៃទុក្ខលំបាកនេះចេញឆ្ងាយពីទូលបង្គំទៅ ប៉ុន្តែ សូមកុំឲ្យបានសម្រេចតាមបំណងទូលបង្គំឡើយ គឺសូមឲ្យបានសម្រេចតាមព្រះហឫទ័យរបស់ព្រះអង្គវិញ» ។

អ- [៤០]ព្រះអង្គយាងមករកក្រុមសាវ័ក ឃើញគេកំពុងតែដេកលក់ ព្រះអង្គមានព្រះបន្ទូលទៅលោកសិលាថា៖

យ- «អ្នករាល់គ្នាមិនស៊ូទ្រាំប្រុងស្មារតីជាមួយខ្ញុំ សូម្បីតែមួយម៉ោងក៏មិនបានដែរឬ!» ។ [៤១]ចូរប្រុងស្មារតី ហើយអធិស្ឋាន កុំឲ្យជាប់ការល្បួងឡើយ ។ វិញ្ញាណរបស់មនុស្សប្រុងប្រៀប ជាស្រេចមែន តែខ្លួនគេនៅទន់ខ្សោយទេ» ។

អ- [៤២]ព្រះអង្គយាងចេញទៅម្ដងទៀត ជាលើកទីពីរ ហើយទូលអង្វរថា៖

យ- «ឱព្រះបិតានៃទូលបង្គំអើយ! ប្រសិនបើទូលបង្គំត្រូវតែទទួលពែងនៃទុក្ខលំបាកនេះចៀសពុំបានទេនោះ សូមឲ្យបានសម្រេចតាមព្រះហឫទ័យរបស់ព្រះអង្គចុះ!» ។

អ- [៤៣]ព្រះយេស៊ូវិលត្រឡប់ទៅរកក្រុមសាវ័កម្ដងទៀត ឃើញគេដេកលក់ ដ្បិតគេងងុយពេក បើកភ្នែកពុំរួចសោះ ។ [៤៤]ព្រះអង្គក៏យាងចាកចេញពីគេ ទៅអធិស្ឋានជាលើកទីបី ហើយទូលអង្វរដោយពាក្យដដែល ។ [៤៥]បន្ទាប់មក ព្រះអង្គវិលមករកសាវ័កវិញ មានព្រះបន្ទូលទៅគេថា៖

យ- «ចូរអ្នករាល់គ្នាដេកលក់ និងសំរាកតទៅ! ពេលកំណត់ដែលបុត្រមនុស្សត្រូវគេបញ្ជូនទៅក្នុងកណ្ដាប់ដៃរបស់មនុស្សបាប មកជិតបង្កើយហើយ ។ [៤៦]ចូរក្រោកឡើង! យើងនាំគ្នាទៅ ដ្បិតអ្នកដែលនាំគេមកចាប់ខ្ញុំ មកជិតដល់ហើយ!» ។

* * *

អ- [៤៧]ព្រះយេស៊ូកំពុងតែមានព្រះបន្ទូលនៅឡើយ ស្រាប់តែយូដា ជាសាវ័កម្នាក់ក្នុងចំណោមសាវ័កទាំងដប់ពីរ មកដល់ ទាំងមានបណ្ដាជនជាច្រើនកាន់ដាវ កាន់ដំបងមកជាមួយផង ។ ពួកនាយកបូជាចារ្យ និងពួកព្រឹទ្ធាចារ្យរបស់ប្រជាជន បានចាត់អ្នកទាំងនោះឲ្យមក ។ [៤៨]យូដាដែលនាំគេមកចាប់ព្រះយេស៊ូ បានសន្មតជាមួយគេនូវសញ្ញាមួយថា៖

ឆ- «ខ្ញុំថើបអ្នកណា គឺអ្នកនោះហើយ សុំចាប់គាត់ទៅ!» ។

អ- [៤៩]កាលយូដាមកដល់ភ្លាម គាត់ដើរតម្រង់មករកព្រះយេស៊ូទូលថា៖

ឆ- «ជម្រាបសួរព្រះគ្រូ!»

អ- រួចថើបព្រះអង្គ ។ [៥០]ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖

យ- «សម្លាញ់អើយ! អ្នកមកនេះចង់ធ្វើអ្វី ធ្វើទៅចុះ!» ។

អ- ពេលនោះ បណ្ដាជនក៏នាំគ្នាចូលមកចាប់ព្រះអង្គ ។ [៥១]មានម្នាក់ក្នុងចំណោមពួកអ្នកដែលនៅជាមួយព្រះយេស៊ូ បានហូតដាវកាប់អ្នកបំរើរបស់លោកមហាបូជាចារ្យ ដាច់ស្លឹកត្រចៀក ។ [៥២]ព្រះយេស៊ូមានព្រះបន្ទូលទៅអ្នកនោះថា៖

យ- «ស៊កដាវអ្នកទៅក្នុងស្រោមវិញទៅ ដ្បិតអស់អ្នកដែលប្រើដាវ នឹងត្រូវស្លាប់ដោយមុខដាវជាមិនខាន ។ [៥៣]អ្នកស្មានថា ខ្ញុំមិនអាចអង្វរព្រះបិតាខ្ញុំឲ្យចាត់ទេវទូតជាងដប់ពីរកងពល មកជួយខ្ញុំបាន

ភ្លាមៗទេឬ? ។ [៥៤]តែបើធ្វើដូច្នោះ ធ្វើម្ដេចនឹងបានស្របតាមសេចក្ដីដែលមានចែងទុកក្នុងគម្ពីរ
អំពីហេតុការណ៍ដែលត្រូវតែកើតឡើងយ៉ាងនេះ! » ។
អ- [៥៥]ពេលនោះ ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់មហាជនថា៖
យ- «ខ្ញុំជាចោរព្រៃឬ បានជាអស់លោកកាន់ដាវកាន់ដំបងមកចាប់ខ្ញុំដូច្នេះ? ខ្ញុំតែងអង្គុយបង្រៀននៅ
ក្នុងព្រះវិហារជារៀងរាល់ថ្ងៃ តែអស់លោកពុំបានចាប់ខ្ញុំទេ ។ [៥៦]ហេតុការណ៍ទាំងនេះកើតឡើង
ដើម្បីឲ្យបានស្របតាមសេចក្ដីដែលមានចែងទុកក្នុងគម្ពីរព្យាការី» ។
អ- ពេលនោះ ពួកសាវ័កនាំគ្នាបោះបង់ចោលព្រះអង្គ ហើយរត់បាត់អស់ទៅ ។

* * *

[៥៧] លុះចាប់ព្រះយេស៊ូបានហើយ គេបណ្ដើរព្រះអង្គទៅដល់ដំណាក់របស់លោកកៃផាស ជាមហាបូជាចា
រ្យ* ។ ពួកធម្មាចារ្យ* និងពួកព្រឹទ្ធាចារ្យ* ជួបជុំគ្នានៅទីនោះ ។ [៥៨] លោកសិលាដើរតាមព្រះអង្គ
ពីចម្ងាយ គាត់តាមរហូតដល់ទីធ្លាខាងក្នុងដំណាក់របស់មហាបូជាចារ្យ ហើយអង្គុយជាមួយកង
រក្សាព្រះវិហារ ចង់ដឹងថាហេតុការណ៍នឹងទៅជាយ៉ាងណា ។
[៥៩] ពួកនាយកបូជាចារ្យ និងក្រុមប្រឹក្សាជាន់ខ្ពស់*ទាំងមូល នាំគ្នារកពាក្យចោទប្រកាន់ មួលបង្កាច់ព្រះ
យេស៊ូ ដើម្បីកាត់ទោសប្រហារជីវិតព្រះអង្គ [៦០] ទោះបីមានមនុស្សជាច្រើនធ្វើសាក្សីក្លែងក្លាយក៏
ដោយ ក៏គេរកមិនបានដែរ ។ នៅទីបំផុត មានបុរសពីរនាក់នាំគ្នាចូលមក [៦១] ពោលថា៖ «អ្នក
នេះបានអះអាងថា "ខ្ញុំអាចរុះព្រះវិហាររបស់ព្រះជាម្ចាស់ចោល ហើយសង់ឡើងវិញបានក្នុងរវាង
បីថ្ងៃ" » ។ [៦២] ពេលនោះ លោកមហាបូជាចារ្យក្រោកឈរឡើង សួរព្រះអង្គថា៖ «ម្ដេចក៏អ្នកមិន
ឆ្លើយនឹងពាក្យចោទប្រកាន់របស់អ្នកទាំងនេះ ? » ។ [៦៣] ព្រះយេស៊ូនៅស្ងៀម ។ លោកមហាបូជា
ចារ្យសួរព្រះអង្គទៀតថា៖ «ចូរស្បថដោយយកព្រះដ៏មានព្រះជន្មគង់នៅធ្វើជាប្រធាន តើអ្នក
ពិតជាព្រះគ្រីស្ដ* ជាព្រះបុត្រារបស់ព្រះជាម្ចាស់មែនឬ ? » ។ [៦៤] ព្រះយេស៊ូមានព្រះបន្ទូលទៅ
លោកថា៖ «ត្រូវដូចលោកមានប្រសាសន៍មែន ប៉ុន្តែ ខ្ញុំសុំបញ្ជាក់ប្រាប់អស់លោកថា អំណើះតទៅ
អស់លោកនឹងឃើញបុត្រមនុស្ស*គង់នៅខាងស្ដាំព្រះដ៏មានឫទ្ធានុភាព ហើយនឹងយាងមកលើ
ពពក*ក្នុងផ្ទៃមេឃ» ។ [៦៥] ពេលនោះ លោកមហាបូជាចារ្យហែកអាវរបស់លោក ហើយមាន
ប្រសាសន៍ថា៖ «ជននេះបានពោលពាក្យប្រមាថព្រះជាម្ចាស់ហើយ ! យើងមិនបាច់រកសាក្សីឯ
ណាទៀតទេ អស់លោកឮអ្នកនេះពោលពាក្យប្រមាថព្រះជាម្ចាស់អំបាញ់មិញស្រាប់ ! [៦៦] តើអស់
លោកមានយល់យ៉ាងណា? » ។ ពួកគេឆ្លើយឡើងថា៖ «អ្នកនេះត្រូវមានទោសដល់ជីវិត ! » ។

៦៧ គេក៏នាំគ្នាស្តោះទឹកមាត់ដាក់ព្រះភក្ត្រព្រះអង្គ គេវាយតប់ព្រះអង្គ ហើយអ្នកខ្លះទះកំផ្លៀងព្រះ
អង្គ ៦៨ ទាំងពោលថា៖ «ទាយមើល៍ ព្រះគ្រីស្តអើយ អ្នកណាវាយឯង ! » ។
៦៩ ពេលនោះ លោកសិលាអង្គុយនៅខាងក្រៅក្នុងទីធ្លា ។ មានស្ត្រីបំរើរបស់មហាបូជាចារ្យ*ម្នាក់ចូលមក
ជិតគាត់ ពោលថា៖ «អ្នកឯងជាបក្សពួករបស់យេស៊ូ ជាអ្នកស្រុកកាលីឡេដែរ ! » ។ ៧០ ប៉ុន្តែ
គាត់ប្រកែកថា៖ «ខ្ញុំមិនដឹងថា នាងចង់និយាយអំពីរឿងអ្វីឡើយ ! » ។ ៧១ ពេលលោកសិលា
ដើរចេញពីទីនោះ ឆ្ពោះទៅរកខ្លោងទ្វារ មានស្ត្រីបំរើម្នាក់ទៀតឃើញគាត់ហើយពោលថា៖ «
អ្នកនេះជាបក្សពួករបស់យេស៊ូជាអ្នកភូមិណាសារ៉ែតដែរ ! » ។ ៧២ លោកសិលាក៏ប្រកែកសាជាថ្មី
ទាំងស្បថថា៖ «ខ្ញុំមិនស្គាល់អ្នកនោះទេ ! » ។ ៧៣ បន្តិចក្រោយមក អស់អ្នកដែលនៅទីនោះ នាំ
គ្នាចូលទៅជិតលោកសិលាហើយពោលថា៖ «អ្នកឯងពិតជាបក្សពួករបស់អ្នកទាំងនោះ ព្រោះ
សំដីអ្នកឯងបញ្ជាក់ច្បាស់ថា អ្នកឯងមកពីស្រុកកាលីឡេមែន!» ។ ៧៤ លោកសិលាក៏ពោលឡើង
ថា៖ «បើខ្ញុំកុហក សូមព្រះជាម្ចាស់ដាក់ទោសខ្ញុំចុះ ! ។ ខ្ញុំសុំស្បថថា ខ្ញុំមិនដែលស្គាល់អ្នកនោះ
ទាល់តែសោះ ! » ។ រំពេចនោះ ស្រាប់តែមាន់រងាវឡើង ៧៥ លោកសិលាក៏នឹកឃើញ ព្រះបន្ទូល
របស់ព្រះយេស៊ូដែលថា៖ «មុនមាន់រងាវ អ្នកនឹងបដិសេធបីដងថា មិនស្គាល់ខ្ញុំ» ។ លោកសិលា
ចាកចេញពីទីនោះ ហើយយំសោកយ៉ាងខ្លោចផ្សា ។
១ លុះព្រឹកឡើង ពួកនាយកបូជាចារ្យ និងព្រឹទ្ធាចារ្យ*ទាំងអស់របស់ប្រជាជនប្រជុំគ្នា ហើយសំរេចចិត្ត
ធ្វើគុតព្រះយេស៊ូ ។ ២ គេក៏ចងព្រះអង្គ បញ្ជូនទៅលោកពីឡាតជាទេសាភិបាល ។
៣ កាលយូដា ជាអ្នកដែលនាំគេមកចាប់ព្រះយេស៊ូ ឃើញគេកាត់ទោសព្រះអង្គដូច្នេះ គាត់សោកស្តាយ
ជាខ្លាំង ក៏យកប្រាក់សាមសិបស្លឹងទៅប្រគល់អោយពួកនាយកបូជាចារ្យ* និងពួកព្រឹទ្ធាចារ្យ*វិញ
៤ ទាំងពោលថា៖ «ខ្ញុំបានប្រព្រឹត្តអំពើបាប ព្រោះខ្ញុំបានបញ្ជូនមនុស្សឥតទោសទៅអោយគេបង្ហូរ
ឈាម» ។ ពួកគេឆ្លើយថា៖ «រឿងនេះគ្មានទាក់ទងអ្វីនឹងយើងទេ ជារឿងរបស់អ្នកទេតើ ! » ។
៥ យូដាបាចប្រាក់នោះនៅក្នុងព្រះវិហារ* ហើយចេញទៅចងកសម្លាប់ខ្លួន ។
៦ ពួកនាយកបូជាចារ្យរើសប្រាក់នោះ ទាំងពោលថា៖ «យើងគ្មានច្បាប់នឹងបញ្ចូលប្រាក់នេះទៅក្នុងហិប
តង្វាយឡើយ ព្រោះជាប្រាក់បង់ថ្លៃឈាម» ។ ៧ ក្រោយពីបានពិភាក្សាគ្នាហើយ គេក៏យកប្រាក់
នោះទៅទិញដីចំការរបស់ជាងស្មូន ទុកធ្វើជាកន្លែងបញ្ចុះសពជនបរទេស ។ ៨ ហេតុនេះហើយបាន
ជាគេហៅចំការនោះថា «ចំការឈាម» រហូតមកទល់សព្វថ្ងៃ ។ ៩ ហេតុការណ៍នេះកើតឡើង
ស្របនឹងសេចក្តីដែលមានចែងទុក តាមរយៈ*ព្យាការី*យេរេមីថា៖ «គេបានយកប្រាក់សាមសិប*

*ស្លឹង ជាប្រាក់ដែលជនជាតិអ៊ីស្រាអែលសន្មតថាជាថ្លៃទិញលោកនោះ ១០ ហើយគេបានយកប្រាក់
នោះទៅទិញចំការរបស់ជាងស្មូន ដូចព្រះអម្ចាស់បង្គាប់មកខ្ញុំ» ។*
១១ ព្រះយេស៊ូឈរនៅចំពោះមុខលោកទេសាភិបាលលោកសួរព្រះអង្គថា៖ «តើអ្នកជាស្ដេចយូដាមែនឬ
? » ។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ «លោកទេតើដែលមានប្រសាសន៍ដូច្នេះ» ។
១២ ពួកនាយកបូជាចារ្យ* និងពួកព្រឹទ្ធាចារ្យ*នាំគ្នាចោទប្រកាន់ព្រះអង្គ តែព្រះអង្គពុំឆ្លើយអ្វីទាល់តែ
សោះ ។ ១៣ លោកពីឡាតសួរព្រះអង្គថា៖ «អ្នកមិនឮសេចក្ដីទាំងប៉ុន្មាន ដែលគេចោទប្រកាន់អ្នក
ទេឬ ? » ។ ១៤ ព្រះយេស៊ូពុំបានឆ្លើយតបមួយម៉ាត់សោះឡើយ ជាហេតុនាំអោយលោកទេសាភិ
បាលងឿងឆ្ងល់ជាខ្លាំង ។
១៥ ជារៀងរាល់ឆ្នាំ ក្នុងឱកាសបុណ្យចម្លង* លោកទេសាភិបាលតែងតែលែងអ្នកទោសម្នាក់ តាមសំណូម
ពររបស់បណ្ដាជន ។ ១៦ នៅពេលនោះ មានអ្នកទោសដ៏ល្បីម្នាក់ ឈ្មោះយេស៊ូបារ៉ាបាស ។ ១៧ កាល
បណ្ដាជនមកជុំគ្នាហើយ លោកពីឡាតសួរគេថា៖ «តើអ្នករាល់គ្នាចង់អោយខ្ញុំដោះលែងអ្នកណា
ដោះលែងយេស៊ូបារ៉ាបាស ឬយេស៊ូហៅព្រះគ្រីស្ដ ? » ។ ១៨ លោកពីឡាតមានប្រសាសន៍ដូច្នេះ
មកពីលោកជ្រាបថា ពួកគេបញ្ជូនព្រះយេស៊ូមកលោក ព្រោះគេមានចិត្តច្រណែន ។
១៩ នៅពេល ដែលលោកពីឡា អង្គុយនៅលើវេទិកាកាត់ក្ដី ភរិយារបស់លោកបានចាត់គេអោយមកជំ
រាបថា៖ «កុំឡូកឡំនឹងរឿងមនុស្សឥតទោសនេះធ្វើអ្វី ។ យប់មិញ ព្រោះតែរឿងបុរសនេះ ខ្ញុំ
យល់សប្ដិអាក្រក់ណាស់» ។
២០ ពួកនាយកបូជាចារ្យ* និងពួកព្រឹទ្ធាចារ្យ*នាំគ្នាញុះញង់បណ្ដាជន អោយសុំដោះលែងបារ៉ាបាស និង
សុំប្រហារជីវិតព្រះយេស៊ូ ។ ២១ លោកទេសាភិបាលមានប្រសាសន៍ទៅគេថា៖ «ក្នុងចំណោមអ្នក
ទាំងពីរនេះ តើអ្នករាល់គ្នាចង់អោយខ្ញុំដោះលែងអ្នកណា ? » ។ ពួកគេឆ្លើយថា៖ «បារ៉ាបាស !
» ។ ២២ លោកពីឡាតសួរទៅគេថា៖ «បើដូច្នេះ តើអ្នករាល់គ្នាចង់អោយខ្ញុំធ្វើអ្វីដល់ឈ្មោះ
យេស៊ូ ហៅព្រះគ្រីស្ដនេះ? » ។ គេស្រែកឡើងទាំងអស់គ្នាថា៖ «យកទៅឆ្កាងទៅ ! » ។
២៣ លោកមានប្រសាសន៍ថា៖ «តើអ្នកនេះបានប្រព្រឹត្តអំពើអាក្រក់អ្វី ? » គេនាំគ្នាស្រែកកាន់តែ
ខ្លាំងឡើងថា៖ «យកទៅឆ្កាងទៅ ! » ។ ២៤ ដោយលោកពីឡាតឃើញថា និយាយទៅឥតបាន
ការ ហើយផ្ទុយទៅវិញ ឃើញគេកើតចលាចលកាន់តែខ្លាំងឡើងៗដូច្នេះ លោកក៏យកទឹកមក
លាងដៃនៅមុខបណ្ដាជន ទាំងពោលថា៖ «នេះជាបញ្ហារបស់អ្នករាល់គ្នាទេ ខ្ញុំឥតទទួលខុសត្រូវ
ក្នុងការបង្ហូរឈាមបុរសនេះឡើយ» ។ ២៥ ប្រជាជនឆ្លើយឡើងទាំងអស់គ្នាថា៖ «យើងខ្ញុំ និងកូន

ចោរបស់យើងខ្ញុំ ទទួលខុសត្រូវក្នុងការប្រហារជីវិតជននេះ ! » ។ ២៦ លោកពីឡាតក៏ដោះលែង
បារ៉ាបាស រីឯព្រះយេស៊ូវិញ លោកអោយគេវាយនឹងរំពាត់ រួចបញ្ជូនព្រះអង្គទៅអោយគេឆ្កាង ។
២៧ ពួកទាហានរបស់លោកទេសាភិបាលនាំព្រះយេស៊ូទៅក្នុងទីធ្លាបន្ទាយ ហើយប្រមូលគ្នីគ្នាក្នុងកងនោះ
មកចោមរោមព្រះអង្គ ។ ២៨ គេដោះព្រះពស្ត្ររបស់ព្រះអង្គចេញ ហើយយកអាវធំ ដែលមាន
ពណ៌ក្រហមទុំ មកបំពាក់ថ្វាយព្រះអង្គ ។ ២៩ គេយកបន្លាមកក្រង ធ្វើជាភួងបំពាក់លើព្រះសិរសា
ព្រះអង្គ និងយកដើមត្រែងមកដាក់ក្នុងព្រះហស្តស្តាំអោយព្រះអង្គកាន់ រួចគេនាំគ្នាលុតជង្គង់នៅ
មុខព្រះអង្គ ទាំងពោលចំអកថា៖ «សូមគោរពថ្វាយបង្គំស្តេចយូដា ! » ។ ៣០ គេស្តោះទឹកមាត់
ដាក់ព្រះអង្គ និងយកដើមត្រែងនោះវាយព្រះសិរសាព្រះអង្គទៀតផង ។ ៣១ ក្រោយពីបានប្រមាថ
មើលងាយព្រះអង្គរួចហើយ ពួកគេដោះអាវធំចេញ យកព្រះពស្ត្ររបស់ព្រះអង្គមកបំពាក់ថ្វាយ
ព្រះអង្គវិញ រួចបណ្តើរនាំយកទៅឆ្កាង ។
៣២ ពេលចេញពីទីក្រុងទៅ គេជួបបុរសម្នាក់ឈ្មោះស៊ីម៉ូន ជាអ្នកស្រុកគីរេន គេបង្ខំគាត់អោយលីឈើ
ឆ្កាងរបស់ព្រះយេស៊ូ ។ ៣៣ លុះមកដល់កន្លែងមួយឈ្មោះ «កុលកូថា» ដែលប្រែថា «ភ្នំលលាដ៍
ក្បាល» ៣៤ គេយកស្រាទំពាំងបាយជូរលាយជាមួយប្រមាត់ មកថ្វាយព្រះអង្គសោយ ។ ព្រះយេស៊ូ
ក្រេបបន្តិច ព្រះអង្គពុំព្រមសោយទេ ។
៣៥ ក្រោយពីឆ្កាងព្រះអង្គរួចហើយ ពួកទាហានយកសម្លៀកបំពាក់របស់ព្រះអង្គមកចាប់ឆ្នោតចែកគ្នា
៣៦ រួចអង្គុយយាមព្រះអង្គនៅទីនោះ ។ ៣៧ គេបានសរសេរប្រកាសអំពីហេតុ ដែលគេធ្វើទោសព្រះ
អង្គថា «អ្នកនេះឈ្មោះយេស៊ូ ជាស្តេចជនជាតិយូដា» ហើយគេបោះប្រកាសនោះ នៅពីខាងលើ
ព្រះសិរសាព្រះអង្គ ។ ៣៨ ពេលនោះ គេបានឆ្កាងចោរព្រៃពីរនាក់ជាមួយព្រះយេស៊ូដែរ ម្នាក់នៅ
ខាងស្តាំ ម្នាក់ទៀតនៅខាងឆ្វេង ។
៣៩ មនុស្សម្នាដើរកាត់តាមនោះ ប្រមាថមើលងាយព្រះអង្គ គ្រវីក្បាលដាក់ព្រះអង្គ ៤០ ទាំងពោលថា៖
«អ្នករុះព្រះវិហារ* ហើយសង់ឡើងវិញតែបីថ្ងៃអើយ ! ចូរសង្គ្រោះខ្លួនឯងទៅ! បើអ្នកពិតជាព្រះ
បុត្រារបស់ព្រះជាម្ចាស់មែន អញ្ជើញចុះពីឈើឆ្កាងមក!» ។ ៤១ រីឯពួកនាយកបូជាចារ្យ ពួកធម្មា
ចារ្យ* និងពួកព្រឹទ្ធាចារ្យ*ក៏នាំគ្នាចំអកដាក់ព្រះអង្គដូចគេដែរ ដោយពោលថា៖ ៤២ «គាត់បានស
ង្គ្រោះអ្នកឯទៀតៗ តែមិនអាចសង្គ្រោះខ្លួនឯងបានទេ ! គាត់ជាស្តេចអ៊ីស្រាអែល អោយគាត់ចុះ
ពីឈើឆ្កាងឥឡូវនេះមក ដើម្បីយើងជឿផង ! ៤៣ គាត់បានទុកចិត្តលើព្រះជាម្ចាស់ បើព្រះជាម្ចាស់
គាប់ព្រះហឫទ័យនឹងគាត់មែន សូមអោយព្រះអង្គដោះលែងគាត់ឥឡូវនេះទៅ ! ដ្បិតគាត់ពោល

ថា "ខ្ញុំជាព្រះបុត្រារបស់ព្រះជាម្ចាស់" » ។ ៤៤ សូម្បីតែចោរព្រៃដែលជាប់ឆ្កាងជាមួយព្រះយេស៊ូក៏
ជេរប្រមាថព្រះអង្គដូច្នោះដែរ ។
៤៥ ផែនដីទាំងមូលងងឹតសូន្យ ចាប់ពីពេលថ្ងៃត្រង់រហូតដល់ម៉ោងបីរសៀល ។ ៤៦ ប្រមាណជាម៉ោងបី
រសៀល ព្រះយេស៊ូស្រែកអង្វរខ្លាំងៗថា៖ «អេលី អេលី ឡេម៉ាសាបាច់ថានី ! » ដែលមានន័យ
ថា «ឱព្រះនៃទូលបង្គំ ព្រះនៃទូលបង្គំអើយ ហេតុអ្វីបានជាព្រះអង្គបោះបង់ទូលបង្គំចោលដូច្នេះ ?
» ។ ៤៧ អ្នកខ្លះឈរនៅទីនោះបានឮព្រះបន្ទូលរបស់ព្រះអង្គ ក៏ពោលថា៖ «គាត់ហៅលោកអេលី
! » ។ ៤៨ រំពេចនោះ មានគ្នាគេម្នាក់រត់ទៅយកសារាយស្ងួត ជ្រលក់នឹងទឹកខ្មេះ រុំជាប់នៅចុង
ត្រែងមួយដើម ហុចថ្វាយព្រះអង្គសោយ ។ ៤៩ ប៉ុន្តែ អ្នកឯទៀតៗពោលថា៖ «ចាំមើលមើល៍ !
តើលោកអេលីមកសង្គ្រោះគាត់ឬទេ ? » ។
៥០ ព្រះយេស៊ូស្រែកយ៉ាងខ្លាំងម្ដងទៀត រួចផុតវិញ្ញាណទៅ ។ ៥១ ពេលនោះ វាំងនននៅក្នុងព្រះវិហារ*
រហែកជាពីរ តាំងពីលើចុះដល់ក្រោម ផែនដីក៏រញ្ជួយផ្ទាំងថ្មក៏ប្រេះចេញពីគ្នា ៥២ ផ្នូរក៏របើកចំហ
ឡើង ហើយសាកសពប្រជាជនដ៏វិសុទ្ធ*ជាច្រើនបានរស់ឡើងវិញ ៥៣ និងនាំគ្នាចេញពីផ្នូរ ។
ក្រោយពេលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ គេបានចូលទៅក្នុងក្រុងដ៏វិសុទ្ធ ព្រមទាំងបង្ហាញ
ខ្លួនអោយមនុស្សជាច្រើនបានឃើញផង ។
៥៤ កាលនាយទាហានរ៉ូម៉ាំង និងពួកទាហាន ដែលនៅយាមព្រះយេស៊ូ បានឃើញផែនដីរញ្ជួយ និងបាន
ឃើញហេតុការណ៍ទាំងឡាយកើតឡើងដូច្នេះ គេកោតស្ញប់ស្ញែងជាខ្លាំង ហើយពោលថា៖ «
លោកនេះ ពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន ! » ។
៥៥ នៅទីនោះ មានស្ត្រីជាច្រើនមើលពីចម្ងាយ គឺស្ត្រីៗ ដែលតាមបំរើព្រះយេស៊ូ តាំងពីស្រុកកាលីឡេម
ក ។ ៥៦ ក្នុងចំណោមស្ត្រីៗ ទាំងនោះ មាននាងម៉ារី ជាអ្នកស្រុកម៉ាដាឡា នាងម៉ារី ជាម្ដាយរបស់
យ៉ាកុប និងយ៉ូសែប ព្រមទាំងភរិយារបស់លោកសេបេដេជាដើម ។
៥៧ លុះដល់ល្ងាច មានសេដ្ឋីម្នាក់ ឈ្មោះយ៉ូសែប ជាអ្នកក្រុងអារីម៉ាថេ មកដល់ គាត់ក៏ជាសាវ័ករបស់
ព្រះយេស៊ូដែរ ។ ៥៨ គាត់បានអញ្ជើញទៅជួបលោកពីឡាតសុំយកព្រះសពព្រះយេស៊ូ ។ លោកពី
ឡាតក៏បញ្ជាអោយគេប្រគល់ព្រះសពមកគាត់ ។ ៥៩ លោកយ៉ូសែបយកព្រះសពមករុំនឹងក្រណាត់
ជាឱបថ្មី ៦០ រួចដាក់ក្នុងផ្នូរ ថ្មីរបស់គាត់ ជារូងថ្មដែលគេដាប់ធ្វើផ្នូរ ។ បន្ទាប់មក គាត់ប្រមៀលថ្ម
មួយដុំធំបិទមាត់ផ្នូរ ហើយចាកចេញទៅ ។ ៦១ នាងម៉ារីជាអ្នកស្រុកម៉ាដាឡា និងនាងម៉ារីម្នាក់
ទៀត ក៏នៅទីនោះដែរ នាងអង្គុយនៅមុខផ្នូរ ។

៦២ នៅថ្ងៃបន្ទាប់ ជាថ្ងៃរៀបចំថ្ងៃឈប់សំរាក* ពួកនាយកបូជាចារ្យ* និងពួកខាងគណៈផារីស៊ី* នាំគ្នា
ទៅជួបលោកពីឡាត ៦៣ ជំរាបថា៖ «លោកម្ចាស់ ! យើងខ្ញុំនៅចាំពាក្យរបស់ជនបោកប្រាស់នោះ
កាលពីគាត់នៅរស់ថា: "បីថ្ងៃក្រោយខ្ញុំស្លាប់ ខ្ញុំនឹងមានជីវិតរស់ឡើងវិញ" ។ ៦៤ ហេតុនេះ សូម
លោកបញ្ជាអោយគេយាមផ្នូរនោះ រហូតដល់ថ្ងៃទីបីទៅ ក្រែងលោសិស្សរបស់គាត់មកលួចយក
សព ហើយប្រាប់ប្រជាជនថាគាត់រស់ឡើងវិញ ។ ការបោកប្រាស់លើកនេះ មុខជាអាក្រក់ជាងមុន
ទៅទៀត» ។ ៦៥ លោកពីឡាតមានប្រសាសន៍ ទៅគេថា៖ «អស់លោកមានទាហានស្រាប់ហើយ
សុំអញ្ជើញទៅចាត់ចែងអោយគេយាមផ្នូរ តាមអស់លោកយល់ឃើញទៅចុះ ! » ។ ៦៦ ពួកគេក៏
នាំគ្នាចេញទៅចាត់ចែងអោយយាមផ្នូរ គឺភ្ជិតផ្នូរ បោះត្រាពីលើ និងដាក់ទាហានអោយនៅយាមផ
ង ។

[— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។]

# ថ្ងៃព្រហស្បតិ៍ពិសិដ្ឋ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម យហ ១៣,៣៤**

ប- បពិត្រព្រះអម្ចាស់យេស៊ូ! យើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងតបស់ព្រះអង្គ ។

គ- ព្រះអង្គប្រទានវិន័យថ្មីឱ្យយើងខ្ញុំ “គឺត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ” ។ -ប

**✠ សូមថ្លែងព្រះគម្ពីរស្ដីអំពីទុក្ខលំបាករបស់ព្រះយេស៊ូជាអម្ចាស់តាមសន្ត យ៉ូហាន** **១៣,១-១៥**

១នៅមុនថ្ងៃបុណ្យចម្លង ព្រះយេស៊ូជ្រាបថា ដល់ពេលកំណត់ ដែលព្រះអង្គត្រូវឆ្លងពីលោកនេះ ឆ្ពោះ
ទៅព្រះបិតាហើយ ។ ដោយព្រះអង្គស្រឡាញ់សាវ័ករបស់ព្រះអង្គ ដែលរស់នៅក្នុងលោកនេះ ទ្រង់ក៏
ស្រឡាញ់គេរហូតដល់ទីបំផុត ។

២ពេលនោះ ព្រះយេស៊ូ និងក្រុមសាវ័កកំពុងបរិភោគអាហារ មារសាតាំងបានធ្វើឲ្យយូដាអ៊ីស្ការីយ៉ុត
ជាកូនលោកស៊ីម៉ូន មានគំនិតនាំគេមកចាប់ព្រះអង្គ ។ ៣ព្រះយេស៊ូជ្រាបថា ព្រះបិតាបានប្រគល់អ្វីៗទាំង
អស់មកក្រោមអំណាចព្រះអង្គ ហើយជ្រាបថា ព្រះអង្គយាងមកពីព្រះជាម្ចាស់ និងយាងទៅឯព្រះជា
ម្ចាស់វិញ ។ ៤ព្រះអង្គក្រោកឡើង ដោះព្រះពស្ត្រចេញ យកក្រមាមកក្រវាត់ចង្កេះ ។ ៥បន្ទាប់មក ព្រះ
អង្គចាក់ទឹកក្នុងជើងមួយ រួចចាប់ផ្ដើមលាងជើងក្រុមសាវ័ក ព្រមទាំងយកក្រមាពីចង្កេះមកជូតផង ។ ៦
ពេលព្រះអង្គហៀបនឹងលាង ជើងឲ្យលោកស៊ីម៉ូនសិលា លោកទូលព្រះអង្គថា៖ «ព្រះអម្ចាស់អើយ មិន
សមនឹងព្រះអង្គលាងជើងឲ្យទូលបង្គំសោះ!» ។ ៧ព្រះយេស៊ូមានព្រះបន្ទូល ទៅគាត់ថា៖ «ពេលនេះ
អ្នកមិនទាន់ដឹងថា ខ្ញុំកំពុងធ្វើអ្វីឡើយ ថ្ងៃក្រោយអ្នកមុខតែយល់ជាមិនខាន» ។ ៨លោកសិលាទូលព្រះ
អង្គថា៖ «ទេ! ព្រះអង្គមិនត្រូវលាងជើងទូលបង្គំជាដាច់ខាត!» ។ ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់
ថា៖ «ប្រសិនបើខ្ញុំមិនលាងជើងអ្នកទេ នោះអ្នកមិនអាចរួមជាមួយខ្ញុំតទៅទៀតបានឡើយ» ។ ៩លោក
ស៊ីម៉ូនក៏ទូលព្រះអង្គថា៖ «ព្រះអម្ចាស់អើយ! បើដូច្នេះ សូមកុំលាងតែជើងប៉ុណ្ណោះ សូមលាងទាំងដៃ
ទាំងក្បាលផង» ។ ១០ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «អ្នក ដែលបានងូតទឹករួច មិនបាច់លាងខ្លួនទេ
គឺលាងតែជើង ដ្បិតខ្លួនគេស្អាតបរិសុទ្ធទាំងមូលហើយ ។ អ្នករាល់គ្នាបានស្អាតបរិសុទ្ធ តែមិនមែនគ្រប់
គ្នាទេ» ។ ១១ព្រះអង្គមានព្រះបន្ទូលថា “អ្នករាល់គ្នាមិនមែនបរិសុទ្ធគ្រប់គ្នា”ដូច្នេះ មកពីព្រះអង្គជ្រាប
អំពីអ្នក ដែលហៀបនឹងនាំគេមកចាប់ព្រះអង្គ ។

១២កាលព្រះយេស៊ូលាងជើងឲ្យគេរួចហើយ ព្រះអង្គស្លៀកពាក់ឡើងវិញ យាងមកតុទាំងមានព្រះ
បន្ទូលសួរទៅគេថា៖ «តើអ្នករាល់គ្នាយល់អំពីកិច្ចការដែលខ្ញុំបានធ្វើ ចំពោះអ្នករាល់គ្នានេះឬទេ?
១៣អ្នករាល់គ្នាហៅខ្ញុំថា ព្រះគ្រូ និងព្រះអម្ចាស់ នោះត្រូវមែន គឺខ្ញុំហ្នឹងហើយ! ។ ១៤បើខ្ញុំជា ព្រះអម្ចាស់
និងជាព្រះគ្រូបានលាងជើងឲ្យអ្នករាល់គ្នាទៅហើយ អ្នករាល់គ្នាក៏ត្រូវតែលាងជើងឲ្យគ្នាទៅវិញទៅមក
ដែរ ។ ១៥ខ្ញុំបានធ្វើជាគំរូឲ្យអ្នករាល់គ្នាប្រព្រឹត្ត ដូចខ្ញុំបានប្រព្រឹត្តដល់អ្នករាល់គ្នា» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃសុក្រពិសិដ្ឋ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ**

ព្រះអង្គបានដាក់ខ្លួន ធ្វើតាមព្រះបញ្ជា រហូតដល់សោយទិវង្គត
គឺរហូតដល់សោយទិវង្គតលើឈើឆ្កាងថែមទៀតផង ។
ហេតុនេះហើយ បានជាព្រះជាម្ចាស់លើកតម្កើងព្រះអង្គឡើងយ៉ាងខ្ពង់ខ្ពស់បំផុត
ព្រមទាំងប្រោសប្រទានឲ្យព្រះអង្គមានព្រះនាមប្រសើរលើស អ្វីៗទាំងអស់ ។

✠ **សូមថ្លែងព្រះគម្ពីរស្តីអំពីទុក្ខលំបាករបស់ព្រះយេស៊ូជាអម្ចាស់តាមសន្ត យ៉ូហាន** **១៨,១-១៩,៤២**

« អ » អ្នកអានដំណើររឿង
« យ » អ្នកអានព្រះបន្ទូលព្រះយេស៊ូ
« ឆ » អ្នកអានពាក្យអ្នកដទៃទៀត

អ- បន្ទាប់ពីជប់លៀងរួចហើយ ១៨[១]ព្រះយេស៊ូយាងទៅខាងនាយជ្រោះកេដ្រូនជាមួយក្រុមសាវ័ក ។
នៅទីនោះ មានសួនឧទ្យានមួយ ព្រះអង្គយាងចូលទៅក្នុងសួនឧទ្យាននោះជាមួយក្រុមសាវ័ក ។ [២]រី
ឯយូដាជាអ្នកក្បត់ ព្រះអង្គក៏ស្គាល់កន្លែងនោះដែរ ព្រោះជាកន្លែង ដែលព្រះយេស៊ូ និងក្រុមសាវ័
កធ្លាប់ជួបជុំគ្នាជាញឹកញាប់ ។ [៣]ដូច្នេះ យូដានាំកងទាហាន និងកងរក្សាព្រះវិហារចូលមក ទាំង
កាន់ចន្លុះ កាន់គោម កាន់អាវុធផង ។ ពួកនាយកបូជាចារ្យ និងពួកខាងគណៈផារីស៊ី បានចាត់អ្នក
ទាំងនោះឲ្យមក ។ [៤]ព្រះយេស៊ូឈ្វេងយល់ហេតុការណ៍ទាំងប៉ុន្មាន ដែលត្រូវកើតដល់ព្រះអង្គ ព្រះ
អង្គក៏យាងទៅមុខ ហើយមានព្រះបន្ទូលសួរគេថា៖

យ- «អ្នករាល់គ្នាមករកនរណា ? » ។

អ- [៥]គេទូលព្រះអង្គថា៖

ឆ- «រកឈ្មោះយេស៊ូជាអ្នកភូមិណាសារ៉ែត» ។

អ- ព្រះអង្គមានព្រះបន្ទូលទៅគេថា៖

យ- «គឺខ្ញុំហ្នឹងហើយ» ។

អ- រីឯយូដាស ជាអ្នកក្បត់ព្រះអង្គក៏នៅជាមួយពួកគេដែរ ។ [៦]កាលព្រះយេស៊ូមានព្រះបន្ទូលទៅគេថា
"គឺខ្ញុំហ្នឹងហើយ" ដូច្នេះ គេថយក្រោយ ហើយដួលដាច់ផ្ងារទាំងអស់គ្នា ។ [៧]ព្រះយេស៊ូមានព្រះ
បន្ទូលសួរគេម្ដងទៀតថា៖

យ-  «អ្នករាល់គ្នាមករកនរណា ?»

អ-  គេទូលថា៖

ឆ-  «រកឈ្មោះយេស៊ូ ជាអ្នកភូមិណាសារ៉ែត» ។

អ-  ៨ព្រះយេស៊ូមានព្រះបន្ទូល ទៅគេថា៖

យ-  «ខ្ញុំបានប្រាប់អ្នករាល់គ្នាថា ខ្ញុំហ្នឹងហើយ បើអ្នករាល់គ្នាមករកខ្ញុំ ទុកឲ្យអ្នកទាំងនេះចេញទៅចុះ»
។

អ-  ៩ព្រះអង្គមានព្រះបន្ទូលដូច្នេះ ស្របតាមសេចក្ដី ដែលព្រះអង្គបានថ្លែងទុកមកថា "អស់អ្នក ដែល
ព្រះអង្គប្រទានមកទូលបង្គំ ឥតមាននរណាម្នាក់ត្រូវវិនាសឡើយ" ។ ១០លោកស៊ីម៉ូន សិលាមានដាវ
មួយ គាត់ហូតកាប់អ្នកបំរើម្នាក់របស់លោកមហាបូជាចារ្យដាច់ស្លឹកត្រចៀកស្ដាំ អ្នកបំរើនោះ
ឈ្មោះម៉ាល់ឃូស ។ ១១ព្រះយេស៊ូមាន ព្រះបន្ទូលទៅលោកសិលាថា៖

យ-  «ស៊កដាវទៅក្នុងស្រោមវិញទៅ តើអ្នកមិនចង់ឲ្យខ្ញុំផឹកពីពែងនៃទុក្ខលំបាក ដែលព្រះបិតាប្រទាន
មកខ្ញុំទេឬ? » ។

អ-  ១២ពួកទាហាន និងមេបញ្ជាការរបស់គេ ព្រមទាំងកងរក្សាព្រះវិហារ*របស់ជនជាតិយូដា នាំគ្នា
ចាប់ព្រះយេស៊ូហើយចងព្រះអង្គ ។ ១៣គេនាំព្រះអង្គទៅជួបលោកហាណ្ណាមុនគេ ព្រោះលោកត្រូវ
ជាឪពុកក្មេករបស់លោកកៃផាស ដែលកាន់តំណែងជាមហាបូជាចារ្យនៅឆ្នាំនោះ ១៤គឺលោកកៃ
ផាសនេះហើយ ដែលបានឲ្យយោបល់ទៅជនជាតិយូដាថា "គួរឲ្យមនុស្សតែម្នាក់ស្លាប់ ជា
ប្រយោជន៍ដល់ប្រជារាស្ត្រ" ។

* * *

អ-  ១៥លោកស៊ីម៉ូនសិលាដើរតាមព្រះយេស៊ូជាមួយសាវ័ក*ម្នាក់ទៀត លោកមហាបូជាចារ្យស្គាល់សាវ័ក
ម្នាក់នោះ ហេតុនេះហើយបានជាគាត់អាចចូលជាមួយព្រះយេស៊ូ ទៅទីធ្លាខាងក្នុងដំណាក់របស់
លោកមហាបូជាចារ្យ ។ ១៦រីឯលោកសិលាវិញ គាត់ឈរនៅខាងក្រៅក្បែរមាត់
ទ្វារ ។ សាវ័កដែលលោកមហាបូជាចារ្យស្គាល់នោះ ក៏ចេញមកនិយាយជាមួយស្ត្រីម្នាក់ជាអ្នកយាម
ទ្វារ ហើយនាំលោកសិលាចូលទៅខាងក្នុងដែរ ។ ១៧ស្ត្រីបំរើជាអ្នក យាមទ្វារនិយាយទៅកាន់លោក
សិលាថា៖

ឆ-  «អ្នកឯងជាសាវ័ករបស់អ្នកនោះដែរ មែនឬ ? » ។

អ-  លោកសិលាតបថា៖

ឆ-  «ទេ ! មិនមែនទេ ! » ។

អ- [១៨]ពួកអ្នកបំរើរបស់លោក មហាបូជាចារ្យ និងកងរក្សាព្រះវិហារនាំគ្នាបង្កាត់ភ្លើងអាំង ព្រោះពេល
នោះរងាណាស់ ។ លោកសិលាក៏នៅអាំងភ្លើងជាមួយពួកគេដែរ ។

* * *

អ- [១៩]លោកមហាបូជាចារ្យសួរព្រះយេស៊ូអំពីក្រុមសាវ័ក*របស់ព្រះអង្គ និងអំពីសេចក្ដីដែលព្រះអង្គប
ង្រៀន ។ [២០]ព្រះយេស៊ូមានព្រះបន្ទូលតបទៅលោកវិញថា៖

យ- «ខ្ញុំបាននិយាយ ដោយចេញមុខប្រាប់មនុស្សលោក ខ្ញុំតែងបង្រៀននៅក្នុងធម្មសាលា និងនៅក្នុង
ព្រះវិហារ ជាកន្លែង ដែលជនជាតិយូដាទាំងអស់ជួបជុំគ្នា គឺឥតនិយាយក្នុងទីលាក់កំបាំងទេ ។ [២១]
ហេតុដូចម្ដេចបានជា លោកសួរខ្ញុំ ? សូមលោកសួរអស់អ្នកដែលបានឮសេចក្ដីខ្ញុំនិយាយនោះទៅ
ដ្បិតគេសុទ្ធតែដឹងអំពីអ្វីៗ ដែលខ្ញុំបាននិយាយ» ។

អ- [២២]ពេលឮព្រះយេស៊ូមានព្រះបន្ទូលដូច្នោះ ទាហានម្នាក់ក្នុងកងរក្សាព្រះវិហារដែលឈរនៅក្បែរ
នោះ ទះកំផ្លៀងព្រះអង្គទាំងពោលថា៖

ឆ- «ម្ដេចក៏អ្នកឯងហ៊ានឆ្លើយរបៀបនេះទៅលោកមហាបូជាចារ្យ ! » ។

អ- [២៣]ព្រះយេស៊ូមាន ព្រះបន្ទូលតបទៅទាហាននោះវិញថា៖

យ- «បើខ្ញុំនិយាយខុសឆ្គង សុំប្រាប់មើល៍! តើមានឆ្គងត្រង់ណា ! តែបើខ្ញុំនិយាយត្រឹមត្រូវ ម្ដេចក៏អ្នក
វាយខ្ញុំ ? » ។

អ- [២៤]ពេលនោះ លោកហាណ្ណាបញ្ជូនព្រះអង្គទាំងជាប់ចំណង ទៅលោកកៃផាស ជាមហាបូជាចារ្យ ។

* * *

អ- [២៥]លោកស៊ីម៉ូនសិលាអាំងភ្លើងនៅទីនោះ ។ មានគេសួរលោកថា៖

ឆ- «អ្នកឯងជាសាវ័ករបស់អ្នកនោះដែរមែនឬ ? » ។

អ- លោកសិលាប្រកែកថា៖

ឆ- «ទេ ! មិនមែនទេ ! » ។

អ- [២៦]មានអ្នកបំរើរបស់មហាបូជាចារ្យម្នាក់ ត្រូវជាបងប្អូននឹងអ្នកដែលលោកសិលាកាប់ដាច់ស្លឹកត្រ
ចៀក ពោលថា៖

ឆ- «ខ្ញុំក៏បានឃើញអ្នកឯងនៅក្នុងសួនជាមួយគាត់ដែរ ! » ។

អ- [២៧]លោកសិលាប្រកែកសាជាថ្មីម្ដងទៀត ។ រំពេចនោះ ស្រាប់តែមាន់រងាវឡើង ។

* * *

អ- [២៨]បន្ទាប់មក គេបណ្ដើរព្រះយេស៊ូចេញពីដំណាក់លោកកៃផាស ទៅបន្ទាយរបស់លោកទេសាភិបា
ល ។ ពេលនោះ ភ្លឺស្រាងៗហើយ ។ ជនជាតិយូដាពុំបានចូលក្នុងបន្ទាយទេ ព្រោះគេខ្លាចមានបាប
នាំឲ្យធ្វើពិធីជប់លៀងក្នុងឱកាសបុណ្យចម្លងមិនបាន ។ [២៩]ដូច្នេះ លោកពីឡាតចេញមកជួបពួកគេ
សួរថា៖

ឆ- «តើអ្នករាល់គ្នាចោទប្រកាន់អ្នកនេះអំពីរឿងអ្វី ? » ។

អ- [៣០]គេជំរាបលោកថា៖

ឆ- «ប្រសិនបើគាត់មិនបានប្រព្រឹត្តអំពើទុច្ចរិតទេ យើងខ្ញុំនាំគាត់មកជូនលោកធ្វើអ្វី ! » ។

អ- [៣១]លោកពីឡាតមានប្រសាសន៍ ទៅគេថា៖

ឆ- «ចូរអ្នករាល់គ្នាយកគាត់ទៅវិនិច្ឆ័យទោស តាមវិន័យរបស់អ្នករាល់គ្នាទៅ !» ។

អ- ជនជាតិយូដាជំរាបទៅលោកវិញថា៖

ឆ- «យើងខ្ញុំគ្មានសិទ្ធិប្រហារជីវិតអ្នកណាសោះឡើយ» ។

អ- [៣២]គេនិយាយដូច្នេះ ស្របតាមសេចក្ដី ដែលព្រះយេស៊ូមានព្រះបន្ទូលអំពីរបៀបព្រះអង្គត្រូវសោយ
ទិវង្គត ។ [៣៣]លោកពីឡាតចូលទៅក្នុងបន្ទាយវិញ រួចហៅព្រះយេស៊ូមកសួរថា៖

ឆ- «តើអ្នកជាស្ដេចរបស់ជនជាតិយូដាមែនឬ ? » ។

អ- [៣៤]ព្រះយេស៊ូមានព្រះបន្ទូលតបថា៖

យ- «លោកមានប្រសាសន៍ដូច្នេះ តើមកពីគំនិតរបស់លោកផ្ទាល់ ឬមានអ្នកផ្សេងទៀតជំរាបលោក
? » ។

អ- [៣៥]លោកពីឡាតតបវិញថា៖

ឆ- «ខ្ញុំមិនមែនជាជនជាតិយូដាទេ! គឺជនជាតិរបស់អ្នក និងពួកនាយកបូជាចារ្យទេតើ ដែលបាន
បញ្ជូនអ្នកមកខ្ញុំ តើអ្នកបានធ្វើអ្វី ? » ។

អ- [៣៦]ព្រះយេស៊ូមានព្រះបន្ទូលតបថា៖

យ- «រាជ្យរបស់ខ្ញុំមិនមែននៅក្នុងលោកនេះទេ ។ ប្រសិនបើរាជ្យរបស់ខ្ញុំនៅក្នុងលោកនេះមែន ពួកបំ
រើរបស់ខ្ញុំមុខជានាំគ្នាតយុទ្ធមិនឲ្យគេបញ្ជូនខ្ញុំទៅ ក្នុងកណ្ដាប់ដៃរបស់សាសន៍យូដាបានឡើយ ។
ប៉ុន្តែ រាជ្យរបស់ខ្ញុំ មិនមែននៅលោកនេះទេ» ។

អ- [៣៧]លោកពីឡាតទូលសួរព្រះអង្គថា៖

ឆ- «បើដូច្នេះ តើអ្នកជាស្ដេចមែនឬ ? » ។

អ- ព្រះយេស៊ូមានព្រះបន្ទូលតបថា៖

យ- «លោកទេតើ ដែលមានប្រសាសន៍ថា ខ្ញុំជាស្ដេច ។ ខ្ញុំកើតមក ហើយខ្ញុំមកក្នុងលោកនេះ ដើម្បីផ្ដល់សក្ខីភាពអំពីសេចក្ដីពិត អ្នកណាកើតពីសេចក្ដីពិត អ្នកនោះនឹងស្ដាប់សំឡេងខ្ញុំ» ។

អ- ៣៨លោកពីឡាតទូលព្រះអង្គថា៖

ឆ- «អ្វីទៅសេចក្ដីពិតនោះ ? » ។

* * *

អ- លោកពីឡាតមានប្រសាសន៍ដូច្នោះហើយ លោកក៏ចេញទៅជួបជនជាតិយូដាជាថ្មីម្ដងទៀតប្រាប់ថា៖

ឆ- «ខ្ញុំពុំឃើញអ្នកនេះមានទោសអ្វីសោះឡើយ ។ ៣៩តាមទំនៀមទម្លាប់របស់អ្នករាល់គ្នា ខ្ញុំត្រូវដោះលែងអ្នកទោសម្នាក់ក្នុងឱកាសបុណ្យចម្លង ។ តើអ្នករាល់គ្នាចង់ឲ្យខ្ញុំដោះលែងស្ដេចយូដាឬទេ? » ។

អ- ៤០ពេលនោះ គេនាំគ្នាស្រែកឡើងសាជាថ្មីថា៖

ឆ- «កុំដោះលែងអ្នកនេះឡើយ សូមដោះលែងបារ៉ាបាសវិញ» ។

អ- រីឯឈ្មោះបារ៉ាបាសនេះជាចោរព្រៃ ។ ១៩ ១ពេលនោះ លោកពីឡាតបង្គាប់ឲ្យទាហានយកព្រះយេស៊ូទៅវាយនឹងរំពាត់ ។ ២ពួកទាហានយកបន្លាមកក្រងធ្វើជាមកុដបំពាក់ព្រះសិរសាព្រះអង្គ ហើយយកអាវពណ៌ក្រហមទុំមកពាក់ឲ្យព្រះអង្គដែរ ។ ៣បន្ទាប់មក គេនាំគ្នាចូលទៅជិតព្រះអង្គទាំងពោលថា៖

ឆ- «ស្ដេចយូដាអើយ! សូមថ្វាយបង្គំ»

អ- ហើយក៏ទះកំផ្លៀងព្រះអង្គ ។

* * *

អ- ៤លោកពីឡាតចេញទៅជួបជនជាតិយូដាសាជាថ្មី មានប្រសាសន៍ទៅគេថា៖

ឆ- «មើល៍! ខ្ញុំនាំគាត់មកខាងក្រៅ ដើម្បីឲ្យអ្នករាល់គ្នាដឹងថា ខ្ញុំពុំឃើញអ្នកនេះមានទោសអ្វីសោះ» ។

អ- ៥ពេលនោះ ព្រះយេស៊ូយាងចេញមក ទាំងពាក់ភួងបន្លាជាមកុដ និងពាក់អាវពណ៌ក្រហមទុំផង ។ លោកពីឡាតមានប្រសាសន៍ទៅគេថា៖

ឆ- «មើល៍! មនុស្សហ្នឹងហើយ ! » ។

អ- ៦កាលពួកនាយកបូជាចារ្យ និងកងរក្សាព្រះវិហារ*ឃើញព្រះអង្គគេនាំគ្នាស្រែកឡើងថា៖

ឆ- «ឆ្កាងទៅ ! ឆ្កាងទៅ ! » ។

អ- លោកពីឡាតមានប្រសាសន៍ថា៖

ឆ- «ចូរអ្នករាល់គ្នាយកគាត់ទៅឆ្កាងខ្លួនឯងទៅ ដ្បិតខ្ញុំពុំឃើញអ្នកនេះមានទោសអ្វីសោះ» ។

អ- ៧ជនជាតិយូដាជំរាបលោក ពីឡាតថា៖

ឆ- «យើងខ្ញុំមានវិន័យហើយតាមវិន័យនោះ ជននេះត្រូវតែស្លាប់ ព្រោះគាត់តាំងខ្លួនជាព្រះបុត្រារបស់ព្រះជាម្ចាស់» ។

អ- ៨កាលលោកពីឡាតឮដូច្នោះ លោករឹតតែភ័យខ្លាចថែមទៀត ។ ៩លោកចូលទៅក្នុងបន្ទាយវិញ សួរព្រះយេស៊ូថា៖

ឆ- «អ្នកមកពីណា ? » ។

អ- ព្រះយេស៊ូពុំបានឆ្លើយតបទៅលោកវិញសោះ ។ ១០ហេតុនេះលោកពីឡាតសួរព្រះអង្គថា៖

ឆ- «ម្ដេចក៏អ្នកមិននិយាយមកខ្ញុំដូច្នេះ ? អ្នកមិនដឹងថាខ្ញុំមានអំណាចដោះលែងអ្នកក៏បាន ឬឆ្កាងអ្នកក៏បានទេឬ ? » ។

អ- ១១ព្រះយេស៊ូមានព្រះបន្ទូលតបទៅគាត់ថា៖

យ- «ប្រសិនបើមិនបានទទួលអំណាចពីស្ថានលើមកទេ លោកគ្មានអំណាចលើខ្ញុំឡើយ ហេតុនេះហើយបានជាអ្នក ដែលចាប់បញ្ជូនខ្ញុំមកលោក មានបាបធ្ងន់ជាង លោកទៅទៀត» ។

អ- ១២តាំងពីពេលនោះមក លោកពីឡាតរកមធ្យោបាយដោះលែងព្រះយេស៊ូ ប៉ុន្ដែ ជនជាតិយូដានាំគ្នាស្រែកឡើងថា៖

ឆ- «បើលោកដោះលែងជននេះ លោកមិនមែនជាមិត្តសម្លាញ់របស់ព្រះចៅអធិរាជឡើយ ដ្បិតអ្នកណាតាំងខ្លួនជាស្ដេច អ្នកនោះប្រឆាំងនឹងព្រះចៅអធិរាជ ! » ។

អ- ១៣កាលលោកពីឡាតឮពាក្យនេះ លោកនាំព្រះយេស៊ូទៅខាងក្រៅ ឲ្យគង់លើវេទិកាសំរាប់កាត់ក្ដីនៅត្រង់កន្លែងមួយឈ្មោះ "លានក្រាលថ្ម" ដែលគេហៅជាភាសាហេប្រឺថា "កាប្បាថា" ១៤ពេលនោះ ជាថ្ងៃ ដែលគេរៀបចំបុណ្យចម្លង ហើយប្រមាណជាពេលថ្ងៃត្រង់ ។ លោកពីឡាតមានប្រសាសន៍ទៅកាន់ជនជាតិយូដាថា៖

ឆ- «នេះនែ៎ ! ស្ដេចរបស់អ្នករាល់គ្នា!» ។

អ- ១៥ប៉ុន្ដែ ជនជាតិយូដាស្រែកឡើងថា៖

ឆ- «សម្លាប់ចោលទៅ ! ឆ្កាងទៅ ! » ។

អ- លោកពីឡាតសួរពួកគេថា៖

ឆ- «ឲ្យខ្ញុំឆ្កាងស្ដេចរបស់អ្នករាល់គ្នាឬ ? » ។

អ- ពួកនាយកបូជាចារ្យឆ្លើយឡើងថា៖

ឆ- «ក្រៅពីព្រះចៅអធិរាជ យើងខ្ញុំគ្មានស្ដេចឯណាទៀតឡើយ» ។

អ- [១៦]ពេលនោះ លោកពីឡាតប្រគល់ព្រះយេស៊ូទៅឲ្យគេឆ្កាង ។ គេនាំគ្នាចាប់ព្រះយេស៊ូយកទៅ ។

* * *

អ- [១៧]ព្រះយេស៊ូលីឈើឆ្កាង ដោយផ្ទាល់ព្រះអង្គ ចេញពីទីក្រុងឆ្ពោះទៅកន្លែងមួយឈ្មោះ “ទួលលលា
ដ៍ក្បាល” ដែលគេហៅជាភាសាហេប្រឺថា “កុលកូថា” [១៨]គេឆ្កាងព្រះអង្គនៅទីនោះ ។ គេឆ្កាង
អ្នកទោសពីរនាក់ទៀតនៅសងខាងព្រះអង្គដែរ ព្រះយេស៊ូនៅកណ្ដាល ។ [១៩]លោកពីឡាតឲ្យគេ
សរសេរប្រកាសបោះភ្ជាប់នឹងឈើឆ្កាង ។ នៅលើប្រកាសនោះ មានសរសេរថា «យេស៊ូអ្នកភូមិណា
សារ៉ែតជាស្ដេចយូដា» ។ [២០]ជនជាតិយូដាជាច្រើន បានមើលប្រកាសនោះ ដ្បិតកន្លែង ដែលគេ
ឆ្កាងព្រះយេស៊ូនៅក្បែរទីក្រុង ហើយប្រកាសនោះសរសេរជាអក្សរហេប្រឺ ឡាតាំង និងក្រិក ។ [២១]
ពួកនាយកបូជាចារ្យ របស់ជនជាតិយូដាជំរាបលោកពីឡាតថា៖

ឆ- «សូមកុំសរសេរថា “ស្ដេចយូដា” ដូច្នេះ តែសរសេរថា “អ្នកនេះនិយាយថា ខ្ញុំជាស្ដេចយូដា” វិញ» ។

អ- [២២]លោកពីឡាតមានប្រសាសន៍តបថា៖

ឆ- «ខ្ញុំសរសេរយ៉ាងណាហើយ ត្រូវទុកយ៉ាងនោះទៅ ! » ។

* * *

អ- [២៣]ក្រោយពីបានឆ្កាងព្រះយេស៊ូរួចហើយ ពួកទាហានយកសម្លៀកបំពាក់របស់ព្រះអង្គ មកធ្វើជា
បួនចំណែកចែកគ្នាម្នាក់មួយចំណែកៗ ។ រីឯអាវវែងរបស់ព្រះអង្គវិញ ជាអាវធ្វើពីក្រណាត់តែមួយ
ផ្ទាំង គ្មានថ្នេរសោះ តាំងពីលើដល់ក្រោម ។ ដូច្នេះ គេនិយាយគ្នាថា៖

ឆ- [២៤]«កុំហែកអាវនេះធ្វើអ្វី យើងចាប់ឆ្នោតវិញ ដើម្បីឲ្យដឹងថាអាវនេះនឹងបានទៅលើអ្នកណា» ។

អ- ពួកទាហានធ្វើដូច្នេះ ស្របតាមសេចក្ដី ដែលមានចែងទុកក្នុងគម្ពីរមកថា៖ «គេបានយកសម្លៀក
បំពាក់របស់ទូលបង្គំចែកគ្នា ហើយចាប់ឆ្នោតយកអាវវែងរបស់ទូលបង្គំ» ។ [២៥]មាតាព្រះយេស៊ូ ប្អូន
ស្រីមាតាព្រះអង្គ នាងម៉ារី ជាភរិយាលោកក្លូប៉ាស និងនាងម៉ារី ជាអ្នកស្រុកម៉ាដាឡា ឈរក្បែរ
ឈើឆ្កាងរបស់ព្រះអង្គ ។ [២៦]ព្រះយេស៊ូឃើញមាតា ព្រមទាំងសាវ័ក ដែលព្រះអង្គស្រឡាញ់ នោះ
ឈរនៅជិត ទ្រង់មានព្រះបន្ទូលទៅមាតាថា៖

យ- «អ្នកអើយ ! នេះហើយកូនរបស់អ្នក» ។

អ- [២៧]បន្ទាប់មក ព្រះអង្គមានព្រះបន្ទូលទៅសាវ័កថា៖

យ- «នេះហើយម្ដាយរបស់អ្នក» ។

អ- តាំងពីពេលនោះមក សាវ័កនោះយកគាត់មកនៅជាមួយ ។

* * *

អ- [២៨]បន្ទាប់មក ព្រះយេស៊ូជ្រាបថា ព្រះអង្គបានបង្ហើយកិច្ចការទាំងអស់ចប់សព្វគ្រប់ ព្រះអង្គមាន
ព្រះបន្ទូលថា៖

យ- «ខ្ញុំស្រេកទឹក»

អ- ព្រះអង្គមានព្រះបន្ទូលដូច្នេះ ដើម្បីឲ្យបានស្របតាមសេចក្ដីគ្រប់ប្រការ ដែលមានចែងទុកក្នុងគម្ពី
រ ។ [២៩]នៅទីនោះ មានក្រឡមួយមានទឹកខ្មេះពេញ ។ ពួកទាហានយកសារាយស្ងួត ជ្រលក់ទឹកខ្មេះ
ជោក រួចរុំនៅចុងត្រែងមួយដើម រុញទៅដល់ព្រះឱស្ឋរបស់ព្រះអង្គ ។ [៣០]កាលព្រះយេស៊ូសោយ
ទឹក ខ្មេះហើយ ព្រះអង្គមានព្រះបន្ទូលថា៖

យ- «ខ្ញុំបានសំរេចសព្វគ្រប់អស់ហើយ!» ។

អ- ព្រះអង្គក៏ឱនព្រះសិរសាចុះ ហើយប្រគល់វិញ្ញាណទៅ ។

*គ្រីស្តបរិស័ទអោនខ្លួន អធិដ្ឋានមួយរយៈពេល*

អ- [៣១]ថ្ងៃនោះជាថ្ងៃរៀបចំបុណ្យចម្លង ជនជាតិយូដាមិនចង់ឲ្យមានសាកសពជាប់នឹងឈើឆ្កាងនៅថ្ងៃស
ប្ប័ទ*ឡើយ ព្រោះថ្ងៃសប្ប័ទនោះ ជាថ្ងៃបុណ្យធំ ។ ហេតុនេះហើយបានជាគេសុំលោកពីឡាត
ចេញបញ្ជាទៅទាហាន ឲ្យបំបាក់ជើងអ្នកជាប់ឆ្កាង ហើយយកសាកសពចុះមក ។ [៣២]ពួកទាហាន
នាំគ្នាមកវាយបំបាក់ជើងអ្នកទោសទីមួយ និងអ្នកទោសទីពីរ ដែលជាប់លើឈើឆ្កាងជាមួយព្រះអ
ង្គ ។ [៣៣]លុះមកដល់ព្រះយេស៊ូ គេឃើញព្រះអង្គសោយទិវង្គតផុតទៅហើយ គេមិនបំបាក់ព្រះបាទា
ព្រះអង្គទេ [៣៤]ប៉ុន្តែ ទាហានម្នាក់យកលំពែងចាក់ត្រង់ចន្លោះឆ្អឹងជំនីរព្រះអង្គ ស្រាប់តែមានទឹក និង
លោហិតហូរចេញមកមួយរំពេច ។ [៣៥]សាវ័កម្នាក់ ដែលបាន ឃើញ ធ្វើជាបន្ទាល់អំពីហេតុការណ៍
នេះ ហើយសក្ខីភាពរបស់គាត់ពិតប្រាកដមែន ។ ព្រះអង្គដឹងថាសាវ័កនោះនិយាយសេចក្ដីពិត
ដើម្បីឲ្យអ្នករាល់គ្នាជឿដែរ ។ [៣៦]ហេតុការណ៍នេះកើតឡើង ស្របតាមសេចក្ដីដែលមានចែងទុក
ក្នុងគម្ពីរមកថា៖ «គ្មានឆ្អឹងណាមួយរបស់លោកត្រូវបាក់បែកឡើយ» ។ [៣៧]មានអត្ថបទគម្ពីរមួយ
ទៀតចែងថា៖ «គេនាំគ្នាមើលអ្នកដែលគេចាក់ទម្លុះ» ។

* * *

អ- [៣៨]បន្ទាប់មក លោកយ៉ូសែប ជាអ្នកស្រុកអរីម៉ាថេ បានទៅសុំច្បាប់លោកពីឡាត យកព្រះសពព្រះ
យេស៊ូ ។ លោកយ៉ូសែបនេះក៏ជាសាវ័ក របស់ព្រះយេស៊ូដែរតែមិនហ៊ានចេញមុខទេ ព្រោះខ្លាចជន

ជាតិយូដា ។ លោកពីឡាតអនុញ្ញាតឲ្យ ហើយលោកយ៉ូសែបក៏មកដោះព្រះសពយកទៅ ។ ៣៩រីឯ
លោកនីកូដេម ដែលមកគាល់ព្រះយេស៊ូទាំងយប់កាលពីមុន ក៏បានមកដែរ ។ លោកយកជ័រល្វីង
ទេស លាយនឹងគ្រឿងក្រអូបប្រមាណជាកន្លះហាបមកផង ។ ៤០លោកទាំងពីរយកព្រះសពព្រះ
យេស៊ូមករុំនឹងសំពត់ស្ទប អប់គ្រឿងក្រអូបតាមទំនៀមទម្លាប់ពិធីបញ្ចុះសពរបស់ជនជាតិយូដា ។
៤១នៅកន្លែងគេឆ្កាងព្រះយេស៊ូមានសួនឧទ្យានមួយ ក្នុងសួននោះមានផ្នូរមួយថ្មី ពុំទាន់ដែលដាក់សព
ណានៅឡើយ ។ ៤២គេដាក់ព្រះយេស៊ូនៅក្នុងផ្នូរនោះ ព្រោះនៅជិតស្រាប់ ដ្បិតថ្ងៃនោះជាថ្ងៃ
រៀបចំបុណ្យចម្លង ។

# រដូវបុណ្យចម្លង

# ថ្ងៃអាទិត្យបុណ្យចម្លង រាត្រីបុណ្យចម្លង ឆ្នាំ ក

## ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ

**អាលេលូយ៉ា! អាលេលូយ៉ា! អាលេលូយ៉ា!** សូមលើកតម្កើងព្រះយេស៊ូ ដែលទ្រង់បានឈ្នះ
សេចក្ដីស្លាប់ ចូរយើងទទួលដោយសប្បាយ ជីវិតថ្មីពីព្រះអម្ចាស់ ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **២៨,១-១០**

១ក្រោយថ្ងៃសប្ប័ទ គឺនៅព្រឹកថ្ងៃអាទិត្យ នាងម៉ារី ជាអ្នកស្រុកម៉ាដាឡា និងនាងម៉ារីម្នាក់ទៀត នាំ
គ្នាទៅមើលផ្នូរ ។ ២ពេលនោះ ស្រាប់តែផែនដីរញ្ជួយយ៉ាងខ្លាំង មានទេវទូតរបស់ព្រះអម្ចាស់ ចុះពីស្ថាន
បរមសុខមក ប្រមៀលថ្មចេញពីមាត់ផ្នូរ ហើយអង្គុយលើថ្មនោះថែមទៀតផង ។ ៣ទេវទូតនោះ មាន
ទ្រង់ទ្រាយភ្លឺដូចផ្លេកបន្ទោរ និងមានសម្លៀកបំពាក់សដូចសំឡី ។ ៤ពួកទាហានភ័យញ័រជាខ្លាំង ភាំង
ស្មារតីដូចមនុស្សស្លាប់ ។ ៥ទេវទូតនិយាយទៅកាន់ស្ត្រីៗថា៖ «កុំភ័យខ្លាចអ្វី! ខ្ញុំដឹងថា នាងៗ មករក
ព្រះយេស៊ូ ជាអ្នកភូមិណាសារ៉ែត ដែលគេបានឆ្កាង ។ ៦ព្រះអង្គមិននៅទីនេះទេ ព្រះជាម្ចាស់បានប្រោស
ព្រះអង្គអោយមានព្រះជន្មរស់ឡើងវិញ ដូចទ្រង់មានព្រះបន្ទូលរួចមកហើយ! សុំមកមើលកន្លែងដែល
គេដាក់ព្រះសពព្រះអង្គឯណេះសិន ៧ហើយសឹមអញ្ជើញទៅប្រាប់សាវ័ករបស់ព្រះអង្គជាប្រញាប់ថា
ព្រះអង្គមានព្រះជន្មរស់ឡើងវិញហើយ ឥឡូវនេះព្រះអង្គយាងទៅស្រុកកាលីឡេមុនអ្នករាល់គ្នា ។ នៅទី
នោះ អ្នករាល់គ្នានឹងឃើញព្រះអង្គ ។ សុំនាងជ្រាប!» ។

៨ស្ត្រីទាំងនោះប្រញាប់ប្រញាល់ចេញពីផ្នូរ ទាំងភ័យទាំងអរយ៉ាងខ្លាំង នាំដំណឹងនេះរត់ទៅជំរាប
ក្រុមសាវ័ក ។ ៩ពេលនោះ ស្រាប់តែព្រះយេស៊ូយាងមកជួបពួកនាង ទ្រង់មានព្រះបន្ទូលថា៖ «ជំរាបសួរ
នាង!» ។ នាងទាំងនោះក៏ចូលមកឱបព្រះបាទា ហើយក្រាបថ្វាយបង្គំព្រះអង្គ ។ ១០ព្រះយេស៊ូមានព្រះ
បន្ទូលថា៖ «កុំភ័យខ្លាចអ្វីឡើយ! សុំទៅប្រាប់បងប្អូនខ្ញុំ ឲ្យទៅស្រុកកាលីឡេទៅ គេនឹងឃើញខ្ញុំនៅទី
នោះ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យបុណ្យចម្លង អភិបូជានៅពេលថ្ងៃ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម យហ ១៣,៣៤

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះគ្រីស្តដែលជាយញ្ញបូជារបស់យើងក្នុងឱកាសបុណ្យចម្លង បានបូជាព្រះជន្មរួចស្រេចទៅហើយ! យើងនាំគ្នាបរិភោគយ៉ាងសប្បាយ នៅពិធីជប់លៀង របស់ព្រះអម្ចាស់! **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** ២០,១-៩

[១]នៅព្រឹកថ្ងៃអាទិត្យ កាលនៅងងឹតនៅឡើយ នាងម៉ារី ជាអ្នកស្រុកម៉ាដាឡា ចេញដំណើរឆ្ពោះទៅ
ផ្នូរ ហើយឃើញថា មានគេយកថ្មពីមាត់ផ្នូរផុតទៅហើយ ។ [២]នាងក៏រត់មកជំរាបលោកស៊ីម៉ូនសិលា
និងសាវ័កម្នាក់ទៀតដែលព្រះយេស៊ូស្រឡាញ់ថា៖ «គេយកព្រះអម្ចាស់ចេញពីផ្នូរបាត់ហើយ យើងមិន
ដឹងជាគេយកដាក់ឯណាទេ!» ។ [៣]លោកសិលានិងសាវ័កម្នាក់ទៀតនោះ ក៏ចេញទៅផ្នូរ ។ [៤]សាវ័កទាំង
ពីររត់ទៅជាមួយគ្នាតែសាវ័កម្នាក់នោះរត់លឿនជាងលោកសិលា ទៅដល់ផ្នូរមុន ។ [៥]គាត់ឈ្ងោកមើល
ទៅឃើញ សំពត់ស្ដប តែគាត់មិនបានចូលទៅក្នុងផ្នូរឡើយ ។ [៦]លោកស៊ីម៉ូនសិលារត់តាមក្រោយ មក
ដល់ គាត់ចូលទៅក្នុងផ្នូរ ហើយសម្លឹងមើលសំពត់ស្ដបនៅទីនោះ [៧]ព្រមទាំងក្រណាត់ដែលគេ គ្របព្រះ
សិរសាព្រះអង្គ មូរទុកដោយឡែក គឺមិននៅជាមួយសំពត់ស្ដបទេ ។ [៨]ពេលនោះ សាវ័កដែលទៅដល់
ផ្នូរមុន ក៏ចូលទៅខាងក្នុងដែរ គាត់បានឃើញហើយជឿ ។ [៩]កាលណោះ ក្រុមសាវ័កពុំទាន់យល់អត្ថន័យ
គម្ពីរដែលចែងទុកមកថា ព្រះយេស៊ូត្រូវមានព្រះជន្មរស់ឡើងវិញនៅឡើយទេ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២ ក្នុងរដូវបុណ្យចម្លង ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម យហ ២០,២៩**

**អាលេលូយ៉ា! អាលេលូយ៉ា!** លោកថូម៉ាសបានឃើញព្រះអម្ចាស់ហើយបានជឿ ។
អ្នកជឿដោយឥតបានឃើញ ពិតជាមានសុភមង្គលហើយ! **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** **២០,១៩-៣១**

[១៩]នៅល្ងាចថ្ងៃអាទិត្យក្រោយព្រះយេស៊ូសោយទិវង្គត ក្រុមសាវ័កនៅក្នុងផ្ទះ ខ្ទាស់ទ្វារយ៉ាងជាប់
ព្រោះខ្លាចជនជាតិយូដា ។ ស្រាប់តែព្រះយេស៊ូយាងមកឈរនៅកណ្ដាលចំណោមពួកគេ ហើយមានព្រះ
បន្ទូលថា៖ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្ត!» ។ [២០]ព្រះអង្គមានព្រះបន្ទូលដូច្នេះ
ទាំងបង្ហាញស្នាមរបួសនៅព្រះហស្ដ និងនៅត្រង់ឆ្អឹងជំនីរឲ្យគេឃើញផង ។ ក្រុមសាវ័កសប្បាយចិត្តជា
ខ្លាំង ដោយបានឃើញព្រះអម្ចាស់ ។ [២១]ព្រះយេស៊ូមានព្រះបន្ទូលទៅគេសាជាថ្មីថា៖ «សូមឲ្យអ្នករាល់
គ្នាបានប្រកបដោយសេចក្ដីសុខសាន្ត! ដូចព្រះបិតាបានចាត់ខ្ញុំឲ្យមកយ៉ាងណា ខ្ញុំចាត់អ្នករាល់គ្នាឲ្យទៅ
យ៉ាងនោះដែរ» ។

[២២]បន្ទាប់ពីមានព្រះបន្ទូលហើយ ព្រះអង្គផ្លុំលើពួកគេ ទាំងមានព្រះបន្ទូលថា៖ «ចូរទទួលព្រះ
វិញ្ញាណ! ។ [២៣]បើអ្នករាល់គ្នាលើកលែងទោសអ្នកណាឲ្យរួចពីបាប ព្រះជាម្ចាស់ក៏នឹងលើកលែងទោស
អ្នកនោះឲ្យរួចពីបាបដែរ ។ ផ្ទុយទៅវិញ បើអ្នករាល់គ្នាប្រកាន់ទោសអ្នកណា អ្នកនោះមុខជាត្រូវជាប់
ទោសមិនខាន» ។

[២៤]កាលព្រះយេស៊ូយាងមកនោះ លោកថូម៉ាសហៅឌីឌីម ជាសាវ័កម្នាក់ក្នុងចំណោមសាវ័កទាំងដប់
ពីរ មិនបាននៅជាមួយពួកគេទេ ។ [២៥]សាវ័កឯទៀតៗប្រាប់គាត់ថា៖ «យើងបានឃើញព្រះអម្ចាស់» ។
ប៉ុន្តែ គាត់និយាយទៅពួកគេវិញថា៖ «បើខ្ញុំមិនឃើញស្នាមដែកគោលនៅបាតដៃ មិនបានដាក់ម្រាមដៃ
ក្នុងស្នាមដែកគោល ហើយបើខ្ញុំមិនបានដាក់ដៃត្រង់ឆ្អឹងជំនីររបស់លោកទេ ខ្ញុំមិនជឿជាដាច់ខាត» ។
[២៦]ប្រាំបីថ្ងៃក្រោយមក ក្រុមសាវ័កជួបជុំគ្នានៅក្នុងផ្ទះសាជាថ្មី លោកថូម៉ាសក៏នៅជាមួយដែរ ។
ពេលនោះ ទ្វារផ្ទះនៅខ្ទាស់ជាប់ ព្រះយេស៊ូយាងមកឈរនៅកណ្ដាលចំណោមពួកគេទាំងមានព្រះបន្ទូល
ថា៖ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្ត!» ។ [២៧]បន្ទាប់មក ព្រះអង្គមានព្រះបន្ទូល
ទៅលោកថូម៉ាសថា៖ «មើលដៃខ្ញុំនេះចូរដាក់ម្រាមដៃអ្នកមក ហើយដាក់ដៃអ្នកត្រង់ឆ្អឹងជំនីរខ្ញុំ ។ ចូរ

ជឿទៅ! កុំរឹងរូសមិនព្រមជឿដូច្នេះ!» ។ ២៨លោកថូម៉ាសទូលព្រះអង្គថា៖ «ព្រះអង្គពិតជាព្រះអម្ចាស់
និងជាព្រះរបស់ទូលបង្គំមែន!» ។ ២៩ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «អ្នកជឿមកពីអ្នកបាន
ឃើញខ្ញុំ អ្នកណាជឿដោយឥតបានឃើញសោះ អ្នកនោះមានសុភមង្គលហើយ!» ។

៣០ព្រះយេស៊ូបានធ្វើទីសំគាល់ជាច្រើនទៀតឲ្យក្រុមសាវ័កឃើញ តែគ្មានកត់ត្រាទុកក្នុងសៀវភៅនេះ
ទេ ។ ៣១រីឯសេចក្ដីដែលមានកត់ត្រាមកនេះ គឺក្នុងគោលបំណងឲ្យអ្នករាល់គ្នាជឿថា ព្រះយេស៊ូពិតជា
ព្រះគ្រីស្ដនិងពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយឲ្យអ្នករាល់គ្នាដែលជឿ មានជីវិតដោយរួមជាមួយ
ព្រះអង្គ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៣ ក្នុងរដូវបុណ្យចម្លង ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ**

**អាលេលូយ៉ា! អាលេលូយ៉ា!** បពិត្រព្រះអម្ចាស់យេស៊ូ! សូមព្រះអង្គបកស្រាយគម្ពីរ
ឲ្យយើងខ្ញុំផង! សូមឲ្យយើងខ្ញុំមានចិត្តរំភើបយ៉ាងខ្លាំង! **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត លូកា** **២៤,១៣-៣៥**

[១៣]នៅថ្ងៃក្រោយពីព្រះយេស៊ូសោយទិវង្គត មានសាវ័កពីរនាក់ធ្វើដំណើរឆ្ពោះទៅភូមិអេម៉ាអ៊ូស
ចម្ងាយប្រមាណដប់មួយគីឡូម៉ែត្រពីក្រុងយេរូសាឡឹម ។ [១៤]គេនិយាយគ្នាអំពីហេតុការណ៍ទាំងប៉ុន្មាន
ដែលកើតមាន ។ [១៥]នៅពេលដែលគេកំពុងតែពិភាក្សាគ្នា ព្រះយេស៊ូយាងមកជិតគេ ហើយធ្វើដំណើរ
ជាមួយគេទៅ ។ [១៦]គេឃើញព្រះយេស៊ូផ្ទាល់នឹងភ្នែក តែគេមិនអាចស្គាល់ព្រះអង្គបានឡើយ ។
[១៧]ព្រះយេស៊ូមានព្រះបន្ទូលសួរគេថា៖ «អ្នករាល់គ្នាដើរបណ្ដើរជជែកគ្នាបណ្ដើរ តើនិយាយគ្នាអំពីរឿង
អ្វីហ្នឹង?» ។ គេក៏ឈប់ដើរ ឈរស្ងៀម មានទឹកមុខស្រងូត ។ [១៨]ម្នាក់ឈ្មោះក្លេអូប៉ាសទូលព្រះអង្គថា៖
«ប្រជាជនទាំងអស់នៅក្រុងយេរូសាឡឹម ដឹងហេតុការណ៍ ដែលកើតឡើងប៉ុន្មានថ្ងៃមុននេះគ្រប់ៗគ្នា
ម្ដេចក៏លោកមិនដឹង?» ។ [១៩]ព្រះអង្គសួរទៅគេថា៖ «តើរឿងអ្វី?» ។ គេទូលឆ្លើយថា៖ «គឺរឿង
លោកយេស៊ូជាអ្នកភូមិណាសារ៉ែត ។ ព្រះជាម្ចាស់និងប្រជាជនទាំងមូលទទួលស្គាល់ថា លោកជាព្យាការី
ម្នាក់មានឫទ្ធានុភាពក្នុងគ្រប់កិច្ចការ ដែលលោកបានធ្វើ និងគ្រប់ពាក្យសំដីដែលលោកបានថ្លែង ។
[២០]ពួកនាយកបូជាចារ្យ និងពួកមន្ត្រីរបស់យើង បានបញ្ជូនលោកទៅឲ្យគេកាត់ទោសប្រហារជីវិត ហើយ
គេឆ្កាងលោកផង ។ [២១]យើងបានសង្ឃឹមថា លោកនេះហើយ ដែលនឹងរំដោះជនជាតិអ៊ីស្រាអែល តែ
ហេតុការណ៍ទាំងនោះបានកន្លងផុតទៅបីថ្ងៃហើយ ។ [២២]មានស្ត្រីខ្លះក្នុងចំណោមពួកយើងបានធ្វើឲ្យយើង
ឆ្ងល់យ៉ាងខ្លាំង គឺនាងនាំគ្នាទៅផ្នូរតាំងពីព្រលឹម [២៣]តែមិនបានឃើញសពលោកទេ ។ នាងត្រឡប់មកវិញ
រៀបរាប់ថា នាងបានឃើញទេវទូតដែលប្រាប់ថា លោកមានជីវិត ។ [២៤]មានពួកយើងខ្លះនាំគ្នាទៅផ្នូរ
ដែរ ហើយបានឃើញ ដូចពាក្យស្ត្រីទាំងនោះនិយាយមែន ប៉ុន្តែពុំមាននរណាបានឃើញលោកសោះ» ។
[២៥]ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «មនុស្សខ្វះប្រាជ្ញាអើយ! អ្នករាល់គ្នាមិនងាយជឿពាក្យទាំង
ប៉ុន្មាន ដែលពួកព្យាការីបានថ្លែងនោះទេ! ។ [២៦]ព្រះគ្រីស្តត្រូវតែរងទុក្ខលំបាកបែបនេះសិន មុននឹងចូល
ទៅទទួលសិរីរុងរឿងរបស់ព្រះអង្គ» ។ [២៧]បន្ទាប់មក ព្រះយេស៊ូបកស្រាយសេចក្ដី ដែលមានចែងទុកអំពី
ព្រះអង្គនៅក្នុងគម្ពីរទាំងមូល ដោយចាប់ផ្ដើមពីគម្ពីរលោកម៉ូសេ រហូតដល់គម្ពីរព្យាការីទាំងអស់ ។
[២៨]លុះមកជិតដល់ភូមិ ដែលសាវ័កទាំងពីរបម្រុងនឹងទៅ ព្រះយេស៊ូធ្វើហាក់ដូចជាចង់យាងបន្តទៅ
មុខទៀត ។ [២៩]គេឃាត់ព្រះអង្គថា៖ «សូមលោកស្នាក់នៅជាមួយយើងខ្ញុំទីនេះហើយ ដ្បិតថ្ងៃកាន់តែ

ទាប ហើយជិតយប់ផង» ។ ព្រះយេស៊ូក៏ចូលទៅស្នាក់នៅជាមួយគេ ។ ៣០ព្រះអង្គគង់រួមតុជាមួយគេ
យកនំប៉័ងមកកាន់ អរព្រះគុណព្រះជាម្ចាស់ រួចកាច់ប្រទានឲ្យគេ ។ ៣១ពេលនោះ ភ្នែកគេបានភ្លឺឡើង
មើលព្រះអង្គស្គាល់ ប៉ុន្តែព្រះអង្គបាត់ពីមុខគេទៅ ។ ៣២គេនិយាយគ្នាថា៖ «កាលព្រះអង្គមានព្រះបន្ទូល
មកកាន់យើង ព្រមទាំងបកស្រាយគម្ពីរឲ្យយើងស្ដាប់ នៅតាមផ្លូវ យើងមានចិត្តរំភើបយ៉ាងខ្លាំង!» ។
៣៣គេក៏ក្រោកឡើង វិលត្រឡប់ទៅក្រុងយេរូសាឡឹមវិញភ្លាម ឃើញក្រុមសាវ័កទាំងដប់មួយនាក់នៅជុំ
គ្នា ជាមួយពួកគេឯទៀតៗ ៣៤គេប្រាប់អ្នកទាំងពីរថា៖ «ព្រះអម្ចាស់មានព្រះជន្មថ្មីដ៏រុងរឿងពិតប្រាកដ
មែន! ហើយឲ្យស៊ីម៉ូនឃើញព្រះអង្គបង្ហាញខ្លួន!» ។ ៣៥សាវ័កទាំងពីរនាក់រៀបរាប់ហេតុការណ៍ ដែល
កើតឡើងនៅតាមផ្លូវ ហើយគេបានស្គាល់ព្រះអង្គ នៅពេលព្រះអង្គកាច់នំប៉័ង ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៤ ក្នុងរដូវបុណ្យចម្លង ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម យហ ១០,១៤-១៥**

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះយេស៊ូជាគង្វាលដ៏ល្អប្រសើរ! ព្រះអង្គស្គាល់ចៀមរបស់ព្រះអង្គ ហើយចៀមក៏ស្គាល់ព្រះអង្គដែរ ។ ព្រះអង្គស៊ូប្ដូរជីវិតដើម្បីចៀមរបស់ព្រះអង្គ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** **១០,១-១០**

ព្រះយេស៊ូមានព្រះបន្ទូលមកកាន់ពួកផារីស៊ីថា៖ ១«ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នកណាមិន
ចូលក្នុងក្រោលចៀមតាមទ្វារ តែផ្លោះចូលតាមកន្លែងផ្សេង អ្នកនោះជាចោរលួច ចោរប្លន់ ។ ២រីឯអ្នក
ដែលចូលតាមទ្វារ ពិតជាអ្នកគង្វាលរបស់ចៀម ។ ៣ឆ្មាំទ្វារបើកទ្វារឲ្យគាត់ចូល ហើយចៀមទាំងប៉ុន្មាន
ស្ដាប់សំឡេងគាត់ ។ គាត់ហៅចៀមផ្ទាល់របស់គាត់តាមឈ្មោះរបស់វារៀងៗខ្លួន រួចនាំចេញទៅខាង
ក្រៅ ។ ៤លុះគាត់បញ្ចេញចៀមចេញពីក្រោលអស់ហើយ គាត់ដើរនាំមុខវា ហើយវាដើរតាមក្រោយ
គាត់ ពីព្រោះវាស្គាល់សំឡេងរបស់គាត់ ។ ៥ចៀមទាំងនោះមិនដើរតាមអ្នកដទៃជាដាច់ខាត ផ្ទុយទៅ
វិញ វារត់គេចចេញឆ្ងាយពីគេ ព្រោះវាមិនស្គាល់សំឡេងរបស់អ្នកដទៃឡើយ» ។

៦ព្រះយេស៊ូមានព្រះបន្ទូលជាប្រស្នានេះឲ្យគេស្ដាប់ ប៉ុន្តែ គេពុំបានយល់ថា ព្រះអង្គមានព្រះបន្ទូលអំពី
រឿងអ្វីឡើយ ។

៧ព្រះយេស៊ូមានព្រះបន្ទូលទៅគេទៀតថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ខ្ញុំហ្នឹងហើយ ជា
ទ្វារសម្រាប់ឲ្យចៀមចេញចូល ។ ៨អ្នកដែលមកមុនខ្ញុំទាំងប៉ុន្មាន សុទ្ធតែជាចោរលួច ចោរប្លន់ទាំងអស់
ចៀមមិនបានស្ដាប់សំឡេងអ្នកទាំងនោះឡើយ ។ ៩ខ្ញុំហ្នឹងហើយជាទ្វារ អ្នកណាចូលតាមខ្ញុំ ព្រះជាម្ចាស់
នឹងសង្គ្រោះអ្នកនោះ អ្នកនោះនឹងចេញចូល ព្រមទាំងរកឃើញចំណីអាហារថែមទៀតផង ។ ១០ចោរវា
មក គិតតែពីលួចប្លន់ គិតតែពីសម្លាប់ និងបំផ្លាញប៉ុណ្ណោះ ។ រីឯខ្ញុំវិញ ខ្ញុំមកដើម្បីឲ្យមនុស្សលោកមាន
ជីវិត ហើយឲ្យគេមានជីវិតពេញបរិបូណ៌ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៥ ក្នុងរដូវបុណ្យចម្លង ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម យហ ១៤,៦.៩**

**អាលេលូយ៉ា! អាលេលូយ៉ា!** បពិត្រព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់!
ព្រះអង្គពិតជាផ្លូវ ជាសេចក្ដីពិត និងជាជីវិត ។
អ្នកណាជឿលើព្រះបុត្រា អ្នកនោះក៏ស្គាល់ព្រះបិតាដែរ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** **១៤,១-១២**

នៅពេលកំណត់ដែលព្រះយេស៊ូត្រូវឆ្លងពីលោកនេះ ឆ្ពោះទៅព្រះបិតា ព្រះអង្គមានព្រះបន្ទូលទៅ
កាន់ក្រុមសាវ័កថា៖ ១«កុំរន្ធត់ចិត្តធ្វើអ្វី អ្នករាល់គ្នាជឿលើព្រះជាម្ចាស់ហើយ សុំជឿលើខ្ញុំផង ។ ២ក្នុង
ដំណាក់របស់ព្រះបិតាខ្ញុំ មានលំនៅជាច្រើន ។ បើពុំដូច្នោះទេ ខ្ញុំមិនបានប្រាប់អ្នករាល់គ្នាថា ខ្ញុំទៅ
រៀបចំកន្លែងទុកឲ្យអ្នករាល់គ្នាឡើយ ។ ៣ពេលខ្ញុំទៅរៀបចំកន្លែងទុកឲ្យអ្នករាល់គ្នារួចហើយ ខ្ញុំនឹងត្រ
ឡប់មកវិញ យកអ្នករាល់គ្នាទៅជាមួយខ្ញុំ ដើម្បីឲ្យអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅ ។ ៤ឯកន្លែង
ដែលខ្ញុំទៅនោះ អ្នករាល់គ្នាក៏ស្គាល់ផ្លូវទៅដែរ» ។

៥លោកថូម៉ាសទូលព្រះអង្គថា៖ «បពិត្រព្រះអម្ចាស់! ធ្វើដូចម្ដេចឲ្យយើងខ្ញុំអាចស្គាល់ផ្លូវទៅបាន
បើយើងខ្ញុំមិនដឹងថា ព្រះអង្គយាងទៅទីណាផងនោះ» ។ ៦ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ខ្ញុំ
ហ្នឹងហើយជាផ្លូវ ជាសេចក្ដីពិត និងជាជីវិត ។ គ្មាននរណាម្នាក់ អាចទៅកាន់ព្រះបិតាបានឡើយ លើក
លែងតែទៅតាមរយៈខ្ញុំ ។ ៧បើអ្នករាល់គ្នាស្គាល់ខ្ញុំ អ្នករាល់គ្នាក៏ស្គាល់ព្រះបិតារបស់ខ្ញុំដែរ ។ ឥឡូវនេះ
អ្នករាល់គ្នាស្គាល់ព្រះអង្គហើយ ព្រមទាំងបានឃើញព្រះអង្គថែមទៀតផង» ។

៨លោកភីលីពទូលព្រះអង្គថា៖ «ឱព្រះអម្ចាស់អើយ! សូមបង្ហាញព្រះបិតាឲ្យយើងខ្ញុំឃើញផង នោះ
យើងខ្ញុំអស់ចិត្តហើយ» ។ ៩ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ភីលីពអើយ! ខ្ញុំនៅជាមួយអ្នករាល់
គ្នាតាំងពីយូរមកហើយ ម្ដេចអ្នកនៅតែមិនស្គាល់ខ្ញុំ! ។ អ្នកណាបានឃើញខ្ញុំ ក៏បានឃើញព្រះបិតាដែរ ។
ហេតុដូចម្ដេចបានជាអ្នកថា សូមបង្ហាញព្រះបិតាឲ្យយើងខ្ញុំឃើញផងដូច្នេះ? ១០តើអ្នកមិនជឿថា ខ្ញុំនៅ
ក្នុងព្រះបិតា ហើយព្រះបិតាគង់នៅក្នុងខ្ញុំទេឬ? ។ សេចក្ដីដែលខ្ញុំនិយាយប្រាប់អ្នករាល់គ្នា មិនមែន
ចេញមកពីខ្ញុំផ្ទាល់ទេ គឺព្រះបិតាដែលស្ថិតនៅជាប់នឹងខ្ញុំ ទ្រង់បំពេញកិច្ចការរបស់ព្រះអង្គ ។ ១១ពេលខ្ញុំ

និយាយថា ខ្ញុំនៅក្នុងព្រះបិតា ហើយព្រះបិតានៅក្នុងខ្ញុំ ចូរជឿខ្ញុំចុះ បើមិនជឿសេចក្ដីដែលខ្ញុំនិយាយនេះទេ ចូរជឿដោយឃើញកិច្ចការទាំងនោះទៅ ។

១២ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នកណាជឿលើខ្ញុំ អ្នកនោះនឹងធ្វើកិច្ចការដែលខ្ញុំធ្វើដែរ ហើយនឹងធ្វើកិច្ចការធំជាងនេះទៅទៀត ពីព្រោះខ្ញុំទៅឯព្រះបិតា» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៦ ក្នុងរដូវបុណ្យចម្លង ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម ១ យហ ៥,៦**

**អាលេលូយ៉ា! អាលេលូយ៉ា!** ចូររួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផ្ដល់សក្ខីភាពថា ព្រះយេស៊ូពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់ ដ្បិតព្រះវិញ្ញាណជាសេចក្ដីពិត ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** **១៤,១៥-២១**

នៅពេលកំណត់ដែលព្រះយេស៊ូត្រូវឆ្លងពីលោកនេះ ឆ្ពោះទៅព្រះបិតា ព្រះអង្គមានព្រះបន្ទូលទៅ
កាន់ក្រុមសាវ័ក ថា៖ [១៥]«ប្រសិនបើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ អ្នករាល់គ្នាពិតជាកាន់តាមបទបញ្ជារបស់ខ្ញុំ
[១៦]ខ្ញុំនឹងទូលអង្វរព្រះបិតា ហើយទ្រង់ប្រទានព្រះជួយការពារមួយអង្គទៀត ឲ្យគង់នៅជាមួយអ្នករាល់គ្នា
ជាដរាបតរៀងទៅ ។ [១៧]ព្រះអង្គជាព្រះវិញ្ញាណ ដែលសំដែងសេចក្ដីពិត ។ មនុស្សលោកពុំអាចទទួល
ព្រះអង្គបានទេ ព្រោះគេមើលព្រះអង្គមិនឃើញ ហើយក៏មិនស្គាល់ព្រះអង្គផង ។ រីឯអ្នករាល់គ្នាវិញ អ្នក
រាល់គ្នាស្គាល់ព្រះអង្គ ព្រោះព្រះអង្គស្ថិតនៅជាប់នឹងអ្នករាល់គ្នា ហើយព្រះអង្គនឹងគង់ក្នុងអ្នករាល់គ្នា ។
[១៨]ខ្ញុំមិនបោលអ្នករាល់គ្នា ឲ្យនៅកំព្រាឡើយ ខ្ញុំនឹងមករកអ្នករាល់គ្នាវិញ ។ [១៩]បន្តិចទៀត មនុស្សលោក
នឹងលែងឃើញខ្ញុំទៀតហើយ ។ រីឯអ្នករាល់គ្នាវិញ អ្នករាល់គ្នានឹងឃើញខ្ញុំ ព្រោះខ្ញុំមានជីវិត ហើយអ្នក
រាល់គ្នាក៏នឹងមានជីវិតដែរ ។ [២០]នៅថ្ងៃនោះ អ្នករាល់គ្នានឹងដឹងថា ខ្ញុំនៅក្នុងព្រះបិតារបស់ខ្ញុំ ហើយអ្នក
រាល់គ្នានៅក្នុងខ្ញុំ ខ្ញុំក៏នៅក្នុងអ្នករាល់គ្នាដែរ ។ [២១]អ្នកណាមានវិន័យរបស់ខ្ញុំ និងប្រតិបត្តិតាម គឺអ្នកនោះ
ហើយ ដែលស្រឡាញ់ខ្ញុំ ។ ព្រះបិតារបស់ខ្ញុំ ស្រឡាញ់អ្នកដែលស្រឡាញ់ខ្ញុំ ហើយខ្ញុំក៏ស្រឡាញ់អ្នកនោះ
ដែរ ខ្ញុំនឹងបង្ហាញឲ្យអ្នកនោះស្គាល់ខ្ញុំថែមទៀតផង» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# បុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ ឆ្នាំ ក

## ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះអម្ចាស់យាងឡើង ប្រជាជនស្រែកជ័យឃោសន៍ ។
ព្រះអង្គយាងឡើងទៅទីដ៏ខ្ពង់ខ្ពស់បំផុត ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **២៨,១៦-២០**

[១៦]សាវ័កទាំងដប់មួយនាក់នាំគ្នាធ្វើដំណើរទៅស្រុកកាលីឡេ ហើយឡើងទៅលើភ្នំដែលព្រះយេស៊ូ
បានប្រាប់ឲ្យគេទៅ ។ [១៧]កាលគេបានឃើញព្រះអង្គ គេក្រាបថ្វាយបង្គំ ប៉ុន្តែ មានអ្នកខ្លះនៅសង្ស័យ ។
[១៨]ព្រះយេស៊ូយាងចូលមកជិតគេ ហើយមានព្រះបន្ទូលថា៖ «ខ្ញុំបានទទួលគ្រប់អំណាច ទាំងនៅស្ថាន
បរមសុខ ទាំងនៅលើផែនដី ។ [១៩]ដូច្នេះ ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ឲ្យធ្វើជាសាវ័ក ហើយ
ធ្វើពិធីជ្រមុជទឹកឲ្យគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។ [២០]ត្រូវបង្រៀនគេឲ្យ
ប្រតិបត្តិតាមសេចក្ដីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា ។ ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជា
រៀងរាល់ថ្ងៃ រហូតដល់អវសានកាលនៃពិភពលោក» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៧ ក្នុងរដូវបុណ្យចម្លង ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម យហ ១៤,១៨**

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះអម្ចាស់មិនបោលអ្នករាល់គ្នាឲ្យនៅកំព្រាឡើយ! ព្រះអង្គនឹងយាងមករកអ្នករាល់គ្នាវិញ ។ នៅពេលនោះ អ្នករាល់គ្នានឹងមានអំណរសប្បាយ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** **១៧,១-១១**

នៅពេលកំណត់ដែលព្រះយេស៊ូត្រូវឆ្លងពីលោកនេះឆ្ពោះទៅព្រះបិតា ព្រះអង្គងើបព្រះភ័ក្ត្រទតទៅ
លើមេឃ ហើយមានព្រះបន្ទូលថា៖ ១«បពិត្រព្រះបិតា! ឥឡូវនេះ ដល់ពេលកំណត់ហើយ សូមសំដែង
សិរីរុងរឿងរបស់បុត្រឡើង ដើម្បីឲ្យបុត្រសំដែងសិរីរុងរឿងរបស់ព្រះបិតាដែរ ។ ២ព្រះអង្គបានប្រទាន
ឲ្យបុត្រមានអំណាចលើមនុស្សទាំងអស់ ដើម្បីឲ្យបុត្រផ្តល់ជីវិតអស់កល្បជានិច្ច ដល់អស់អ្នក ដែលព្រះ
អង្គប្រទានមកបុត្រ ។ ៣រីឯជីវិតអស់កល្បជានិច្ចនោះ គឺឲ្យគេស្គាល់ព្រះអង្គ ដែលជាព្រះជាម្ចាស់ដ៏ពិត
តែមួយគត់ និងឲ្យគេស្គាល់ព្រះយេស៊ូគ្រីស្តដែលព្រះអង្គបាត់ឲ្យមក ។ ៤ទូលបង្គំបានសំដែង សិរីរុងរឿង
របស់ព្រះអង្គនៅលើផែនដី ហើយទូលបង្គំក៏បានបង្ហើយកិច្ចការ ដែលព្រះអង្គបញ្ជា ឲ្យទូលបង្គំធ្វើនោះ
ចប់សព្វគ្រប់ដែរ ។ ៥ឱព្រះបិតាអើយ! ឥឡូវនេះ សូមលើកតម្កើងទូលបង្គំឲ្យមានសិរីរុងរឿងនៅក្បែរ
ព្រះអង្គ គឺសិរីរុងរឿង ដែលទូលបង្គំធ្លាប់មាននៅក្បែរព្រះអង្គ តាំងពីមុនកំណើតពិភពលោកមក ។

៦ទូលបង្គំ បានសំដែងព្រះនាមរបស់ព្រះអង្គ ឲ្យអស់អ្នកដែលព្រះអង្គញែកចេញពីលោកនេះប្រទាន
មកទូលបង្គំស្គាល់ហើយ ។ អ្នកទាំងនោះនៅក្រោមការគ្រប់គ្រងរបស់ព្រះអង្គ ព្រះអង្គប្រទានគេមកឲ្យ
ទូលបង្គំ ហើយគេបានប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះអង្គ ។ ៧ឥឡូវនេះ អ្នកទាំងនោះដឹងថា អ្វីៗ ដែល
ព្រះអង្គប្រទានមកទូលបង្គំ សុទ្ធតែមកពីព្រះអង្គទាំងអស់ ៨ដ្បិតទូលបង្គំបានប្រគល់ព្រះបន្ទូលដែលព្រះ
អង្គប្រទានមកទូលបង្គំទៅឲ្យគេ គេបានទទួលព្រះបន្ទូលទាំងនោះ ហើយទទួលស្គាល់យ៉ាងច្បាស់ថា ទូល
បង្គំបានចេញមកពីព្រះអង្គមែន ព្រមទាំងជឿថា ព្រះអង្គបានចាត់ទូលបង្គំឲ្យមកទៀតផង ។

៩ទូលបង្គំ សូមអង្វរព្រះអង្គឲ្យអ្នកទាំងនោះ ទូលបង្គំមិនអង្វរព្រះអង្គឲ្យមនុស្សលោកឡើយ គឺអង្វរ
ឲ្យតែអស់អ្នក ដែលព្រះអង្គប្រទានមកទូលបង្គំប៉ុណ្ណោះ ព្រោះអ្នកទាំងនោះនៅក្រោមការគ្រប់គ្រង
របស់ព្រះអង្គ ។ ១០អ្វីៗជារបស់ព្រះអង្គ ក៏ជារបស់ទូលបង្គំ ហើយអ្វីៗជារបស់ទូលបង្គំ ក៏ជារបស់ព្រះអង្គ

ដែរ ។  ទូលបង្គំសំដែងសិរីរុងរឿងក្នុងអ្នកទាំងនោះ ។ ១១ទូលបង្គំមិននៅក្នុងលោកនេះទៀតទេ  រីឯអ្នក
ទាំងនោះ ស្ថិតនៅក្នុងលោកនៅឡើយ  ហើយទូលបង្គំទៅឯព្រះអង្គវិញ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# បុណ្យលើកតម្កើងព្រះវិញ្ញាណយាងមក ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ**

**អាលេលូយ៉ា! អាលេលូយ៉ា!** ឱ! ព្រះវិញ្ញាណដ៏វិសុទ្ធ! សូមយាងមក!
សូមជ្រួតជ្រាបចិត្តគំនិតអ្នកបម្រើព្រះអង្គ!
សូមប្រទានសេចក្ដីស្រឡាញ់របស់ព្រះអង្គឲ្យយើងខ្ញុំផង! ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** **២០,១៩-២៣**

ក្រោយពីព្រះយេស៊ូសោយទិវង្គត [១៩]នៅល្ងាចថ្ងៃអាទិត្យ ក្រុមសាវ័កនៅក្នុងផ្ទះខ្ទាស់ទ្វារយ៉ាងជាប់ ព្រោះខ្លាចជនជាតិយូដា ។ ស្រាប់តែព្រះយេស៊ូយាងមកឈរនៅកណ្ដាលចំណោមពួកគេ ហើយមានព្រះបន្ទូលថា៖ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្ត!» ។ [២០]ព្រះអង្គមានព្រះបន្ទូលដូច្នេះ ទាំងបង្ហាញស្នាមរបួសនៅព្រះហស្ត និងនៅត្រង់ឆ្អឹងជំនីរ ឲ្យគេឃើញផង ។ ក្រុមសាវ័កសប្បាយចិត្តជាខ្លាំងដោយបានឃើញព្រះអម្ចាស់ ។ [២១]ព្រះយេស៊ូមានព្រះបន្ទូលទៅគេសាជាថ្មីថា៖ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្ត! ដូចព្រះបិតាបានចាត់ខ្ញុំឲ្យមកយ៉ាងណា ខ្ញុំចាត់អ្នករាល់គ្នា ឲ្យទៅយ៉ាងនោះដែរ» ។

[២២]បន្ទាប់ពីមានព្រះបន្ទូលហើយ ព្រះអង្គផ្លុំលើពួកគេ ទាំងមានព្រះបន្ទូលថា៖ «ចូរទទួលព្រះវិញ្ញាណ! ។ [២៣]បើអ្នករាល់គ្នា លើកលែងទោសអ្នកណាឲ្យរួចពីបាប ព្រះជាម្ចាស់ក៏នឹងលើកលែងទោសអ្នកនោះឲ្យរួចពីបាបដែរ ។ ផ្ទុយទៅវិញ បើអ្នករាល់គ្នាប្រកាន់ទោសអ្នកណា អ្នកនោះមុខជាត្រូវជាប់ទោសមិនខាន» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# រដូវធម្មតា

# បុណ្យលើកតម្កើងព្រះត្រៃឯក ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម វវ ១,៨**

**អាលេលូយ៉ា! អាលេលូយ៉ា!** សូមលើកតម្កើងសិរីរុងរឿងនៃព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ គឺព្រះជាអម្ចាស់ដែលមានព្រះជន្មគង់នៅសព្វថ្ងៃ គង់នៅពីដើម ហើយកំពុងតែយាងមក ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** **៣,១៦-១៨**

[១៦]ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយ បានជាព្រះអង្គប្រទានព្រះបុត្រាតែ
មួយរបស់ព្រះអង្គមក ដើម្បីឲ្យអស់អ្នក ដែលជឿលើព្រះបុត្រា មានជីវិតអស់កល្បជានិច្ច គឺមិនឲ្យគេ
វិនាសឡើយ ។ [១៧]ព្រះជាម្ចាស់ចាត់ព្រះបុត្រារបស់ព្រះអង្គឲ្យយាងមកក្នុងលោកនេះ ពុំមែនដើម្បីដាក់
ទោសមនុស្សលោកទេ គឺដើម្បីសង្គ្រោះមនុស្សលោកដោយសារព្រះបុត្រាវិញ ។ [១៨]អ្នកជឿលើព្រះបុត្រា
មិនត្រូវទទួលទោសទេ រីឯអ្នកមិនជឿ ទទួលទោសរួចស្រេចទៅហើយ ព្រោះគេពុំបានជឿលើព្រះនាម
ព្រះបុត្រាតែមួយរបស់ព្រះជាម្ចាស់ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# បុណ្យព្រះកាយ និងព្រះលោហិត ដ៏វិសុទ្ធបំផុតរបស់ព្រះគ្រីស្ដ ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម យហ ៦,៥១-៥២

**អាលេលូយ៉ា! អាលេលូយ៉ា!** បពិត្រព្រះអម្ចាស់យេស៊ូ! ព្រះអង្គពិតជាអាហារ
ដែលផ្ដល់ជីវិត ចុះមកពីស្ថានបរមសុខ ។ អ្នកណាបរិភោគអាហារនេះ
នឹងរស់នៅអស់កល្បជានិច្ច ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** ៦,៥១-៥៨

ក្រោយពេលព្រះយេស៊ូបានចែកនំប៉័ងប្រាំដុំ និងត្រីពីរកន្ទុយមកចិញ្ចឹមមហាជន ព្រះអង្គមានព្រះបន្ទូលថា៖ «[៥១]ខ្ញុំនេះហើយជាអាហារ ដែលមានជីវិតចុះមកពីស្ថានបរមសុខ ។ អ្នកណាបរិភោគអាហារនេះ នឹងរស់នៅអស់កល្បជានិច្ច ។ អាហារដែលខ្ញុំនឹងឲ្យនោះ គឺខ្លួនខ្ញុំផ្ទាល់ដែលត្រូវបូជា សម្រាប់ឲ្យមនុស្សលោកមានជីវិត» ។

[៥២]ជនជាតិយូដាទាស់ទែងគ្នាយ៉ាងខ្លាំង ហើយគេនិយាយថា៖ «តើអ្នកនេះអាចឲ្យខ្លួនគាត់មកយើងបរិភោគដូចម្ដេចកើត? » ។

[៥៣] ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ប្រសិនបើអ្នករាល់គ្នាមិនពិសាសាច់ និងលោហិតរបស់បុត្រមនុស្សទេ អ្នករាល់គ្នាគ្មានជីវិតក្នុងខ្លួនឡើយ ។ [៥៤]អ្នកណាពិសាសាច់និងលោហិតរបស់ខ្ញុំ អ្នកនោះមានជីវិតអស់កល្បជានិច្ច ហើយខ្ញុំក៏នឹងប្រោសគេឲ្យមានជីវិតរស់ឡើងវិញ នៅថ្ងៃចុងក្រោយបំផុតផង ។ [៥៥]សាច់របស់ខ្ញុំជាអាហារដ៏ពិតប្រាកដ លោហិតរបស់ខ្ញុំក៏ជាភេសជ្ជៈដ៏ពិតប្រាកដដែរ ។ [៥៦]អ្នកណាពិសាសាច់និងលោហិតរបស់ខ្ញុំ អ្នកនោះស្ថិតនៅក្នុងខ្ញុំ ហើយខ្ញុំក៏ស្ថិតនៅក្នុងអ្នកនោះដែរ ។ [៥៧]ព្រះបិតា ដែលបានចាត់ខ្ញុំឲ្យមក ទ្រង់មានព្រះជន្មរស់ ហើយខ្ញុំមានជីវិតដោយសារព្រះអង្គយ៉ាងណា អ្នកបរិភោគខ្ញុំ ក៏នឹងមានជីវិតរស់ដោយសារខ្ញុំយ៉ាងនោះដែរ ។ [៥៨]អាហារដែលបានចុះពីស្ថានបរមសុខមក ខុសប្លែកពីអាហារ ដែលបុព្វបុរសរបស់អ្នករាល់គ្នាបានបរិភោគ ដ្បិតលោកទទួលមរណភាពអស់ទៅហើយ ។ រីឯអ្នកដែលបរិភោគអាហារនេះ នឹងរស់នៅអស់កល្បជានិច្ច» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** យហ ១,១៤.១២

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះបន្ទូលប្រសូតជាមនុស្ស ហើយគង់នៅក្នុងចំណោមយើង ។ អស់អ្នកដែលទទួលព្រះអង្គ ព្រះអង្គប្រទានឲ្យគេទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** ១,២៩-៣៤

[២៩]លោកយ៉ូហានបាទីស្ដឃើញព្រះយេស៊ូយាងតម្រង់មករកលោក លោកក៏មានប្រសាសន៍ថា៖
«មើលហ្ន៎ ! លោកនេះហើយជាកូនចៀមរបស់ព្រះជាម្ចាស់ ដែលដកបាបចេញពីពិភពលោក [៣០]គឺលោក
នេះហើយ ដែលខ្ញុំបានប្រាប់អ្នករាល់គ្នាថា "អ្នកដែលមកក្រោយខ្ញុំប្រសើរជាងខ្ញុំ ដ្បិតលោកមានជីវិត
មុនខ្ញុំ" ។ [៣១]កាលពីដើម ខ្ញុំពុំស្គាល់ឋានៈរបស់លោកទេ ប៉ុន្តែ ខ្ញុំមកធ្វើពិធីជ្រមុជក្នុងទឹក ដើម្បីឲ្យលោក
បង្ហាញខ្លួនឲ្យប្រជារាស្ត្រអ៊ីស្រាអែលស្គាល់» ។

[៣២]លោកយ៉ូហានបានផ្ដល់សក្ខីភាពថា៖ «ខ្ញុំបានឃើញព្រះវិញ្ញាណយាងចុះពីស្ថានបរមសុខ ដូចសត្វ
ព្រាប មកសណ្ឋិតលើលោក ។ [៣៣]ពីមុន ខ្ញុំពុំស្គាល់ឋានៈលោកទេ ប៉ុន្តែព្រះជាម្ចាស់ ដែលបានចាត់ខ្ញុំឲ្យ
មកធ្វើពិធីជ្រមុជក្នុងទឹក ទ្រង់មានព្រះបន្ទូលមកខ្ញុំថា "អ្នកឃើញព្រះវិញ្ញាណយាងចុះមកសណ្ឋិតលើ
អ្នកណា គឺអ្នកនោះហើយ ដែលធ្វើពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ" ។ [៣៤]ខ្ញុំឃើញដូច្នោះមែន ហើយ
ខ្ញុំសូមបញ្ជាក់ថា លោកនេះ ពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៣ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **លក ១,៦៨-៧៩**

**អាលេលូយ៉ា! អាលេលូយ៉ា!** សូមលើកតម្កើងព្រះអម្ចាស់ជាព្រះរបស់យើង! ព្រះអង្គសព្វព្រះហឫទ័យបាត់ពន្លឺឲ្យយាងមកបំភ្លឺអស់អ្នក ដែលស្ថិតនៅក្នុងភាពងងឹត ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **៤,១២-២៣ (ឬយ៉ាងខ្លី ៤,១២-១៧)**

[១២]កាលព្រះយេស៊ូជ្រាបដំណឹងថា គេបានចាប់លោកយ៉ូហានយកទៅឃុំឃាំងហើយ ព្រះអង្គក៏ភៀស
ចេញទៅស្រុកកាលីឡេ ។ [១៣]ព្រះអង្គចាកចេញពីភូមិណាសារ៉ែត ទៅស្នាក់នៅក្រុងកាផានុម ជិតមាត់
សមុទ្រ ក្នុងតំបន់សាប៊ូឡូន និងតំបន់ណែបថាលី [១៤]ដើម្បីអោយបានស្របនឹងសេចក្ដីដែលមានចែងទុក
តាមរយៈព្យាការីអេសាយថា៖ [១៥]*«ដែនដីសាប៊ូឡូន និងដែនដីណែបថាលី ដែលស្ថិតនៅតាមផ្លូវទៅកាន់
សមុទ្រអើយ ! ស្រុកខាងនាយទន្លេយ័រដាន់ ស្រុកកាលីឡេដែលសាសន៍ដទៃរស់នៅអើយ !* [១៦]*ប្រជា
ជនដែលអង្គុយនៅក្នុងទីងងឹត បានឃើញពន្លឺមួយដ៏ភ្លឺខ្លាំង ហើយមានពន្លឺមួយលេចឡើង បំភ្លឺអស់អ្នក
រស់ក្នុងស្រុកដែលស្ថិតនៅក្រោមអំណាចនៃសេចក្ដីស្លាប់»* ។
[១៧]តាំងពីគ្រានោះមក ព្រះយេស៊ូចាប់ផ្ដើមប្រកាសថា៖ «ចូរកែប្រែចិត្តគំនិត ដ្បិតព្រះរាជ្យនៃស្ថាន
បរមសុខនៅជិតបង្កើយហើយ ! » ។

[១៨]កាលព្រះអង្គយាងតាមឆ្នេរសមុទ្រកាលីឡេ ទ្រង់ទតឃើញបងប្អូនពីរនាក់ ជាអ្នកនេសាទ កំពុងតែ
បង់សំណាញ់ គឺលោកស៊ីម៉ូន ហៅសិលា និងលោកអន់ដ្រេ ជាប្អូនរបស់គាត់ ។ [១៩]ព្រះអង្គមានព្រះបន្ទូល
ទៅគេថា៖ «សូមអញ្ជើញមកតាមខ្ញុំ ខ្ញុំនឹងតាំងអ្នកអោយនេសាទមនុស្សវិញ» ។ [២០]អ្នកទាំងពីរក៏ទុក
សំណាញ់នៅទីនោះភ្លាម រួចដើរតាមព្រះអង្គទៅ ។

[២១]ព្រះយេស៊ូយាងទៅមុខឆ្ងាយបន្តិច ព្រះអង្គទតឃើញបងប្អូនពីរនាក់ទៀត គឺលោកយ៉ាកុប និង
លោកយ៉ូហាន ជាកូនរបស់លោកសេបេដេ កំពុងតែរៀបចំអួននៅក្នុងទូកជាមួយលោកសេបេដេ
ជាឪពុក ។ ព្រះអង្គក៏ត្រាស់ហៅអ្នកទាំងពីរ ។ [២២]អ្នកទាំងពីរចាកចោលទូក ចាកចោលឪពុកភ្លាម រួច
ដើរតាមព្រះយេស៊ូទៅ ។

[២៣]ព្រះយេស៊ូយាងកាត់ស្រុកកាលីឡេទាំងមូល ព្រះអង្គបង្រៀនអ្នកស្រុកនៅក្នុងធម្មសាលារបស់ពួក
គេ ព្រះអង្គប្រកាសដំណឹងល្អអំពីព្រះរាជ្យ និងប្រោសអ្នកជំងឺគ្រប់យ៉ាង មនុស្សពិការគ្រប់ប្រភេទ ក្នុង
ចំណោមប្រជាជនឲ្យបានជាផង ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៤ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **មថ ៥,១-១២**

**អាលេលូយ៉ា! អាលេលូយ៉ា!** ចូរអរសប្បាយរីករាយឡើង! ព្រោះអ្នករាល់គ្នានឹងទទួលរង្វាន់យ៉ាងធំនៅស្ថានបរមសុខ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **៥,១-១២**

១ព្រះយេស៊ូទតឃើញមហាជនទាំងនេះ ព្រះអង្គយាងឡើងទៅលើភ្នំ រួចព្រះអង្គគង់នៅទីនោះ ។ សាវ័កនាំគ្នាចូលមកគាល់ព្រះអង្គ ២ព្រះអង្គក៏មានព្រះបន្ទូលបង្រៀនគេថា៖

៣«អ្នកណាដាក់ចិត្តជាអ្នកក្រខ្សត់ អ្នកនោះមានសុភមង្គល! ដ្បិតពួកគេបានទទួលព្រះរាជ្យនៃស្ថានបរមសុខហើយ

៤អ្នកណាសោកសៅ អ្នកនោះមានសុភមង្គល! ដ្បិតព្រះជាម្ចាស់នឹងសំរាលទុក្ខពួកគេ!

៥អ្នកណាមានចិត្តស្លូតបូត អ្នកនោះមានសុភមង្គលហើយ! ដ្បិតពួកគេនឹងទទួលទឹកដីទុកជាមត៌ក!

៦អ្នកណាស្រេកឃ្លានសេចក្ដីសុចរិត អ្នកនោះមានសុភមង្គលហើយ! ដ្បិតព្រះជាម្ចាស់នឹងប្រទានឲ្យពួកគេបានឆ្អែត!

៧អ្នកណាមានចិត្តមេត្តាករុណា អ្នកនោះមានសុភមង្គលហើយ! ដ្បិតព្រះជាម្ចាស់នឹងសម្តែងព្រះហឫទ័យមេត្តាករុណាដល់ពួកគេវិញ!

៨អ្នកណាមានចិត្តបរិសុទ្ធ អ្នកនោះមានសុភមង្គលហើយ! ដ្បិតពួកគេនឹងឃើញព្រះជាម្ចាស់!

៩អ្នកណាកសាងសន្តិភាព អ្នកនោះមានសុភមង្គលហើយ! ដ្បិតពួកគេនឹងមានឈ្មោះជាបុត្ររបស់ព្រះជាម្ចាស់!

១០អ្នកណាត្រូវគេបៀតបៀន ព្រោះតែបានធ្វើតាមសេចក្ដីសុចរិត អ្នកនោះមានសុភមង្គល! ដ្បិតគេបានទទួលព្រះរាជ្យនៃស្ថានបរមសុខហើយ!

១១ប្រសិនបើមានគេត្មះតិះដៀល បៀតបៀន និងមានគេនិយាយអាក្រក់គ្រប់យ៉ាង បង្ខូចឈ្មោះអ្នករាល់គ្នា ព្រោះតែខ្ញុំ នោះអ្នករាល់គ្នាមានសុភមង្គលហើយ! 
១២ចូរអរសប្បាយរីករាយឡើង! ព្រោះអ្នករាល់គ្នានឹងទទួលរង្វាន់យ៉ាងធំនៅស្ថានបរមសុខ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៥ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** យហ ៨,១២

**អាលេលូយ៉ា! អាលេលូយ៉ា!** បពិត្រព្រះយេស៊ូគ្រីស្ត! ព្រះអង្គជាពន្លឺបំភ្លឺពិភពលោក! ។
អ្នកណាទៅតាមព្រះអង្គ អ្នកនោះមិនដើរក្នុងភាពងងឹតឡើយ គឺគេមានពន្លឺនាំគេទៅកាន់ជីវិត ។
**អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** ៥,១៣-១៦

នៅគ្រានោះ ក្រុមសាវ័កជួបជុំជាមួយព្រះយេស៊ូនៅលើភ្នំ ។ ព្រះអង្គមានព្រះបន្ទូលទៅកាន់ពួកគេ
ថា៖ [១៣]«អ្នករាល់គ្នាជាអំបិលសំរាប់មនុស្សលោក! ប៉ុន្តែ ប្រសិនបើអំបិលបាត់ជាតិប្រៃហើយ តើគេនឹង
យកអ្វីមកធ្វើឲ្យប្រៃឡើងវិញបាន? ។ អំបិលនោះគ្មានប្រយោជន៍អ្វីទៀតទេ គឺមានតែបោះបោលទៅ
ខាងក្រៅ ឲ្យមនុស្សដើរជាន់ប៉ុណ្ណោះ ។ [១៤]អ្នករាល់គ្នាជាពន្លឺ សម្រាប់បំភ្លឺមនុស្សលោក ។ គេមិនអាច
លាក់បំបាំងក្រុងណា ដែលសង់នៅលើភ្នំបានឡើយ ។ [១៥]គេមិនដែលអុជចង្កៀង ហើយយកធុងគ្របពី
លើនោះទេ គឺគេតែងយកចង្កៀងទៅដាក់លើជើងចង្កៀងវិញ ហើយចង្កៀងនោះបំភ្លឺអស់អ្នកដែលនៅ
ក្នុងផ្ទះ ។ [១៦]ចូរឲ្យពន្លឺរបស់អ្នករាល់គ្នា បំភ្លឺមនុស្សទាំងឡាយដូច្នោះដែរ ។ គេនឹងឃើញអំពើល្អ ដែល
អ្នករាល់គ្នាប្រព្រឹត្ត ហើយនាំគ្នាលើកតម្កើងសិរីរុងរឿងព្រះបិតារបស់អ្នករាល់គ្នាដែលគង់នៅស្ថានបរម
សុខ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៦ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ**

**អាលេលូយ៉ា! អាលេលូយ៉ា!** ធម្មវិន័យនៃព្រះអម្ចាស់ ធ្វើឲ្យមនុស្សមានចិត្តត្រេកអរសប្បាយ ធម្មវិន័យជាពន្លឺបំភ្លឺភ្នែកមនុស្ស ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **៥,១៧-៣៧**

**(ឬយ៉ាងខ្លី ៥,២០-២២.២៧-២៨.៣៣-៣៤.៣៧)**

នៅគ្រានោះ ក្រុមសាវ័កជួបជុំជាមួយព្រះយេស៊ូនៅលើភ្នំ ។ ព្រះអង្គមានព្រះបន្ទូលទៅកាន់ពួកគេ
ថា៖

[១៧]«សុំកុំនឹកស្មានថា ខ្ញុំមកលុបបំបាត់គម្ពីរវិន័យ ឬគម្ពីរព្យាការីចោលឡើយ ។ ខ្ញុំមិនមែនមកលុប
បំបាត់ទេ គឺខ្ញុំមកធ្វើឲ្យគម្ពីរមានអត្ថន័យពេញលក្ខណៈទៅវិញ ។ [១៨]ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា
ដរាបណាផ្ទៃមេឃនិងផែនដីនៅស្ថិតស្ថេរ ដរាបនោះគ្មានក្បៀស ឬបន្តក់ណាមួយក្នុងគម្ពីរវិន័យ ត្រូវ
រលុបបាត់ឡើយ គឺគម្ពីរទាំងមូលនឹងនៅស្ថិតស្ថេររហូតដល់ទីបំផុត ។ [១៩]អ្នកណាល្មើសនឹងបញ្ញត្តិតូចមួយ
នេះ ហើយបង្រៀនអ្នកផ្សេងឲ្យធ្វើតាម អ្នកនោះនឹងមានឋានៈតូចជាងគេ ក្នុងព្រះរាជ្យនៃស្ថានបរម
សុខ ។ ផ្ទុយទៅវិញ អ្នកណាប្រតិបត្តិតាមវិន័យ ហើយបង្រៀនអ្នកផ្សេងឲ្យប្រតិបត្តិតាម អ្នកនោះនឹង
មានឋានៈធំក្នុងព្រះរាជ្យនៃស្ថានបរមសុខ ។

[២០]ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា បើសេចក្តីសុចរិតរបស់អ្នករាល់គ្នា មិនប្រសើរជាងសេចក្តី
សុចរិតរបស់ពួកធម្មាចារ្យ និងពួកខាងផារីស៊ីទេ អ្នករាល់គ្នាពុំអាចចូលទៅក្នុងព្រះរាជ្យនៃស្ថានបរមសុខ
បានឡើយ ។ [២១]អ្នករាល់គ្នាធ្លាប់ឮសេចក្តីដែលមានថ្លែងប្រាប់បុព្វបុរសថា “កុំសម្លាប់មនុស្ស អ្នកណា
សម្លាប់គេ អ្នកនោះនឹងត្រូវគេផ្តន្ទាទោស” ។ [២២]រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា អ្នកណាខឹង
នឹងបងប្អូន អ្នកនោះនឹងត្រូវគេផ្តន្ទាទោសដែរ ។

អ្នកណាជេរប្រទេចផ្តាសាបងប្អូន អ្នកនោះនឹងត្រូវក្រុមប្រឹក្សាជាន់ខ្ពស់កាត់ទោស ហើយអ្នកណាត្មះ
តិះដៀលគេ អ្នកនោះនឹងត្រូវគេផ្តន្ទាទោស ធ្លាក់ក្នុងភ្លើងនរកអវិចី ។ [២៣]ដូច្នេះ កាលណាអ្នកយកតង្វាយ
ទៅថ្វាយព្រះជាម្ចាស់ ហើយនៅទីនោះ អ្នកនឹកឃើញថា បងប្អូនណាម្នាក់មានទំនាស់នឹងអ្នក [២៤]ចូរទុក
តង្វាយរបស់អ្នកនៅកន្លែងថ្វាយតង្វាយ ហើយទៅស្រុះស្រួលនឹងបងប្អូនរបស់អ្នកជាមុនសិន រួចសឹមវិល
មកថ្វាយតង្វាយរបស់អ្នកវិញ ។ [២៥]កាលណាអ្នកធ្វើដំណើរទៅតុលាការជាមួយគូវិវាទរបស់អ្នក ចូរស្រុះ
ស្រួលជាមួយអ្នកនោះជាប្រញាប់ ក្រែងលោគេបញ្ជូនអ្នកទៅចៅក្រម ចៅក្រមបញ្ជូនអ្នកទៅនគរបាល

ហើយអ្នកត្រូវជាប់គុក ។ [២៦]ខ្ញុំសុំប្រាប់ឲ្យអ្នកដឹងច្បាស់ថា ដរាបណាអ្នកមិនបានបង់ប្រាក់ពិន័យគ្រប់
ចំនួន ឥតខ្វះមួយសេនទេនោះ អ្នកនឹងមិនរួចខ្លួនឡើយ ។

[២៧]អ្នករាល់គ្នាធ្លាប់ឮសេចក្ដីថ្លែងទុកមកថា "កុំប្រព្រឹត្តអំពើផិតក្បត់" ។ [២៨]រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់
ប្រាប់អ្នករាល់គ្នាថា អ្នកណាមើលស្ត្រីម្នាក់ ហើយមានចិត្តស្រើបស្រាលចង់រួមបវេណីជាមួយនាង អ្នក
នោះដូចជាបានប្រព្រឹត្តអំពើផិតក្បត់ជាមួយនាង នៅក្នុងចិត្តរបស់ខ្លួនរួចស្រេចទៅហើយ ។

[២៩]ប្រសិនបើភ្នែកស្ដាំរបស់អ្នកនាំអ្នកឲ្យប្រព្រឹត្តអំពើបាប ចូរខ្វេះចេញ ហើយបោះចោលឲ្យឆ្ងាយពី
អ្នកទៅ! បើអ្នកបាត់ភ្នែកតែមួយនេះ ប្រសើរជាងបណ្ដោយឲ្យរូបកាយទាំងមូលធ្លាក់ទៅក្នុងនរក ។
[៣០]ប្រសិនបើដៃស្ដាំរបស់អ្នកនាំអ្នកឲ្យប្រព្រឹត្តអំពើបាប ចូរកាត់វា ហើយបោះចោលឲ្យឆ្ងាយពីអ្នកទៅ!
បើអ្នកបាត់តែអវយវៈមួយនេះ ប្រសើរជាងបណ្ដោយឲ្យរូបកាយទាំងមូលធ្លាក់ទៅក្នុងនរក ។ [៣១]មាន
សេចក្ដីថ្លែងទុកមកថា "បុរសណាលែងភរិយា ត្រូវធ្វើលិខិតលែងលះឲ្យនាង" [៣២]រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់
ប្រាប់អ្នករាល់គ្នាថា បុរសណាលែងភរិយារបស់ខ្លួន (លើកលែងតែរួមរស់ជាមួយគ្នា ដោយឥតបានរៀប
ការ) ប្រសិនបើនាងរៀបការម្ដងទៀត បុរសនោះធ្វើឲ្យនាងទៅជាស្ត្រីផិតក្បត់ ។ រីឯបុរសណារៀបការ
នឹងស្ត្រីប្ដីលែង បុរសនោះក៏ប្រព្រឹត្តអំពើផិតក្បត់ដែរ» ។

[៣៣]អ្នករាល់គ្នាធ្លាប់បានឮសេចក្ដីដែលមានថ្លែងប្រាប់បុព្វបុរសថា៖ "កុំបំភ្លេចពាក្យសម្បថចោល
ឡើយ ។ ត្រូវតែធ្វើតាមគ្រប់ពាក្យដែលអ្នកបានស្បថនឹងព្រះអម្ចាស់" ។ [៣៤]រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់ប្រាប់
អ្នករាល់គ្នាថា កុំស្បថឲ្យសោះ!

កុំស្បថដោយយកមេឃជាសាក្សីឡើយ ព្រោះមេឃជាបល្ល័ង្ករបស់ព្រះជាម្ចាស់ [៣៥]ក៏កុំស្បថដោយ
យកផែនដីជាសាក្សីដែរ ព្រោះផែនដីជាកំណល់ទ្រព្រះបាទារបស់ព្រះអង្គ ។ កុំស្បថដោយយកក្រុងយេ
រូសាឡឹមជាសាក្សី ព្រោះយេរូសាឡឹមជាក្រុងរបស់ព្រះមហាក្សត្រដ៏ឧត្ដម ។ [៣៦]កុំស្បថដោយយកក្បាល
អ្នកជាសាក្សី ព្រោះអ្នកពុំអាចធ្វើឲ្យសក់របស់អ្នកទៅជាស ឬខ្មៅបានឡើយ សូម្បីតែមួយសរសៃក៏ពុំបាន
ផង ។

[៣៧]ត្រូវនិយាយឲ្យទៀងទាត់ បើ "មែន" ឲ្យប្រាកដជា "មែន" បើ "ទេ" ឲ្យប្រាកដជា "ទេ" ។
រីឯពាក្យពន្លើស សុទ្ធតែមកពីមារកំណាចទាំងអស់» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៧ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម យហ ១៣,៣៤**

**អាលេលូយ៉ា! អាលេលូយ៉ា!** អ្នកដែលកាន់តាមព្រះបន្ទូលរបស់ព្រះគ្រីស្ត
អ្នកនោះស្គាល់សេចក្តីស្រឡាញ់ ដ៏គ្រប់លក្ខណៈរបស់ព្រះជាម្ចាស់មែន ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **៥,៣៨-៤៨**

នៅគ្រានោះ ក្រុមសាវ័កជួបជុំជាមួយព្រះយេស៊ូនៅលើភ្នំ ។ ព្រះអង្គមានព្រះបន្ទូលទៅកាន់ពួកគេ
ថា៖ ៣៨«អ្នករាល់គ្នាធ្លាប់បានឮសេចក្ដីថ្លែងទុកមកថា “ប្រសិនបើគេវាយភ្នែកអ្នកម្ខាង ត្រូវវាយភ្នែក
គេម្ខាងវិញ ប្រសិនបើគេវាយអ្នកបាក់ធ្មេញមួយ ក៏ត្រូវវាយគេឲ្យបាក់ធ្មេញតែមួយដែរ” ។ ៣៩រីឯខ្ញុំ
វិញ ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា កុំតបតនឹងមនុស្សកំណាចឲ្យសោះ បើមានគេទះកំផ្លៀងស្ដាំរបស់
អ្នក ចូរបែរឲ្យគេទះម្ខាងទៀតទៅ ។ ៤០បើមានគេប្ដឹងចង់បានអាវក្នុងរបស់អ្នក ចូរឲ្យគេយកអាវធំថែម
ទៀតទៅ ។ ៤១បើមានគេបង្ខំអ្នកឲ្យធ្វើដំណើរមួយយោជន៍ ចូរទៅពីរយោជន៍ជាមួយគេចុះ ។ ៤២អ្នក
ណាសុំអ្វីពីអ្នក ចូរឲ្យគេទៅ ហើយក៏កុំគេចមុខចេញពីអ្នកដែលសុំខ្ចីអ្វីៗពីអ្នកដែរ ។

៤៣អ្នករាល់គ្នាធ្លាប់បានឮសេចក្ដីថ្លែងទុកមកថា “ចូរស្រឡាញ់បងប្អូនឯទៀតៗ ហើយស្អប់ខ្មាំងសត្រូវ
របស់អ្នក” ។ ៤៤រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា ចូរស្រឡាញ់ខ្មាំងសត្រូវរបស់អ្នករាល់គ្នា ព្រម
ទាំងទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរឲ្យអស់អ្នកដែលបៀតបៀនអ្នករាល់គ្នាផង ។ ៤៥ធ្វើ
ដូច្នេះ អ្នករាល់គ្នានឹងទៅជាបុត្រធីតារបស់ព្រះបិតា ដែលគង់នៅស្ថានបរមសុខ ដ្បិតព្រះអង្គប្រទានឲ្យ
ព្រះអាទិត្យរបស់ព្រះអង្គរះបំភ្លឺ ទាំងមនុស្សអាក្រក់ ទាំងមនុស្សល្អ ហើយទ្រង់ប្រទានទឹកភ្លៀងឲ្យ ទាំង
មនុស្សសុចរិត ទាំងមនុស្សទុច្ចរិតផងដែរ ។ ៤៦ប្រសិនបើអ្នករាល់គ្នាស្រឡាញ់តែអស់អ្នកដែលស្រឡាញ់
អ្នករាល់គ្នា តើនឹងទទួលរង្វាន់អ្វី? សូម្បីតែអ្នកទារពន្ធ ក៏ចេះស្រឡាញ់គ្នាគេដែរ ។ ៤៧បើអ្នករាល់គ្នា
រាប់រកតែបងប្អូនរបស់ខ្លួនប៉ុណ្ណោះ តើមានអ្វីអស្ចារ្យ? សូម្បីតែសាសន៍ដទៃក៏ប្រព្រឹត្តដូច្នោះដែរ ។
៤៨ព្រះបិតារបស់អ្នករាល់គ្នា ដែលគង់នៅស្ថានបរមសុខ ទ្រង់គ្រប់លក្ខណ៍យ៉ាងណា សុំឲ្យអ្នករាល់គ្នាបាន
គ្រប់លក្ខណ៍យ៉ាងនោះដែរ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៨ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** មថ ៤,១២

**អាលេលូយ៉ា! អាលេលូយ៉ា!** ចូរស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ជាមុនសិន
ទើបព្រះអង្គប្រទានរបស់ទាំងអស់មកអ្នករាល់គ្នាថែមទៀត ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាតាយ** ៦,២៤-៣៤

នៅគ្រានោះ ក្រុមសាវ័កជួបជុំជាមួយព្រះយេស៊ូនៅលើភ្នំ ។ ព្រះអង្គមានព្រះបន្ទូលទៅកាន់ពួកគេ
ថា៖ [២៤]«គ្មានអ្នកណាម្នាក់អាចបម្រើម្ចាស់ពីរបានទេ ព្រោះអ្នកនោះនឹងស្រឡាញ់ម្នាក់ខ្លាំងជាងម្នាក់
ទៀត យកចិត្តទុកដាក់បម្រើម្នាក់ ច្រើនជាងម្នាក់ទៀតជាពុំខាន ។ អ្នករាល់គ្នាក៏ពុំអាចគោរពបម្រើ
ព្រះជាម្ចាស់ផង ហើយគោរពបម្រើទ្រព្យសម្បត្តិ ទុកជាព្រះផងបានឡើយ ។

[២៥]ហេតុនេះហើយ បានជាខ្ញុំសុំប្រាប់អ្នករាល់គ្នា កុំឲ្យខ្វល់ខ្វាយអំពីម្ហូបអាហារសម្រាប់ចិញ្ចឹមជីវិត ឬ
សម្លៀកបំពាក់សម្រាប់បិទបាំងកាយឡើយ ។ ជីវិតមានតម្លៃ លើសម្ហូបអាហារ ហើយរូបកាយក៏មាន
តម្លៃ លើសសម្លៀកបំពាក់ទៅទៀត ។ [២៦]ចូររំពៃមើលបក្សាបក្សីនៅលើមេឃ វាមិនដែលសាបព្រោះ
មិនដែលច្រូតកាត់ មិនដែលប្រមូលស្រូវដាក់ជង្រុកឡើយ ប៉ុន្តែ ព្រះបិតារបស់អ្នករាល់គ្នាដែលគង់នៅ
ស្ថានបរមសុខទ្រង់ចិញ្ចឹមវា ។ រីឯអ្នករាល់គ្នា អ្នករាល់គ្នាមានតម្លៃលើសបក្សាបក្សីទាំងនោះទៅទៀត ។
[២៧]ក្នុងចំណោមអ្នករាល់គ្នា ទោះបីខំខ្វល់ខ្វាយយ៉ាងណាក៏ដោយ ក៏គ្មាននរណាអាចនឹងបង្កើនអាយុរបស់
ខ្លួនឲ្យវែងបានដែរ សូម្បីតែបន្តិចក៏មិនបានផង ។

[២៨]ហេតុដូចម្ដេច បានជាអ្នករាល់គ្នាខ្វល់ខ្វាយអំពីសម្លៀកបំពាក់? ចូរសង្កេតមើលផ្កានៅតាម
វាល ។ វាមិនដែលធ្វើការនឿយហត់ ឬត្បាញរវៃឡើយ [២៩]ប៉ុន្តែ ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា សូម្បីតែ
ព្រះបាទសាឡូម៉ូន កាលពីជំនាន់ ដែលទ្រង់មានសិរីរុងរឿងដ៏ប្រសើរបំផុតនោះ ក៏ដោយក៏ទ្រង់គ្មានព្រះ
ភូសាល្អស្មើនឹងផ្កាមួយទងនេះផង ។ [៣០]មនុស្សមានជំនឿតិចអើយ! ប្រសិនបើព្រះជាម្ចាស់ផ្តល់សម្រស់ឲ្យ
ផ្កា ដែលរីកនៅតាមវាលថ្ងៃនេះ តែថ្ងៃស្អែកត្រូវគេដុតបោលយ៉ាងហ្នឹងទៅហើយ តើព្រះអង្គនឹងទំនុក
បម្រុងអ្នករាល់គ្នាលើសនេះយ៉ាងណាទៅទៀត? ។ [៣១]ហេតុនេះ កុំខ្វល់ខ្វាយដោយពោលថា "យើង
នឹងមានអ្វីបរិភោគ? មានអ្វីស្លៀកពាក់?" នោះឡើយ [៣២]ដ្បិតមានតែសាសន៍ដទៃប៉ុណ្ណោះទេ ដែលខំ
ស្វះស្វែងរករបស់ទាំងនោះ ។ រីឯព្រះបិតាដែលគង់នៅស្ថានបរមសុខ ទ្រង់ជ្រាបនូវអ្វីៗដែលអ្នករាល់គ្នា

ត្រូវការ ។ ៣៣ចូរស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ និងសេចក្ដីសុចរិតរបស់ព្រះអង្គជាមុនសិន ទើបព្រះអង្គប្រទានរបស់ទាំងនោះមកអ្នករាល់គ្នាថែមទៀត ។ ៣៤កុំខ្វល់ខ្វាយអំពីហេតុការណ៍ ដែលនឹងកើតមាននៅថ្ងៃស្អែកឡើយ ចាំស្អែកសឹមគិតពីរឿងថ្ងៃស្អែកទៅ! បើមានការលំបាកកើតឡើងនៅថ្ងៃណា ត្រូវដោះស្រាយសម្រាប់តែថ្ងៃនោះបានហើយ! » ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៩ ក្នុងរដូវធម្មតា ឆ្នាំ ក

### ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ

**អាលេលូយ៉ា! អាលេលូយ៉ា!** សូមអញ្ជើញមក! ចូរស្រែកច្រៀងដោយអំណរថ្វាយព្រះអម្ចាស់ ដែលជាថ្មដា និងជាព្រះសង្គ្រោះរបស់យើង! ព្រះអង្គពិតជាព្រះរបស់យើងមែន! ។

**អាលេលូយ៉ា!**

### ✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ ៧,២១-២៧

នៅគ្រានោះ ក្រុមសាវ័កជួបជុំជាមួយព្រះយេស៊ូនៅលើភ្នំ ។ ព្រះអង្គមានព្រះបន្ទូលទៅកាន់ពួកគេ
ថា៖ [២១]«អ្នកដែលចូលទៅក្នុងព្រះរាជ្យនៃស្ថានបរមសុខ មិនមែនជាអ្នកដែលគ្រាន់តែហៅខ្ញុំថា “ព្រះ
អម្ចាស់! ព្រះអម្ចាស់!” ប៉ុណ្ណោះទេ គឺជាអ្នកដែលធ្វើតាមព្រះហឫទ័យរបស់ព្រះបិតាខ្ញុំ ដែលគង់នៅ
ស្ថានបរមសុខនោះវិញ ។ [២២]នៅថ្ងៃនោះ នឹងមានមនុស្សជាច្រើន ពោលមកខ្ញុំថា “ព្រះអម្ចាស់! ព្រះ
អម្ចាស់អើយ! យើងខ្ញុំធ្លាប់ថ្លែងព្រះបន្ទូលក្នុងព្រះនាមព្រះអង្គ យើងខ្ញុំធ្លាប់ដេញខ្មោចក្នុងព្រះនាមព្រះ
អង្គ យើងខ្ញុំក៏ធ្លាប់ធ្វើការអស្ចារ្យជាច្រើន ក្នុងព្រះនាមព្រះអង្គដែរ” ។ [២៣]ពេលនោះ ខ្ញុំនឹងប្រកាសប្រាប់
អ្នករាល់គ្នាថា “ពួកអ្នកប្រព្រឹត្តអំពើទុច្ចរិតអើយ! ចូរថយចេញអោយឆ្ងាយពីខ្ញុំទៅ! ខ្ញុំមិនដែលស្គាល់
អ្នករាល់គ្នាទេ!” ។

[២៤]អ្នកណាស្ដាប់ពាក្យខ្ញុំនេះ ហើយប្រព្រឹត្តតាម អ្នកនោះប្រៀបបានទៅនឹងមនុស្សឈ្លាសវៃម្នាក់
ដែលបានសង់ផ្ទះរបស់ខ្លួននៅលើផ្ទាំងថ្ម ។ [២៥]ទោះបីភ្លៀងបង្អុរចុះមក មានទឹកជន់ មានខ្យល់បក់បោក
ប៉ះនឹងផ្ទះនោះយ៉ាងណាក៏ដោយ ក៏ផ្ទះនោះមិនរលំដែរ ព្រោះមានគ្រឹះនៅលើផ្ទាំងថ្ម ។ [២៦]រីឯអ្នកដែល
ស្ដាប់ពាក្យខ្ញុំនេះ តែមិនប្រព្រឹត្តតាម ប្រៀបបានទៅនឹងមនុស្សឥតប្រាជ្ញាម្នាក់ ដែលបានសង់ផ្ទះរបស់ខ្លួន
នៅលើដីខ្សាច់ ។ [២៧]ពេលភ្លៀងបង្អុរចុះមក មានទឹកជន់ មានខ្យល់បក់បោកប៉ះនឹងផ្ទះនោះ ផ្ទះនោះរលំ
បាក់បែកខ្ទេចអស់ គ្មានសល់» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១០ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** ទន ១៣០,៧

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះអម្ចាស់មានព្រះហឫទ័យមេត្តាករុណា
ព្រះអង្គរំដោះយើងឲ្យរួចពីអំពើបាប ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** ៩,៩-១៣

[៩]ព្រះយេស៊ូយាងចេញពីក្រុងកាផានុម ព្រះអង្គទតឃើញបុរសម្នាក់ឈ្មោះម៉ាថាយ អង្គុយនៅកន្លែង
យកពន្ធ ។ ព្រះអង្គមានព្រះបន្ទូលទៅគាត់ថា៖ «សុំអញ្ជើញមកតាមខ្ញុំ» ។ គាត់ក៏ក្រោកឡើង ដើរតាម
ព្រះអង្គទៅ ។

[១០] បន្ទាប់មក ព្រះអង្គសោយព្រះស្ងោយនៅផ្ទះលោកម៉ាថាយ ។ មានអ្នកទារពន្ធ ព្រមទាំងមនុស្ស
បាបជាច្រើន មកអង្គុយរួមតុជាមួយព្រះយេស៊ូនិងក្រុមសាវ័កដែរ ។ [១១]ពួកខាងគណៈផារីស៊ីឃើញដូច្នេះ
គេនិយាយទៅកាន់សាវ័ករបស់ព្រះអង្គថា៖ «ហេតុអ្វី បានជាគ្រូរបស់អ្នករាល់គ្នា បរិភោគជាមួយអ្នក
ទារពន្ធ និងមនុស្សបាប?» ។ [១២]ព្រះយេស៊ូឮដូច្នេះ ក៏មានព្រះបន្ទូលថា៖ «មនុស្សមានសុខភាពល្អមិន
ត្រូវការគ្រូពេទ្យទេ មានតែអ្នកជំងឺប៉ុណ្ណោះដែលត្រូវការ ។ [១៣]ចូរអ្នករាល់គ្នាទៅរិះគិតមើល សេចក្ដី
ដែលមានចែងទុកមកថា៖ "យើងមិនចង់បានយញ្ញបូជាទេ គឺចង់បានតែសេចក្ដីមេត្តាករុណាប៉ុណ្ណោះ"
មានន័យដូចម្ដេច? ខ្ញុំមិនមែនមករកមនុស្សសុចរិតទេ គឺមករកមនុស្សបាបវិញ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១១ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **មក ១,១៥**

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះរាជ្យរបស់ព្រះជាម្ចាស់មកជិតបង្កើយហើយ ។
ចូរជឿដំណឹងល្អចុះ! ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **៩,៣៦-១០,៨**

[៣៦]ព្រះយេស៊ូទតឃើញមហាជន ព្រះអង្គមានព្រះហឫទ័យអាណិតអាសូរគេពន់ពេកណាស់ ព្រោះ
អ្នកទាំងនោះអស់កម្លាំងល្វើយ ធ្លាក់ទឹកចិត្ត ប្រៀបបីដូចជាចៀមដែលគ្មានគង្វាលថែទាំ ។ [៣៧]ព្រះអង្គ
មានព្រះបន្ទូលទៅកាន់ក្រុមសាវ័កថា៖ «ស្រូវដែលត្រូវប្រូតមានច្រើនណាស់ តែអ្នកប្រូតមានតិច
ពេក ។ [៣៨]ហេតុនេះ ចូរអង្វរម្ចាស់ស្រែអោយចាត់អ្នកប្រូតមកក្នុងស្រែរបស់លោក» ។

១០ [១]ព្រះយេស៊ូត្រាស់ហៅក្រុមសាវ័កដប់ពីរនាក់មក ព្រះអង្គប្រទានឲ្យគេមានអំណាចដេញខ្មោច
ព្រមទាំងមានអំណាចប្រោសអ្នកជំងឺគ្រប់យ៉ាង និងអ្នកពិការគ្រប់ប្រភេទឲ្យបានជាផង ។ [២]ទូតទាំងដប់
ពីររបស់ព្រះអង្គមាននាមដូចតទៅនេះ អ្នកទីមួយ គឺស៊ីម៉ូន ហៅសិលា និងអន់ទ្រេ ជាប្អូនរបស់គាត់
យ៉ាកុប និងយ៉ូហានជាប្អូនរបស់គាត់ ដែលត្រូវជាកូនរបស់លោកសេបេដេ [៣]ភីលីព និងបារថូឡូមេ
ថូម៉ាស់ និងម៉ាថាយ ជាអ្នកទារពន្ធ យ៉ាកុប ជាកូនរបស់លោកអាល់ផាយ និងថាដេ [៤]ស៊ីម៉ូន ជាអ្នកជាតិ
និយម និងយូដាអ៊ីស្ការីយ៉ុត ជាអ្នកក្បត់ព្រះអង្គ ។

[៥]ព្រះយេស៊ូចាត់ក្រុមសាវ័កទាំងដប់ពីរនាក់នេះ ឲ្យទៅដោយផ្ដែផ្ដាំថា៖ «កុំទៅរកសាសន៍ដទៃ
ឡើយ! ហើយក៏កុំចូលទៅក្នុងភូមិរបស់ជនជាតិសាម៉ារីដែរ [៦]គឺត្រូវទៅស្វែងរកអស់ជនជាតិអ៊ីស្រាអែល
ដែលវង្វេងនោះវិញ ។ [៧]ពេលធ្វើដំណើរទៅ ចូរប្រកាសថា ព្រះរាជ្យនៃស្ថានបរមសុខមកជិតបង្កើយ
ហើយ! ។ [៨]ចូរមើលអ្នកជំងឺឲ្យបានជា ប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ ធ្វើឲ្យមនុស្សឃ្លង់បានជាស្អាត
បរិសុទ្ធ ដេញខ្មោចចេញពីមនុស្ស ។ អ្នករាល់គ្នាបានទទួលអំណាចដោយឥតបង់ថ្លៃ ត្រូវជួយគេវិញ
ដោយឥតគិតថ្លៃដែរ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១២ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម យហ ១៥,២៦.២៧**

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះវិញ្ញាណដែលសម្ដែងសេចក្ដីពិត ធ្វើជាសាក្សីក្នុងចិត្តអ្នករាល់គ្នា! ចូរអ្នករាល់គ្នាធ្វើជាសាក្សីអំពីព្រះគ្រីស្តនៅចំពោះមុខមនុស្សដែរ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **១០,២៦-៣៣**

ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ក្រុមសាវ័កទាំងដប់ពីរនាក់ថា៖ [២៦]«កុំខ្លាចពួកមនុស្សឡើយ ដ្បិត
ការលាក់កំបាំងទាំងអស់ នឹងត្រូវបើកឲ្យគេឃើញ ហើយអាថ៌កំបាំងទាំងប៉ុន្មាន ក៏នឹងត្រូវបើកឲ្យគេដឹង
ដែរ ។ [២៧]អ្វីៗដែលខ្ញុំនិយាយប្រាប់អ្នករាល់គ្នាក្នុងទីងងឹត ចូរយកទៅនិយាយនៅក្នុងពន្លឺថ្ងៃ ហើយអ្វីៗ
ដែលគេខ្សឹបដាក់ត្រចៀក ចូរយកទៅប្រកាសនៅពីលើផ្ទះ ។ [២៨]កុំខ្លាចអស់អ្នក ដែលសម្លាប់បានត្រឹម
តែរូបកាយ តែពុំអាចសម្លាប់ព្រលឹងបាននោះឲ្យសោះ គឺត្រូវខ្លាចព្រះជាម្ចាស់វិញ ព្រោះព្រះអង្គអាចធ្វើ
ឲ្យទាំងព្រលឹង ទាំងរូបកាយ ធ្លាក់ទៅក្នុងភ្លើងនរកបាន ។ [២៩]ធម្មតាគេលក់ចាបពីរ ថ្លៃមួយសេន ។ ទោះ
បីថោកយ៉ាងនេះក៏ដោយ ប្រសិនបើព្រះបិតារបស់អ្នករាល់គ្នាមិនយល់ព្រមទេនោះ ក៏គ្មានចាបណាមួយ
ធ្លាក់ចុះដល់ដីបានឡើយ ។ [៣០]រីឯអ្នករាល់គ្នាវិញ សូម្បីតែសក់នៅលើក្បាលអ្នករាល់គ្នា ក៏ព្រះអង្គរាប់
អស់ដែរ ។ [៣១]ដូច្នេះ ចូរអ្នករាល់គ្នាកុំខ្លាចអ្វីឡើយ ព្រោះអ្នករាល់គ្នាមានតម្លៃលើសចាបទាំងអស់ទៅ
ទៀត ។

[៣២]អ្នកណាទទួលស្គាល់ខ្ញុំ នៅចំពោះមុខមនុស្សលោក ខ្ញុំក៏នឹងទទួលស្គាល់អ្នកនោះវិញ នៅចំពោះព្រះ
ភក្ត្រព្រះបិតារបស់ខ្ញុំ ដែលគង់នៅស្ថានបរមសុខ ។ [៣៣]រីឯអ្នកណាបដិសេធមិនទទួលស្គាល់ខ្ញុំនៅចំពោះ
មុខមនុស្សលោក ខ្ញុំក៏នឹងបដិសេធមិនទទួលស្គាល់អ្នកនោះ នៅចំពោះព្រះភក្ត្រព្រះបិតារបស់ខ្ញុំ ដែលគង់
នៅស្ថានបរមសុខដែរ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១៣ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម ១ សល ២,៩**

**អាលេលូយ៉ា! អាលេលូយ៉ា!** ប្រជាជនដែលព្រះជាម្ចាស់បានជ្រើសរើសជាប្រជារាស្ត្ររបស់ព្រះមហាក្សត្រ ចូរប្រកាសដំណឹងអំពីស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះអង្គ ដែលត្រាស់ហៅបងប្អូនឲ្យចេញពីទីងងឹត មកកាន់ពន្លឺរុងរឿងរបស់ព្រះអង្គ ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **១០,៣៧-៤២**

ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ក្រុមសាវ័កថា៖ [៣៧]«អ្នកណាស្រឡាញ់ឪពុកម្ដាយ ខ្លាំងជាង
ស្រឡាញ់ខ្ញុំ អ្នកនោះមិនសមនឹងធ្វើជាសាវ័ករបស់ខ្ញុំឡើយ ហើយអ្នកដែលស្រឡាញ់កូនប្រុស កូនស្រី
របស់ខ្លួន ខ្លាំងជាងស្រឡាញ់ខ្ញុំ ក៏មិនសមនឹងធ្វើជាសាវ័ករបស់ខ្ញុំដែរ ។ [៣៨]អ្នកណាមិនយកឈើឆ្កាងរបស់
ខ្លួន ហើយមិនមកតាមខ្ញុំទេ អ្នកនោះមិនសមធ្វើជាសាវ័ករបស់ខ្ញុំឡើយ ។ [៣៩]អ្នកណាចង់រក្សាទុកជីវិត
របស់ខ្លួន អ្នកនោះនឹងបាត់បង់ជីវិត រីឯអ្នកដែលបាត់បង់ជីវិតព្រោះតែខ្ញុំ នឹងបានជីវិតនោះមកវិញ ។
[៤០]អ្នកណាទទួលអ្នករាល់គ្នា ក៏ដូចជាទទួលខ្ញុំ ហើយអ្នកណាទទួលខ្ញុំ ក៏ដូចជាទទួលព្រះអង្គ ដែល
បាត់ខ្ញុំឲ្យមកនោះដែរ ។ [៤១]អ្នកណាទទួលព្យាការីម្នាក់ ក្នុងនាមលោកជាព្យាការី អ្នកនោះនឹងទទួលរង្វាន់
ដូចព្យាការី ។ អ្នកណាទទួលមនុស្សសុចរិតម្នាក់ ក្នុងនាមជាមនុស្សសុចរិត អ្នកនោះនឹងទទួលរង្វាន់ដូច
មនុស្សសុចរិត ។ [៤២]អ្នកណាឲ្យទឹកត្រជាក់ សូម្បីតែមួយកែវ ដល់អ្នកតូចតាចម្នាក់ ក្នុងនាមជាសាវ័ក
របស់ខ្ញុំ ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នកនោះនឹងទទួលរង្វាន់ជាមិនខាន» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១៤ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម មថ ១១,២៥**

**អាលេលូយ៉ា! អាលេលូយ៉ា!** បពិត្រព្រះបិតាជាអម្ចាស់នៃពិភព! យើងខ្ញុំសូមលើកតម្កើង
ព្រះអង្គ ព្រោះទ្រង់បានសម្ដែងការអស្ចារ្យនៃព្រះរាជ្យឲ្យមនុស្សតូចតាចស្គាល់ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **១១,២៥-៣០**

[២៥]នៅពេលនោះ ព្រះយេស៊ូមានព្រះបន្ទូលឡើងថា៖ «បពិត្រព្រះបិតា ជាអម្ចាស់នៃស្ថានបរមសុខ
និងជាអម្ចាស់នៃផែនដី ទូលបង្គំសូមសរសើរតម្កើងព្រះអង្គ ព្រោះទ្រង់បានសម្ដែងការអាថ៌កំបាំងនៃព្រះ
រាជ្យឲ្យមនុស្សតូចតាចយល់ តែទ្រង់បានលាក់មិនឲ្យអ្នកប្រាជ្ញ និងអ្នកចេះដឹងយល់ទេ ។ [២៦]មែនហើយ!
ព្រះអង្គសព្វព្រះហឫទ័យសំរេចដូច្នេះ ។

[២៧]ព្រះបិតារបស់ខ្ញុំ បានប្រគល់អ្វីៗទាំងអស់មកខ្ញុំ គ្មានអ្នកណាស្គាល់ព្រះបុត្រា ក្រៅពីព្រះបិតា
ហើយក៏គ្មាននរណាស្គាល់ព្រះបិតា ក្រៅពីព្រះបុត្រា និងអ្នកដែលព្រះបុត្រាសព្វព្រះហឫទ័យសំដែងឲ្យ
ស្គាល់នោះដែរ ។

[២៨]អស់អ្នកដែលនឿយហត់ និងលីបន្ទុកធ្ងន់អើយ! ចូរមករកខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាបានសម្រាក ។
[២៩]ចូរយកនឹមរបស់ខ្ញុំ ដាក់លើអ្នករាល់គ្នា ហើយរៀនពីខ្ញុំទៅ ដ្បិតខ្ញុំស្លូត និងមានចិត្តសុភាព អ្នករាល់គ្នា
មុខជាបានស្ងប់ចិត្តមិនខាន ។ [៣០]នឹមរបស់ខ្ញុំស្រួល ហើយបន្ទុកដែលខ្ញុំដាក់លើអ្នករាល់គ្នា ក៏ស្រាល
ដែរ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១៥ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម មថ ១៣,៨.២៣**

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះគ្រីស្តចេញទៅព្រោះដំណឹងល្អ ។ អ្នកណាទទួលព្រះបន្ទូល
ហើយធ្វើឲ្យព្រះបន្ទូលបង្កើតផល អ្នកនោះពិតជាមានសុភមង្គលហើយ! **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **១៣,១-២៣ (ឬយ៉ាងខ្លី ១៣,១-៩)**

១នៅគ្រានោះ ព្រះយេស៊ូចាកចេញពីផ្ទះ យាងទៅគង់នៅមាត់សមុទ្រ ។ ២មានមហាជនច្រើនកុះករ
មកចោមរោមព្រះអង្គ ព្រះអង្គក៏យាងចុះទៅគង់ក្នុងទូកមួយ រីឯបណ្ដាជនឈរនៅមាត់ច្រាំង ។ ៣ព្រះ
អង្គមានព្រះបន្ទូលទៅគេយ៉ាងច្រើន ដោយប្រើពាក្យប្រស្នាដូចតទៅ៖ «មានអ្នកសាបព្រោះម្នាក់ចេញ
ទៅព្រោះស្រូវពូជ ។ ៤ពេលគាត់ព្រោះ មានគ្រាប់ពូជខ្លះ ធ្លាក់ទៅលើផ្លូវ ហើយសត្វមកចឹកស៊ីអស់ទៅ ។
៥មានគ្រាប់ពូជខ្លះទៀត ធ្លាក់ទៅលើកន្លែងមានថ្ម ពុំសូវមានដី ។ គ្រាប់ពូជក៏ដុះឡើងភ្លាម ព្រោះដីមិន
ជ្រៅ ។ ៦លុះដល់ថ្ងៃក្ដៅឡើង ពន្លកទាំងនោះក្រៀមស្វិតអស់ទៅ ព្រោះឫសចាក់មិនបានជ្រៅ ។ ៧គ្រាប់
ពូជខ្លះទៀត ធ្លាក់ទៅលើដីមានបន្លា ។ បន្លាក៏ដុះឡើងរួបរឹតស្រូវ មិនឲ្យដុះបានឡើយ ។ ៨គ្រាប់ពូជខ្លះ
ទៀត ធ្លាក់ទៅលើដីមានដីជាតិល្អ មួយគ្រាប់ឲ្យផលជាមួយរយគ្រាប់ មួយទៀតឲ្យហុកសិប និងមួយ
ទៀតឲ្យសាមសិប ។ ៩អស់អ្នកដែលឮពាក្យនេះ សូមយកទៅពិចារណាចុះ» ។

១០ពេលនោះ ក្រុមសាវ័កនាំគ្នាចូលមកជិតព្រះអង្គ ហើយទូលសួរថា៖ «ហេតុដូចម្ដេចបានជាព្រះគ្រូ
មានព្រះបន្ទូលទៅកាន់បណ្ដាជន ដោយប្រើពាក្យប្រស្នាដូច្នេះ?» ។ ១១ព្រះអង្គតបទៅគេវិញថា៖
«មកពីព្រះជាម្ចាស់បានប្រោសប្រទានឲ្យអ្នករាល់គ្នាយល់ គម្រោងការដ៏លាក់កំបាំងរបស់ព្រះរាជ្យនៃ
ស្ថានបរមសុខ រីឯអ្នកដទៃវិញ ព្រះអង្គមិនប្រទានឲ្យយល់ឡើយ ។ ១២អ្នកណាមានហើយ ព្រះជាម្ចាស់
នឹងប្រទានថែមទៀត ដើម្បីឲ្យអ្នកនោះបានបរិបូណ៌ រីឯអ្នកដែលគ្មាន ព្រះអង្គនឹងហូតយកអ្វីដែលអ្នក
នោះមានផង ។ ១៣ហេតុនេះហើយ បានជាខ្ញុំនិយាយទៅគេ ដោយប្រើពាក្យប្រស្នា គឺទោះបីគេមើល គេ
ក៏ពុំឃើញ ទោះបីគេស្ដាប់ គេក៏ពុំឮ ហើយក៏ពុំយល់ដែរ ។ ១៤ហេតុការណ៍នេះ កើតដល់គេស្របនឹង
សេចក្ដី ដែលព្យាការីអេសាយថ្លែងទុកថា៖ "*អ្នករាល់គ្នាស្ដាប់មែន តែពុំឮទេ ហើយក៏ពុំយល់ផង ។ អ្នក*
*រាល់គ្នាមើលមែន តែមិនឃើញសោះ ១៥ដ្បិតចិត្តប្រជារាស្ត្រនេះរឹងណាស់ ហើយត្រចៀកគេក៏ធ្ងន់ ។ គេ*

*នាំគ្នាបិទភ្នែក មិនឲ្យមើលឃើញ មិនឲ្យត្រចៀកស្ដាប់ឮ មិនឲ្យប្រាជ្ញាយល់ ហើយមិនចង់វិលមកវិញទេ ក្រែងលោយើងប្រោសគេឲ្យបានជា”* ។

[16]រីឯអ្នករាល់គ្នាវិញ អ្នករាល់គ្នាមានសុភមង្គលហើយ ព្រោះភ្នែកអ្នករាល់គ្នាមើលឃើញ ត្រចៀកអ្នករាល់គ្នាស្ដាប់ឮ ។ [17]ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ព្យាការីនិងមនុស្សសុចរិតជាច្រើន មានបំណងចង់ឃើញហេតុការណ៍ ដែលអ្នករាល់គ្នាឃើញនេះដែរ តែមិនបានឃើញទេ គេចង់ឮសេចក្ដីដែលអ្នករាល់គ្នាឮនេះដែរ តែមិនបានឮឡើយ! ។

[18]ដូច្នេះ សុំស្ដាប់អត្ថន័យនៃប្រស្នាអំពីអ្នកព្រោះស្រូវដូចតទៅ៖ [19]អ្នកដែលបានឮព្រះបន្ទូលអំពីព្រះរាជ្យតែមិនយល់ ប្រៀបបាននឹងអ្នកដែលទទួលគ្រាប់ពូជនៅតាមផ្លូវ ហើយមារកំណាចមកឆក់យកព្រះបន្ទូលដែលបានធ្លាក់ក្នុងចិត្តគេនោះទៅ ។ [20]រីឯអ្នកដែលទទួលគ្រាប់ពូជលើដីមានថ្ម គឺអស់អ្នកដែលឮព្រះបន្ទូលហើយ ក៏ទទួលយកភ្លាមដោយអំណរ [21]ប៉ុន្តែ គេពុំបានទុកឲ្យព្រះបន្ទូលចាក់ឫសនៅក្នុងខ្លួនគេឡើយ គេជាប់ចិត្តតែមួយភ្លែតប៉ុណ្ណោះ លុះដល់មានទុក្ខលំបាក ឬត្រូវគេបៀតបៀនព្រោះតែព្រះបន្ទូល គេក៏បោះបង់បោលជំនឿភ្លាម ។ [22]អ្នកដែលទទួលគ្រាប់ពូជក្នុងដីមានបន្លា គឺអ្នកដែលបានឮព្រះបន្ទូល ប៉ុន្តែ ការខ្វល់ខ្វាយអំពីជីវិតក្នុងលោកីយ៍ ចិត្តលោភលន់ចង់បានទ្រព្យសម្បត្តិ រួបរឹតព្រះបន្ទូលមិនឲ្យបង្កើតផលបានឡើយ ។ [23]រីឯអ្នកដែលទទួលគ្រាប់ពូជក្នុងដីមានជីជាតិល្អ គឺអស់អ្នកដែលបានឮព្រះបន្ទូល ហើយយល់ ។ គេបង្កបង្កើតផល ខ្លះបានមួយជាមួយរយ ខ្លះបានមួយជាហុកសិប និងខ្លះទៀតបានមួយជាសាមសិប» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១៦ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម មថ ១១,២៥**

**អាលេលូយ៉ា! អាលេលូយ៉ា!** បពិត្រព្រះបិតា ជាអម្ចាស់នៃពិភព យើងខ្ញុំសូមលើកតម្កើងព្រះអង្គ ព្រោះទ្រង់បានសម្ដែងការអស្ចារ្យនៃព្រះរាជ្យព្រះអង្គ ឲ្យមនុស្សតូចតាចស្គាល់ ។
**អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **១៣,២៤-៤៣ (ឬយ៉ាងខ្លី ១៣,២៤-៣០)**

[២៤]ព្រះយេស៊ូមានព្រះបន្ទូលជាពាក្យប្រស្នាទៅគេថា៖ «ព្រះរាជ្យនៃស្ថានបរមសុខប្រៀបបាននឹង
បុរសម្នាក់ ដែលបានព្រោះគ្រាប់ពូជល្អទៅក្នុងស្រែរបស់គាត់ ។ [២៥]ពេលមនុស្សម្នាដេកលក់អស់ មារ
សត្រូវរបស់គាត់មកព្រោះស្រងែនៅក្នុងស្រែនោះ រួចចេញបាត់ទៅ ។ [២៦]ពេលស្រូវដុះឡើងដាក់គ្រាប់
ស្រងែក៏ដុះឡើងដែរ ។ [២៧]ពួកអ្នកបម្រើចូលមកជម្រាបម្ចាស់ស្រែថា៖ "លោកម្ចាស់! លោកបានព្រោះ
តែគ្រាប់ពូជល្អក្នុងស្រែសោះ ចុះស្រងែនេះមកពីណា?" ។ [២៨]ម្ចាស់តបវិញថា៖ "ពិតជាមានមារសត្រូវ
មកព្រោះហើយ!" ។ ពួកអ្នកបម្រើសួរលោកទៀតថា៖ "តើលោកចង់ឲ្យយើងខ្ញុំទៅដកស្រងែនោះ
ចេញឬ?" ។ [២៩]ម្ចាស់តបថា៖ "កុំអី! បើអ្នករាល់គ្នាដក ក្រែងលោដោយស្រូវមកជាមួយដែរ [៣០]ទុក
ឲ្យវាដុះជាមួយគ្នារហូតដល់ស្រូវទុំចុះ ពេលនោះ ខ្ញុំនឹងប្រាប់ពួកអ្នកច្រូតថា ចូរប្រមូលស្រងែចងជាបាច់
យកទៅដុតចោលជាមុនសិន រួចសឹមប្រមូលស្រូវដាក់ជង្រុកឲ្យខ្ញុំ"» ។

[៣១]ព្រះយេស៊ូមានព្រះបន្ទូលជាពាក្យប្រស្នាមួយទៀតទៅគេថា៖ «ព្រះរាជ្យនៃស្ថានបរមសុខ ប្រៀប
បីដូចជាគ្រាប់ពូជម្យ៉ាងដ៏ល្អិត ដែលបុរសម្នាក់យកទៅដាំក្នុងចំការរបស់ខ្លួន ។ [៣២]គ្រាប់ពូជនោះតូចជាង
គ្រាប់ពូជទាំងអស់ ប៉ុន្តែ ពេលដុះឡើង វាធំជាងដំណាំឯទៀតៗ គឺទៅជាដើមឈើមួយយ៉ាងធំ ហើយ
បក្សាបក្សីមកធ្វើសំបុកស្នាក់អាស្រ័យនៅតាមមែករបស់វា» ។

[៣៣]ព្រះអង្គមានព្រះបន្ទូលជាពាក្យប្រស្នាមួយទៀតថា៖ «ព្រះរាជ្យនៃស្ថានបរមសុខ ប្រៀបបីដូចជា
មេនំប៉័ងដែលស្ត្រីម្នាក់យកទៅលាយនឹងម្សៅពីរតៅ ធ្វើឲ្យម្សៅនោះដោរឡើង» ។

[៣៤]ព្រះយេស៊ូមានព្រះបន្ទូលអំពីសេចក្ដីទាំងនេះ ទៅកាន់មហាជនជាពាក្យប្រស្នាទាំងអស់ គឺព្រះអង្គ
មិនដែលមានព្រះបន្ទូលទៅគេ ដោយឥតប្រើពាក្យប្រស្នាឡើយ [៣៥]ដើម្បីឲ្យស្របនឹងសេចក្ដីដែលមាន

ចែងទុកដោយសារពួកព្យាការីថា៖ *«យើងនឹងនិយាយទៅគេជាពាក្យប្រស្នា យើងនឹងប្រកាសសេចក្ដី
លាក់កំបាំង តាំងពីដើមកំណើតពិភពលោក មកឲ្យគេដឹង»* ។

[៣៦]ពេលនោះ ព្រះយេស៊ូយាងចេញពីមហាជនចូលទៅក្នុងផ្ទះ ។ ក្រុមសាវ័កនាំគ្នាចូលមកគាល់
ព្រះអង្គទូលថា៖ «សូមព្រះគ្រូបកស្រាយប្រស្នាអំពីស្រងែក្នុងស្រែ ឲ្យយើងខ្ញុំបានយល់អត្ថន័យផង» ។
[៣៧]ព្រះអង្គមានព្រះបន្ទូលតបទៅគេវិញថា៖ «អ្នកព្រោះគ្រាប់ពូជល្អ គឺបុត្រមនុស្ស [៣៨]ស្រែ គឺពិភព
លោក គ្រាប់ពូជល្អ គឺអ្នកដែលត្រូវចូលទៅក្នុងព្រះរាជ្យ រីឯស្រងែវិញ គឺកូនចៅរបស់មារកំណាច
[៣៩]សត្រូវដែលសាបព្រោះស្រងែ គឺមារ រដូវចម្រូត គឺអវសានកាលនៃពិភពលោក ហើយអ្នកច្រូត គឺទេវ
ទូត ។ [៤០]គេច្រូតស្រងែយកទៅដុតក្នុងភ្លើងយ៉ាងណា នៅអវសានកាលនៃពិភពលោក ក៏នឹងកើតមាន
យ៉ាងនោះដែរ ។ [៤១]បុត្រមនុស្សនឹងចាត់ទេវទូតរបស់លោកឲ្យមក ។ ទេវទូតទាំងនោះនឹងប្រមូលពួកអ្នក
ដែលនាំគេឲ្យប្រព្រឹត្តអំពើបាប និងពួកអ្នកដែលបានប្រព្រឹត្តអំពើទុច្ចរិត យកចេញពីព្រះរាជ្យ [៤២]បោះ
ទៅក្នុងភ្លើងដែលឆេះសន្ធោសន្ធៅ ហើយនៅទីនោះមានតែសម្រែកយំសោក ខឹង សង្កៀតធ្មេញ ។
[៤៣]រីឯអ្នកសុចរិតវិញ គេនឹងស្ថិតនៅក្នុងព្រះរាជ្យនៃព្រះបិតារបស់គេ ទាំងបញ្ចេញរស្មី គេភ្លឺដូចព្រះ
អាទិត្យ ។ អ្នកណាឮពាក្យនេះ សូមយកទៅពិចារណាចុះ! » ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១៧ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម មថ ១១,២៥

**អាលេលូយ៉ា! អាលេលូយ៉ា!** បពិត្រព្រះបិតាជាអម្ចាស់នៃពិភពទាំងមូល! យើងខ្ញុំសូមលើកតម្កើងព្រះអង្គ ព្រោះទ្រង់បានសម្តែងការអស្ចារ្យនៃព្រះរាជ្យឲ្យមនុស្សតូចតាចស្គាល់! ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** ១៣,៤៤-៥២ (ឬយ៉ាងខ្លី ១៣,៤៤-៤៦)

ព្រះយេស៊ូមានព្រះបន្ទូលមកកាន់បណ្តាជន ជាពាក្យប្រស្នាថា៖ [៤៤]«ព្រះរាជ្យស្ថានបរមសុខ ប្រៀប
បីដូចជាកំណប់ ដែលគេកប់ទុកនៅក្នុងស្រែមួយ ។ មានបុរសម្នាក់រកកំណប់នោះឃើញ ហើយកប់ទុក
វិញ ។ គាត់មានចិត្តត្រេកអរជាខ្លាំង ក៏ចេញទៅលក់អ្វីៗទាំងប៉ុន្មានដែលគាត់មាន យកប្រាក់ទិញដីស្រែ
នោះ ។

[៤៥]ម្យ៉ាងទៀត ព្រះរាជ្យនៃស្ថានបរមសុខប្រៀបបីដូចជាអ្នកជំនួញម្នាក់ ដែលស្វែងរកទិញពេជ្រ
ល្អៗ ។ [៤៦]កាលបានឃើញពេជ្រមួយគ្រាប់ដ៏មានតម្លៃលើសលប់ហើយ គាត់ក៏ទៅលក់អ្វីៗទាំងប៉ុន្មាន
ដែលគាត់មាន យកប្រាក់មកទិញពេជ្រនោះ ។

[៤៧]ព្រះរាជ្យនៃស្ថានបរមសុខ ក៏ប្រៀបបីដូចជាអួនមួយដែលគេរាយក្នុងសមុទ្រ ហើយជាប់បានត្រី
គ្រប់យ៉ាង ។ [៤៨]ពេលជាប់បានត្រីពេញហើយ គេអូសអួននោះឡើងមកលើគោក រួចអង្គុយរើសត្រីល្អៗ
ដាក់ក្នុងកញ្ជ្រោល រីឯត្រីមិនល្អវិញ គេបោះបោល ។ [៤៩]នៅអវសានកាលនៃពិភពលោក ក៏នឹងកើតមាន
ដូច្នេះដែរ ។ ពួកទេវទូតនាំគ្នាមកញែកមនុស្សទុច្ចរិត ចេញពីចំណោមមនុស្សសុចរិត [៥០]រួចបោះមនុស្ស
ទុច្ចរិតទាំងនោះទៅក្នុងភ្លើងដែលឆេះ សន្ធោសន្ធៅ ។ នៅទីនោះ មានតែសម្រែកយំសោក ខឹងសង្កៀត
ធ្មេញ ។

[៥១]តើអ្នករាល់គ្នាយល់សេចក្តីទាំងនេះឬទេ?» ក្រុមសាវ័កទូលព្រះអង្គថា៖ «បាទ យល់!» ។

[៥២]ព្រះអង្គមានព្រះបន្ទូលទៅគេទៀតថា៖ «ហេតុនេះហើយ បានជាពួកធម្មាចារ្យ ដែលបានទទួល
ការអប់រំអំពីព្រះរាជ្យនៃស្ថានបរមសុខ ប្រៀបបានទៅនឹងម្ចាស់ផ្ទះ ដែលយកទ្រព្យទាំងចាស់ ទាំងថ្មី
ចេញពីឃ្លាំងរបស់គាត់» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១៨ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម ទន ៧៨,៣៤**

**អាលេលូយ៉ា! អាលេលូយ៉ា!** នៅវាលរហោស្ថាន ព្រះអម្ចាស់ប្រទានអាហារឲ្យ
ប្រជារាស្ត្រព្រះអង្គ ។ ព្រះអង្គបានប្រទានអាហារនៃស្ថានបរមសុខឲ្យគេ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **១៤,១៣-២១**

១៣កាលព្រះយេស៊ូយាងចុះទូក ចាកចេញជាមួយក្រុមសាវ័ក ឆ្ពោះទៅកាន់កន្លែងមួយស្ងាត់ដាច់ឡែក
ពីបណ្ដាជន ។ ប៉ុន្តែ មហាជនបានដឹង ហើយនាំគ្នាចេញពីក្រុងនានា ដើរទៅតាមព្រះអង្គ ។ ១៤កាលព្រះ
យេស៊ូយាងឡើងពីទូក ព្រះអង្គទតឃើញមហាជនដ៏ច្រើនយ៉ាងនេះ ទ្រង់មានព្រះហឫទ័យអាណិតអាសូរ
គេពន់ពេកណាស់ ព្រះអង្គក៏ប្រោសអ្នកជំងឺឲ្យបានជា ។

១៥ពេលនោះ ថ្ងៃជ្រេណាស់ហើយ សាវ័កនាំគ្នាចូលមកជិតព្រះអង្គ ហើយទូលថា៖ «ទីនេះស្ងាត់
ណាស់ ហើយក៏ជិតយប់ផង សូមប្រាប់បណ្ដាជនទាំងនេះឲ្យត្រឡប់ទៅវិញ រកទិញម្ហូបអាហារនៅតាម
ភូមិ» ។ ១៦ប៉ុន្តែ ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់សាវ័កថា៖ «មិនបាច់ឲ្យគេត្រឡប់ទៅវិញទេ ចូរអ្នក
រាល់គ្នាយកម្ហូបអាហារឲ្យគេបរិភោគទៅ» ។ ១៧សាវ័កទូលព្រះអង្គថា៖ «យើងខ្ញុំមាននំប៉័ងតែប្រាំដុំ
និងត្រីងៀតពីរកន្ទុយប៉ុណ្ណោះ» ។ ១៨ព្រះអង្គមានព្រះបន្ទូលថា៖ «ចូរយកនំប៉័ងនិងត្រីនោះមកឲ្យខ្ញុំ» ។
១៩បន្ទាប់មក ព្រះអង្គប្រាប់បណ្ដាជនឲ្យអង្គុយលើស្មៅ ព្រះអង្គយកនំប៉័ងទាំងប្រាំដុំ និងត្រីពីរកន្ទុយនោះ
មកកាន់ ទ្រង់ងើបព្រះភក្ត្រឡើងលើ លើកតម្កើងព្រះជាម្ចាស់ ហើយកាច់នំប៉័ងប្រទានឲ្យក្រុមសាវ័ក
ក្រុមសាវ័កក៏ចែកឲ្យបណ្ដាជនបរិភោគ ។ ២០អ្នកទាំងនោះបានបរិភោគឆ្អែតគ្រប់ៗគ្នា ហើយក្រុមសាវ័ក
ប្រមូលនំប៉័ងដែលនៅសល់ ដាក់បានពេញជប់ពីរល្អី ។ ២១អស់អ្នកដែលបានបរិភោគនំប៉័ង មានប្រុសៗ
ទាំងអស់ប្រមាណប្រាំពាន់នាក់ ឥតគិតស្រីៗនិងក្មេងៗផងទេ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១៩ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម ទន ៦២,៣ ; ១៨,១៧**

**អាលេលូយ៉ា! អាលេលូយ៉ា!** មានតែព្រះជាម្ចាស់មួយព្រះអង្គទេ ជាថ្មដាដែលសង្គ្រោះខ្ញុំ! ព្រះអង្គលាតព្រះហស្តពីស្ថានបរមសុខមករកខ្ញុំ ព្រះអង្គស្រង់ខ្ញុំចេញឲ្យផុតពីទឹកសមុទ្រ ។
**អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **១៤,២២-៣៣**

ព្រះយេស៊ូបានចែកអាហារឲ្យបណ្ដាជនក្នុងវាលរហោស្ថាន ។ [២២]ក្រោយមក ព្រះអង្គបង្ខំក្រុមសាវ័ក
ឲ្យចុះទូកឆ្លងទៅត្រើយម្ខាងភ្លាមមុនព្រះអង្គ ហើយព្រះអង្គក៏ប្រាប់មហាជនឲ្យវិលត្រឡប់ទៅវិញដែរ ។
[២៣]កាលព្រះអង្គឲ្យមហាជនចេញផុតអស់ហើយ ព្រះអង្គយាងឡើងទៅលើភ្នំដាច់ឡែកពីគេ ដើម្បីអធិ
ដ្ឋាន ។ លុះដល់យប់ ព្រះយេស៊ូគង់នៅទីនោះតែមួយព្រះអង្គឯង ។

[២៤]ពេលនោះ ទូកចេញឆ្ងាយពីច្រាំង ហើយក៏ត្រូវរលកបក់បោក ព្រោះបញ្ច្រាសខ្យល់ ។ [២៥]ដល់ពេល
ជិតភ្លឺ ព្រះអង្គយាងលើទឹក ឆ្ពោះទៅរកក្រុមសាវ័ក ។ [២៦]កាលពួកគេឃើញព្រះអង្គយាងលើទឹកសមុទ្រ
ដូច្នេះ គេភ័យរន្ធត់ ហើយស្រែកឡើងថា៖ «ខ្មោចលង!» ព្រោះគេភ័យពេក ។ [២៧]រំពេចនោះ ព្រះ
យេស៊ូមានព្រះបន្ទូលទៅគេថា៖ «ចូរតាំងចិត្តក្លាហានឡើង! ខ្ញុំទេតើ! កុំខ្លាចអី!» ។ [២៨]លោកសិលា
ទូលព្រះអង្គថា៖ «ព្រះអម្ចាស់! ប្រសិនបើពិតជាព្រះអង្គមែន សូមបញ្ជាឲ្យខ្ញុំអាចដើរលើទឹកទៅរកព្រះ
អង្គផង» ។ [២៩]ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «អញ្ជើញមក!» ។ លោកសិលាក៏ចុះពីទូក ដើរ
លើទឹកឆ្ពោះទៅរកព្រះយេស៊ូ ។ [៣០]ប៉ុន្តែ កាលលោកឃើញខ្យល់បក់ខ្លាំង លោកភ័យណាស់ ហើយចាប់
ផ្ដើមលិចទៅក្នុងទឹក ។ លោកស្រែកឡើងថា៖ «លោកម្ចាស់អើយ! សូមជួយខ្ញុំផង!» ។ [៣១]ព្រះយេស៊ូក៏
លូកព្រះហស្តទាញគាត់ឡើងភ្លាម ទាំងមានព្រះបន្ទូលថា៖ «មនុស្សមានជំនឿតិចអើយ! ហេតុដូចម្ដេច
បានជាអ្នកមិនទុកចិត្តដូច្នេះ?» ។ [៣២]បន្ទាប់មក ព្រះអង្គនិងលោកសិលាចូលមកក្នុងទូក ហើយខ្យល់ក៏
ស្ងប់ ។ [៣៣]អ្នកនៅក្នុងទូកនាំគ្នាក្រាបថ្វាយបង្គំព្រះអង្គ ទាំងពោលថា៖ «ព្រះអង្គពិតជាព្រះបុត្រារបស់
ព្រះជាម្ចាស់មែន!» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២០ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម ទន ១៤៦,៥.៨-៩**

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះអម្ចាស់រំដោះអ្នកដែលត្រូវគេជិះជាន់ ព្រះអង្គការពារជនបរទេស! ។ អស់អ្នកដែលផ្ញើជីវិតលើព្រះអង្គ ពិតជាបានសុភមង្គល! ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **១៥,២១-២៨**

[២១]ព្រះយេស៊ូយាងទៅកាន់តំបន់ជិតក្រុងទីរ៉ូស និងក្រុងស៊ីដូន ។ [២២]មានស្ត្រីសាសន៍កាណានម្នាក់
ដែលរស់នៅស្រុកនោះ ចូលមកគាល់ព្រះអង្គ ហើយទូលអង្វរថា៖ «ឱព្រះអម្ចាស់ ជាព្រះរាជវង្ស
ព្រះបាទដាវីឌអើយ! សូមអាណិតមេត្តាខ្ញុំម្ចាស់ផង! កូនស្រីខ្ញុំម្ចាស់ត្រូវខ្មោចចូល បណ្ដាលឲ្យវេទនាខ្លាំង
ណាស់» ។ [២៣]ព្រះយេស៊ូពុំបានឆ្លើយតបនឹងនាងឡើយ ។ ពួកសាវ័ក នាំគ្នាចូលមកជិតព្រះអង្គ ហើយទូល
ថា៖ «សូមព្រះគ្រូប្រោសប្រណីដល់នាងផង ព្រោះនាងចេះតែស្រែកអង្វរពីក្រោយយើង» ។ [២៤]ព្រះអង្គ
មានព្រះបន្ទូលតបថា៖ «ព្រះជាម្ចាស់បានចាត់ឲ្យខ្ញុំមករក តែអស់អ្នកដែលវង្វេង ក្នុងចំណោមជនជាតិ
អ៊ីស្រាអែលប៉ុណ្ណោះ» ។

[២៥]ប៉ុន្តែ ស្ត្រីនោះចូលមកក្រាបទៀបព្រះបាទាព្រះអង្គ ហើយទូលថា៖ «ព្រះអម្ចាស់អើយ! សូមជួយ
ខ្ញុំម្ចាស់ផង!» ។ [២៦]ព្រះអង្គមានព្រះបន្ទូលតបថា៖ «មិនគួរយកអាហាររបស់កូនចៅបោះទៅឲ្យកូនឆ្កែ
ស៊ីឡើយ» ។ [២៧]នាងទូលព្រះអង្គថា៖ «ពិតមែនហើយ ព្រះអម្ចាស់! ប៉ុន្តែ កូនឆ្កែស៊ីកំទេចអាហារ ដែល
ជ្រុះពីតុរបស់ម្ចាស់វា» ។ [២៨]ព្រះយេស៊ូក៏មានព្រះបន្ទូលទៅនាងថា៖ «នាងអើយ! នាងមានជំនឿមាំមួន
ណាស់ ដូច្នេះ សូមឲ្យបានសម្រេចតាមចិត្តនាងប្រាថ្នាចុះ!» ។ កូនស្រីរបស់នាងបានជា តាំងពីពេលនោះ
មក ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២១ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** មថ ១៦,១៨

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះអម្ចាស់បានសង់ព្រះសហគមន៍លើជំនឿរបស់លោកសិលា សេចក្ដីស្លាប់ពុំមានអំណាចលើព្រះសហគមន៍នេះបានឡើយ! ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** ១៦,១៣-២០

១៣ព្រះយេស៊ូយាងមកដល់ស្រុកសេសារេភីលីព ព្រះអង្គមានព្រះបន្ទូលសួរក្រុមសាវ័កថា៖ «តើ
មនុស្សទាំងឡាយថា បុត្រមនុស្សជានរណា?» ។ ១៤គេទូលថា៖ «អ្នកខ្លះថា លោកជាលោកយ៉ូហាន
បាទីស្ដ អ្នកខ្លះថា លោកជាព្យាការីអេលី អ្នកខ្លះទៀតថា លោកជាព្យាការីយេរេមី ឬជាព្យាការីណាមួយ
រូប» ។ ១៥ព្រះអង្គសួរគេទៀតថា៖ «ចុះអ្នករាល់គ្នាវិញ តើអ្នករាល់គ្នាថា ខ្ញុំជានរណាដែរ?» ។
១៦លោកស៊ីម៉ូនសិលាទូលព្រះអង្គថា៖ «លោកជាព្រះគ្រីស្ដ ជាព្រះបុត្រារបស់ព្រះជាម្ចាស់ដ៏មានព្រះជន្ម
គង់នៅ» ។ ១៧ព្រះយេស៊ូមានព្រះបន្ទូលតបទៅគាត់វិញថា៖ «ស៊ីម៉ូន កូនលោកយ៉ូណាសអើយ! អ្នកពិត
ជាមានសុភមង្គលមែន! អ្នកដឹងសេចក្ដីនេះមិនមែនដោយខ្លួនឯងទេ គឺព្រះបិតារបស់ខ្ញុំដែលគង់នៅស្ថាន
បរមសុខបានសម្ដែងឲ្យអ្នកដឹង ។ ១៨ខ្ញុំសុំប្រាប់អ្នកថា អ្នកឈ្មោះសិលា ហើយនៅលើផ្ទាំងសិលានេះ ខ្ញុំនឹង
សង់ព្រះសហគមន៍របស់ខ្ញុំ ។ សេចក្ដីស្លាប់ពុំមានអំណាចលើព្រះសហគមន៍នេះបានឡើយ ១៩ខ្ញុំនឹងប្រគល់
កូនសោព្រះរាជ្យនៃស្ថានបរមសុខឲ្យអ្នក ។ អ្វីៗដែលអ្នកចងនៅលើផែនដីនេះ ព្រះជាម្ចាស់នឹងចងនៅ
ស្ថានបរមសុខ ហើយអ្វីៗដែលអ្នកស្រាយនៅលើផែនដី ព្រះជាម្ចាស់ក៏នឹងស្រាយនៅស្ថានបរមសុខដែរ»
។

២០បន្ទាប់មក ព្រះអង្គមានព្រះបន្ទូលហាមក្រុមសាវ័ក មិនឲ្យប្រាប់នរណាថា ព្រះអង្គជាព្រះគ្រីស្ដ
ឡើយ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២២ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម អភ ១,១៧-១៨

**អាលេលូយ៉ា! អាលេលូយ៉ា!** សូមព្រះបិតារបស់ព្រះយេស៊ូគ្រីស្ដជាអម្ចាស់នៃយើង បំភ្លឺចិត្ត គំនិតយើងឲ្យយល់ថា យើងមានសេចក្ដីសង្ឃឹម យ៉ាងណាដោយព្រះអង្គត្រាស់ហៅយើង! ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** ១៦,២១-២៧

លោកស៊ីម៉ូនសិលាទូលព្រះយេស៊ូថា៖ «លោកជាព្រះគ្រីស្ដ ជាព្រះបុត្រារបស់ព្រះជាម្ចាស់ដ៏មានព្រះ
ជន្មគង់នៅ» ។ [២១]តាំងពីពេលនោះមក ព្រះគ្រីស្ដចាប់ផ្ដើមប្រាប់ឲ្យក្រុមសាវ័កដឹងថា ព្រះអង្គត្រូវតែ
យាងទៅក្រុងយេរូសាឡឹម ។ នៅទីនោះ ពួកព្រឹទ្ធាចារ្យ ពួកនាយកបូជាចារ្យ និងពួកធម្មាចារ្យ នឹងនាំ
គ្នាធ្វើបាបព្រះអង្គឲ្យរងទុក្ខលំបាកយ៉ាងខ្លាំង ថែមទាំងធ្វើគុតព្រះអង្គទៀតផង តែថ្ងៃទីបី ព្រះអង្គនឹង
មានព្រះជន្មថ្មីដ៏រុងរឿង ។ [២២]លោកសិលានាំព្រះយេស៊ូទៅដាច់ឡែកពីគេ ហើយទូលជំទាស់ថា៖
«បពិត្រព្រះអម្ចាស់! សូមព្រះជាម្ចាស់មេត្តាអាណិត កុំឲ្យការណ៍នេះកើតមានដល់ព្រះអង្គឡើយ» ។
[២៣]ព្រះយេស៊ូបែរមក ហើយមានព្រះបន្ទូលទៅលោកសិលាថា៖ «នែ៎! មារសាតាំងអើយ! ថយទៅខាង
ក្រោយខ្ញុំ ដ្បិតអ្នកកំពុងរារាំងផ្លូវខ្ញុំ! គំនិតអ្នកមិនមែនជាគំនិតរបស់ព្រះជាម្ចាស់ទេ គឺជាគំនិតរបស់
មនុស្សលោកសុទ្ធសាធ!» ។

[២៤]បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ក្រុមសាវ័កថា៖ «អ្នកដែលចង់មកតាមក្រោយខ្ញុំ
ត្រូវលះបង់ខ្លួនឯងចោល ត្រូវលីឈើឆ្កាងរបស់ខ្លួន ហើយមកតាមខ្ញុំចុះ [២៥]ដ្បិតអ្នកណាចង់បានរួចជីវិត
អ្នកនោះនឹងបាត់បង់ជីវិត ប៉ុន្តែ អ្នកណាបាត់បង់ជីវិតព្រោះតែខ្ញុំ អ្នកនោះនឹងបានជីវិតវិញ ។ [២៦]បើ
មនុស្សម្នាក់បានពិភពលោកទាំងមូល មកធ្វើជាសម្បត្តិរបស់ខ្លួន តែបាត់បង់ជីវិត នោះនឹងមាន
ប្រយោជន៍អ្វី? តើមនុស្សអាចយកអ្វីមកប្ដូរនឹងជីវិតរបស់ខ្លួនបាន? [២៧]លុះដល់បុត្រមនុស្សប្រកប
ដោយសិរីរុងរឿងនៃព្រះបិតារបស់ព្រះអង្គយាងមកជាមួយពួកទេវទូតរបស់ព្រះអង្គ ទ្រង់នឹងប្រទាន
រង្វាន់ ឬដាក់ទោសម្នាក់ៗ តាមអំពើដែលខ្លួនបានប្រព្រឹត្ត» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២៣ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម ២ ករ ៥,១៩**

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះជាម្ចាស់បានសម្រុះសម្រួលមនុស្សលោកឲ្យជានានឹងព្រះអង្គក្នុងអង្គព្រះគ្រីស្ត ។ ព្រះអង្គក៏ដាក់ព្រះបន្ទូលនៃការសម្រុះសម្រួលនេះមកក្នុងយើងដែរ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **១៨,១៥-២០**

ព្រះយេស៊ូមានព្រះបន្ទូលមកកាន់ក្រុមសាវ័កថា៖ [១៥] «ប្រសិនបើ មានបងប្អូនណាម្នាក់បានប្រព្រឹត្ត
អំពើបាបអ្វីមួយ ចូរទៅជួបអ្នកនោះស្ងាត់ៗតែពីរនាក់ ហើយស្ដីប្រដៅគាត់ទៅ ។ បើគាត់ស្ដាប់អ្នក អ្នក
នឹងរក្សាបងប្អូននោះ មិនឲ្យបាត់ឡើយ [១៦]តែបើគាត់មិនព្រមស្ដាប់អ្នកទេ ចូរនាំម្នាក់ឬពីរនាក់ទៀតទៅ
ជាមួយ ជួយជាស់តឿន ដើម្បីសម្រួលរឿងទាំងអស់ ដោយមានសាក្សីពីរឬបីនាក់ ។ [១៧]ប្រសិនបើ គាត់
មិនព្រមស្ដាប់ពាក្យអ្នកទាំងនោះ ត្រូវនាំរឿងនេះទៅប្រាប់ព្រះសហគមន៍ ហើយបើគាត់នៅតែមិនព្រម
ស្ដាប់ព្រះសហគមន៍ទៀតនោះ ត្រូវចាត់ទុកគាត់ដូចជាសាសន៍ដទៃ ឬដូចជាអ្នកទារពន្ធចុះ ។ [១៨]ខ្ញុំសុំ
ប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្វីៗទាំងអស់ដែលអ្នករាល់គ្នាចងនៅលើផែនដីនេះ ព្រះជាម្ចាស់នឹងចង
នៅស្ថានបរមសុខ ហើយអ្វីៗដែលអ្នករាល់គ្នាស្រាយនៅលើផែនដី ព្រះជាម្ចាស់ក៏នឹងស្រាយនៅស្ថាន
បរមសុខដែរ ។ [១៩]ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ទៀតថា ក្នុងចំណោមអ្នករាល់គ្នា ប្រសិនបើមានពីរ
នាក់នៅលើផែនដីនេះ រួមចិត្តគំនិតគ្នាទូលសូមអ្វីក៏ដោយ ព្រះបិតារបស់ខ្ញុំដែលគង់នៅស្ថានបរមសុខ
នឹងប្រទានឲ្យជាមិនខាន [២០]ដ្បិតនៅទីណាមានពីរឬបីនាក់ជួបជុំគ្នាក្នុងនាមខ្ញុំ ខ្ញុំក៏ស្ថិតនៅទីនោះជាមួយ
គេដែរ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២៤ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម យ៉ូហ ១៣,៣៤**

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះអម្ចាស់ប្រទានវិន័យថ្មីឲ្យយើងខ្ញុំគឺ «អ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ» ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **១៨,២១-៣៥**

[២១]ពេលនោះ លោកសិលាចូលមកជិតព្រះយេស៊ូ ហើយទូលថា៖ «បពិត្រព្រះអម្ចាស់ បើបងប្អូនចេះ
តែប្រព្រឹត្តអំពើបាបមកលើទូលបង្គំ តើទូលបង្គំត្រូវអត់ទោសឲ្យគេប៉ុន្មានដង? រហូតដល់ប្រាំពីរដង
ឬ?» ។ [២២]ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ខ្ញុំសុំប្រាប់អ្នកថា អ្នកត្រូវអត់ទោសឲ្យគេមិនត្រឹម
តែប្រាំពីរដងប៉ុណ្ណោះទេ គឺត្រូវអត់ទោសឲ្យគេចិតសិបដង គុណនឹងប្រាំពីរដង» ។

[២៣]«ហេតុនេះ ព្រះរាជ្យនៃស្ថានបរមសុខ ប្រៀបបាននឹងស្ដេចមួយអង្គ ដែលចង់គិតបញ្ជីជាមួយអ្នក
បម្រើ ។ [២៤]ពេលព្រះរាជាចាប់ផ្ដើមគិតបញ្ជី មានគេនាំកូនបំណុលម្នាក់ ដែលជំពាក់ប្រាក់មួយរយលាន
ណែនមក ។ [២៥]ដោយអ្នកនោះគ្មានប្រាក់សង ស្ដេចក៏ចេញបញ្ជា ឲ្យលក់ទាំងគាត់ទាំងប្រពន្ធ ទាំងកូន
ទាំងទ្រព្យសម្បត្តិដែលគាត់មាន ដើម្បីយកប្រាក់មកសងបំណុល ។ [២៦]អ្នកបម្រើនោះលុតជង្គង់ ក្រាប
ទៀបព្រះបាទាស្ដេចទូលអង្វរថា៖ "សូមទ្រង់មេត្តាអត់ឱន ពន្យារពេលឲ្យទូលបង្គំផង! ទូលបង្គំនឹងសង
ព្រះអង្គវិញគ្រប់ចំនួន!" ។ [២៧]ព្រះរាជាមានព្រះហឫទ័យអាណិតអាសូរ ដល់អ្នកបម្រើនោះពន់ពេក
ណាស់ ព្រះអង្គក៏ឲ្យគាត់ទៅវិញ ទាំងលុបបំណុលចោលថែមទៀតផង ។

[២៨]ពេលអ្នកបម្រើនោះចេញទៅ គាត់ជួបនឹងគូកនម្នាក់ ដែលជំពាក់ប្រាក់គាត់មួយរយដួង គាត់ចាប់
អ្នកនោះប្របាច់កទាំងពោលថា៖ "សងប្រាក់អញទាំងអស់មក!" ។ [២៩]គូកនរបស់អ្នកនោះក៏លុតជង្គង់
ចុះអង្វរថា "សុំអត់ឱនពន្យារពេលឲ្យគ្នាផង! គ្នានឹងសងឯងវិញគ្រប់ចំនួន!" ។ [៣០]ប៉ុន្តែ អ្នកបម្រើនោះ
ពុំព្រមទេ មិនតែប៉ុណ្ណោះសោត គាត់ចាប់អ្នកជំពាក់ប្រាក់យកទៅឃុំឃាំង រហូតទាល់តែបានសងបំណុល
គ្រប់ចំនួន ។ [៣១]អ្នកបម្រើឯទៀតៗឃើញដូច្នោះ ទាស់ចិត្តជាខ្លាំង គេយករឿងនេះទៅទូលស្ដេច ។
[៣២]ស្ដេចក៏ហៅអ្នកបម្រើនោះមកសួរថា៖ "នែ៎ អ្នកបម្រើអាក្រក់! យើងបានលុបបំណុលឯងទាំងប៉ុន្មាន
ចោលអស់ ព្រោះឯងបានទទូចអង្វរយើង ។ [៣៣]យើងបានអាណិតមេត្តាឯង ។ ហេតុដូចម្ដេច បានជាឯង
ពុំព្រមអាណិតមេត្តាគូកនរបស់ឯងផងដូច្នេះ?" ។ [៣៤]ស្ដេចទ្រង់ខ្ញាល់ក្រៃលែងក៏បញ្ជាឲ្យគេយកអ្នក
នោះទៅធ្វើទារុណកម្ម រហូតទាល់តែសងបំណុលគ្រប់ចំនួន ។ [៣៥]ចំពោះអ្នករាល់គ្នា បើម្នាក់ៗមិនព្រម
លើកលែងទោសឲ្យបងប្អូនដោយស្មោះអស់ពីចិត្តទេ ព្រះបិតារបស់ខ្ញុំដែលគង់នៅស្ថានបរមសុខ ក៏នឹងធ្វើ
ទារុណកម្មអ្នករាល់គ្នាដូច្នោះដែរ» ។ — នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២៥ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** ទន ១៤៥,៧.៩

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះអម្ចាស់មានព្រះហឫទ័យសប្បុរសចំពោះមនុស្សទាំងអស់!
ព្រះអង្គអាណិតអាសូរដល់សត្វលោកទាំងអស់ដែលទ្រង់បានបង្កើតមក ។
សត្វលោកទាំងអស់នាំគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** ២០,១-១៦

ព្រះយេស៊ូមានព្រះបន្ទូលជាពាក្យប្រស្នាដូចតទៅ៖ ១«ព្រះរាជ្យនៃស្ថានបរមសុខប្រៀបបាននឹងម្ចាស់
ចម្ការម្នាក់ ដែលចាកចេញពីផ្ទះតាំងពីព្រលឹម ដើម្បីរកជួលកម្មករមកធ្វើការ នៅក្នុងចម្ការទំពាំងបាយ
ជូររបស់គាត់ ។ ២គាត់ព្រមព្រៀងជាមួយពួកកម្មករជាស្រេចថា នឹងឲ្យប្រាក់មួយដួងក្នុងមួយថ្ងៃ ហើយ
ចាត់គេឲ្យទៅធ្វើការក្នុងចម្ការ ។ ៣ប្រមាណជាម៉ោងប្រាំបួនព្រឹក គាត់ចេញទៅ ឃើញអ្នកផ្សេងទៀត
កំពុងតែឈរនៅតាមទីផ្សារ ឥតធ្វើអ្វីសោះ ។ ៤គាត់ក៏និយាយទៅកាន់គេថា "ចូរអ្នករាល់គ្នាទៅធ្វើការ
នៅចម្ការខ្ញុំដែរទៅ! ខ្ញុំនឹងឲ្យប្រាក់ឈ្នួលត្រឹមត្រូវ" ។ ៥អ្នកទាំងនោះក៏នាំគ្នាទៅធ្វើការនៅចម្ការ ។
ម្ចាស់ចម្ការចេញទៅសាជាថ្មីទៀត នៅម៉ោងដប់ពីរ និងម៉ោងបីរសៀល ហើយជួលអ្នកផ្សេងតាមរបៀប
ដដែល ។ ៦ប្រមាណជាម៉ោងប្រាំល្ងាច គាត់ចេញទៅសាជាថ្មី ឃើញអ្នកខ្លះទៀតឈរនៅតាមទីផ្សារ ។
គាត់សួរគេថា "ហេតុដូចម្ដេចបានជាអ្នករាល់គ្នាឈរនៅទីនេះ មួយថ្ងៃវាល់ល្ងាច ឥតធ្វើអ្វីសោះ
ដូច្នេះ?" ៧ពួកគេឆ្លើយថា "មកពីគ្មាននរណាជួលយើងខ្ញុំទៅធ្វើការទេ!" ។ គាត់ក៏ពោលទៅអ្នកទាំង
នោះថា "ចូរអ្នករាល់គ្នាទៅធ្វើការនៅចម្ការខ្ញុំដែរទៅ" ។

៨លុះដល់ល្ងាច ម្ចាស់ចម្ការប្រាប់ទៅអ្នកកាន់ប្រាក់ថា "ចូរហៅពួកកម្មករមក ហើយបើកប្រាក់ឲ្យគេ
គឺចាប់ផ្ដើមពីអ្នកដែលចូលធ្វើការក្រោយគេបង្អស់ រហូតដល់អ្នកមកមុនគេបង្អស់" ។ ៩ពួកអ្នកដែលបាន
ចាប់ផ្ដើមធ្វើការម៉ោងប្រាំល្ងាចមកដល់ ទទួលប្រាក់ម្នាក់មួយដួងៗ ។ ១០ពួកអ្នកដែលចាប់ផ្ដើមធ្វើការមុន
គេក៏មកដល់ដែរ ហើយគិតថា នឹងបានប្រាក់ច្រើនជាង ប៉ុន្តែ គេទទួលម្នាក់មួយដួងៗដូចគ្នា ។ ១១គេ
ទទួលយកប្រាក់ទាំងរអ៊ូរទាំដាក់ម្ចាស់ចម្ការថា ១២"ពួកអ្នកដែលមកដល់ក្រោយនេះ បានធ្វើការតែមួយ
ម៉ោងប៉ុណ្ណោះ រីឯយើងខ្ញុំវិញ យើងខ្ញុំធ្វើការហាលថ្ងៃហាលក្ដៅ ហើយលោកបែរជាបើកប្រាក់ឲ្យគេស្មើ
នឹងយើងខ្ញុំដែរ!" ។ ១៣ម្ចាស់ចម្ការនិយាយទៅកាន់ម្នាក់ ក្នុងចំណោមកម្មករទាំងនោះថា "សំឡាញ់

អើយ! ខ្ញុំមិនបានបោកបញ្ឆោតអ្នកទេ ។ អ្នកបានយល់ព្រមធ្វើការឲ្យខ្ញុំមួយដួងក្នុងមួយថ្ងៃ មែនឬមិន
មែន! ។ [១៤]ចូរយកប្រាក់ឈ្នួលរបស់អ្នក ហើយចេញទៅចុះ! ខ្ញុំចង់ឲ្យអ្នកដែលមកដល់ក្រោយទទួល
ប្រាក់ស្មើនឹងអ្នកដែរ ។ [១៥]តើខ្ញុំគ្មានសិទ្ធិនឹងយកប្រាក់របស់ខ្ញុំ ទៅធ្វើអ្វីតាមបំណងចិត្តខ្ញុំទេឬ? ឬមួយអ្នក
ប្រណែនមកពីឃើញខ្ញុំមានចិត្តសប្បុរស?” ។ [១៦]ហេតុនេះ អ្នកដែលនៅខាងក្រោយ នឹងត្រឡប់ទៅនៅ
ខាងមុខ រីឯអ្នកដែលនៅខាងមុខ នឹងត្រឡប់ទៅនៅខាងក្រោយវិញ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២៦ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** ទន ៩៥,៨

**អាលេលូយ៉ា! អាលេលូយ៉ា!** ថ្ងៃនេះ កុំមានចិត្តរឹងរូសឡើយ!
ចូរស្ដាប់ព្រះសូរសៀងរបស់ព្រះអម្ចាស់! ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **២១,២៨-៣២**

ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ពួកនាយកបូជាចារ្យ និងពួកព្រឹទ្ធាចារ្យថា៖ [២៨]«តើអ្នករាល់គ្នាយល់យ៉ាងណាដែរ ប្រសិនបើបុរសម្នាក់មានកូនប្រុសពីរ ហើយគាត់និយាយទៅកាន់កូនច្បងថា "ថ្ងៃនេះចូរកូនទៅធ្វើការនៅចម្ការទំពាំងបាយជូររបស់ពុកទៅ!" ។ [២៩]កូនតបមកវិញថា "ខ្ញុំមិនចង់ទៅទេ!" ។ ប៉ុន្តែ ក្រោយមក កូននោះដូរគំនិត ហើយក៏ទៅចម្ការ ។ [៣០]បន្ទាប់មក ឪពុកនិយាយពាក្យដដែលទៅកាន់កូនពៅ កូនពៅឆ្លើយថា៖ "បាទ! កូនទៅ!" តែអត់ទៅទេ ។ [៣១]ក្នុងចំណោមកូនទាំងពីរនាក់ តើកូនណាបានធ្វើតាមបំណងឪពុក?» ។ គេទូលព្រះអង្គថា៖ «កូនច្បង» ។ ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ពួកអ្នកទារពន្ធ និងពួកស្ត្រីពេស្យា នឹងចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ជំនួសអ្នករាល់គ្នា [៣២]ដ្បិតលោកយ៉ូហានបានមកណែនាំអ្នករាល់គ្នាឲ្យដើរតាមមាគ៌ាសុចរិត តែអ្នករាល់គ្នាមិនព្រមជឿលោកទេ ។ ពួកអ្នកទារពន្ធនិងស្ត្រីពេស្យាបានជឿលោក រីឯអ្នករាល់គ្នាវិញ ទោះបីអ្នករាល់គ្នាបានឃើញហេតុការណ៍ទាំងនោះ ក៏ដោយ ក៏អ្នករាល់គ្នាមិនបានដូរចិត្តគំនិត ហើយជឿលោកដែរ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២៧ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម ១ សល ១,២៣**

**អាលេលូយ៉ា! អាលេលូយ៉ា!** សព្វថ្ងៃ ព្រះជាម្ចាស់មានព្រះបន្ទូលមកយើង ដោយសារព្រះបុត្រា ។ ព្រះអង្គបានប្រគល់អ្វីៗទាំងអស់ឲ្យព្រះបុត្រាគ្រប់គ្រងជាមត៌ក ។ ព្រះអម្ចាស់បានសម្រេចការអស្ចារ្យនេះ! ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **២១,៣៣-៤៣**

ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ពួកនាយកបូជាចារ្យនិងពួកព្រឹទ្ធាចារ្យថា៖ [៣៣]«សុំស្ដាប់ប្រស្នា
នេះសិន៖ មានបុរសម្នាក់ជាម្ចាស់ចម្ការ គាត់បានដាំទំពាំងបាយជូរ ហើយធ្វើរបងព័ទ្ធជុំវិញ គាត់រៀបចំ
កន្លែងមួយ ដើម្បីបញ្ជាន់ផ្លែទំពាំងបាយជូរ ព្រមទាំងសង់ខ្ទមមួយផង ។ បន្ទាប់មក គាត់ប្រវាស់ឲ្យពួក
កសិករមើលថែទាំ រួចចេញដំណើរពីស្រុកនោះទៅ ។ [៣៤]លុះដល់រដូវទំពាំងបាយជូរទុំ គាត់ក៏ចាត់ពួក
អ្នកបម្រើឲ្យមកជួបអ្នកថែចម្ការទាំងនោះ ដើម្បីទទួលយកផលរបស់គាត់ ។ [៣៥]ពួកកសិករនាំគ្នាចាប់ពួក
អ្នកបម្រើមកវាយដំម្នាក់ ប្រហារជីវិតម្នាក់ និងយកដុំថ្មគប់សម្លាប់ម្នាក់ទៀត ។ [៣៦]ម្ចាស់ចម្ការក៏ចាត់
អ្នកបម្រើផ្សេងទៀត ដែលមានគ្នាច្រើនជាងមុនឲ្យមក ។ ប៉ុន្តែ ពួកអ្នកថែចម្ការបានធ្វើបាបអ្នកបម្រើ
ទាំងនោះ ដូចពួកមុនៗដែរ ។ [៣៧]នៅទីបំផុត ម្ចាស់ចម្ការចាត់កូនប្រុសរបស់គាត់ឲ្យមកជួបគេ ដោយគិត
ថា "គេមុខជាគោរពកោតខ្លាចកូនប្រុសខ្ញុំមិនខាន" ។ [៣៨]ប៉ុន្តែ ពេលពួកកសិករឃើញកូនប្រុសម្ចាស់
ចម្ការមកដល់ គេពិគ្រោះគ្នាថា៖ "អ្នកនេះជាអ្នកទទួលកេរមត៌កពីម្ចាស់ចម្ការទៅថ្ងៃក្រោយ បើយើង
នាំគ្នាសម្លាប់វា មត៌កនេះនឹងត្រូវបានមកយើងមិនខាន" ។ [៣៩]គេក៏ចាប់កូនប្រុសម្ចាស់ចម្ការ បោះទៅ
ខាងក្រៅ ហើយសម្លាប់ចោលទៅ ។ [៤០]ដល់ពេលម្ចាស់ចម្ការមក តើគាត់នឹងធ្វើយ៉ាងណាចំពោះកសិករ
ទាំងនោះ? » ។ [៤១]គេទូលព្រះអង្គថា៖ «គាត់មុខជាសម្លាប់ជនពាលទាំងនោះ ឥតត្រាប្រណីឡើយ រួច
ប្រវាស់ចម្ការឲ្យអ្នកផ្សេងទៀត ដែលនឹងប្រគល់ផលជូនគាត់ នៅរដូវទំពាំងបាយជូរទុំ» ។

[៤២]ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ក្នុងគម្ពីរមានចែងថា "ថ្មដែលពួកជាងសង់ផ្ទះបោះចោល
បានត្រឡប់មកជាថ្មគ្រឹះដ៏សំខាន់បំផុត ។ ព្រះអម្ចាស់បានសម្រេចការអស្ចារ្យនេះ យើងបានឃើញ
ហើយស្ងើចសរសើរផង" ។ តើអ្នករាល់គ្នាដែលអានអត្ថបទនេះឬទេ? ។ [៤៣]ហេតុនេះហើយ បានជាខ្ញុំសុំ
ប្រាប់អ្នករាល់គ្នាថា ព្រះជាម្ចាស់នឹងដកព្រះរាជ្យចេញពីអ្នករាល់គ្នា ប្រគល់ទៅឲ្យសាសន៍មួយទៀត
ដែលចេះបង្កើតផលសមស្របនឹងព្រះរាជ្យ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២៨ ក្នុងរដូវធម្មតា ឆ្នាំ ក

## ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ

**អាលេលូយ៉ា! អាលេលូយ៉ា!** នេះជាពិធីបុណ្យចម្លងរបស់ព្រះអម្ចាស់នៅកណ្ដាលប្រជារាស្ដ្ររបស់ព្រះអង្គ ។ អស់អ្នកដែលចូលរួមក្នុងពិធីជប់លៀងនេះ ពិតនឹងបានសុភមង្គល!

**អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ដ ម៉ាថាយ** **២២,១-១៤ (ឬយ៉ាងខ្លី ២២,១-១០)**

១ព្រះយេស៊ូមានព្រះបន្ទូលជាប្រស្នាទៅពួកគេម្ដងទៀតថា៖ ២«ព្រះរាជ្យនៃស្ថានបរមសុខ ប្រៀប
បាននឹងស្ដេចមួយអង្គ ដែលរៀបវិវាហមង្គលការព្រះរាជបុត្រ ។ ៣ព្រះរាជាចាត់រាជបម្រើឲ្យទៅ
អញ្ជើញភ្ញៀវ មកជប់លៀងក្នុងឱកាសមង្គលការនោះ តែគ្មាននរណាមកសោះ ។ ៤ព្រះអង្គចាត់រាជ
បម្រើផ្សេងទៀត ឲ្យទៅជម្រាបភ្ញៀវថា: “យើងបានរៀបចំភោជនាហារសម្រាប់ជប់លៀង គឺបាន
សម្លាប់គោ និងសម្លាប់សត្វដែលបានបំប៉ននោះ រួចរាល់អស់ហើយ សូមអញ្ជើញមកពិសាការ!” ។ ៥ប៉ុន្តែ
ភ្ញៀវមិនរវីរវល់អើពើឡើយ អ្នកខ្លះទៅចម្ការ អ្នកខ្លះទៅធ្វើជំនួញ ៦អ្នកខ្លះទៀតចាប់ពួករាជបម្រើវាយ
ធ្វើបាប ព្រមទាំងសម្លាប់បោលថែមទៀត ។ ៧ព្រះរាជាព្រះអង្គព្រះពិរោធយ៉ាងខ្លាំង ក៏ចាត់ទាហានឲ្យ
ទៅប្រហារជីវិតឃាតកទាំងនោះ ហើយដុតកម្ទេចស្រុកភូមិរបស់គេផង ។ ៨បន្ទាប់មក ស្ដេចមានរាជឱ
ង្ការទៅពួករាជបម្រើថា: “យើងបានរៀបចំពិធីមង្គលការរួចស្រេចហើយ ប៉ុន្តែ ភ្ញៀវទាំងនោះមិនសម
នឹងមកចូលរួមទេ ។ ៩ហេតុនេះ ចូរនាំគ្នាចេញទៅតាមផ្លូវកែង ហើយអញ្ជើញមនុស្សទាំងអស់ដែលអ្នក
រាល់គ្នាជួប ឲ្យមកជប់លៀង” ។ ១០ពួករាជបម្រើក៏ចេញទៅតាមផ្លូវ ប្រមូលមនុស្សម្នា ដែលគេបានជួប
ទាំងប៉ុន្មានមក ទាំងអាក្រក់ ទាំងល្អ ។ ពេលនោះ មានភ្ញៀវពេញរោងការ ។

១១ព្រះរាជាយាងចូលមកមើលភ្ញៀវនៅក្នុងរោងការ ទតឃើញបុរសម្នាក់ស្លៀកពាក់មិនត្រូវនឹង
របៀបពិធីការ ១២ព្រះរាជាក៏មានរាជឱង្ការទៅអ្នកនោះថា “សម្លាញ់អើយ! ហេតុអ្វីបានជាអ្នកចូលមក
ទីនេះ ដោយមិនស្លៀកសម្លៀកបំពាក់សម្រាប់មង្គលការដូច្នេះ?” ។ បុរសនោះរកនិយាយអ្វីមិនចេញ
ឡើយ ។ ១៣ព្រះរាជាបង្គាប់ទៅពួករាជបម្រើថា “ចូរចងដៃចងជើងអ្នកនេះ សែងយកទៅបោលនៅទី
ងងឹតខាងក្រៅ ជាកន្លែងយំសោកខឹងសង្កៀតធ្មេញនោះទៅ!”» ។

១៤ព្រះយេស៊ូមានព្រះបន្ទូលទៀតថា៖ «ព្រះជាម្ចាស់ត្រាស់ហៅមនុស្សទាំងអស់ តែព្រះអង្គជ្រើស
រើសយកបានចំនួនតិចទេ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២៩ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** ទន ២៩,១-២

**អាលេលូយ៉ា! អាលេលូយ៉ា!** ពពួកទេវតាអើយ! ចូរនាំគ្នាលើកតម្កើងព្រះអម្ចាស់! ចូរលើកតម្កើងសិរីរុងរឿងនិងតេជានុភាពរបស់ព្រះអម្ចាស់! ចូរលើកតម្កើងព្រះនាមដ៏រុងរឿងរបស់ព្រះអង្គ! **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** ២២,១៥-២១

១៥ពួកខាងគណៈផារីស៊ីពិគ្រោះគ្នា រិះរកមធ្យោបាយចាប់កំហុសព្រះយេស៊ូ នៅពេលព្រះអង្គមានព្រះ
បន្ទូល ។ ១៦គេក៏ចាត់សិស្សរបស់គេ និងពួកខាងស្ដេចហេរ៉ូដ ឲ្យទៅជួបព្រះអង្គ ហើយទូលថា៖ «លោក
គ្រូ! យើងខ្ញុំដឹងថា ពាក្យដែលលោកមានប្រសាសន៍សុទ្ធតែពិតទាំងអស់ ។ លោកគ្រូប្រៀនប្រដៅអំពី
របៀបរស់នៅ ដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់តាមសេចក្ដីពិត គឺលោកគ្រូពុំយោគយល់ ហើយក៏ពុំ
រើសមុខនរណាឡើយ ។ ១៧ហេតុនេះ សូមលោកគ្រូឲ្យយោបល់យើងខ្ញុំមើល៍ តើវិន័យរបស់យើងអនុញ្ញាត
ឲ្យបង់ពន្ធដារ ថ្វាយព្រះចៅអធិរាជរ៉ូម៉ាំងឬទេ?» ។ ១៨ព្រះយេស៊ូឈ្វេងយល់គំនិតអាក្រក់របស់ពួកគេ
ទើបមានព្រះបន្ទូលថា៖ «មនុស្សមានពុតអើយ! ហេតុអ្វីបានជាអ្នករាល់គ្នាចង់ចាប់កំហុសខ្ញុំដូច្នេះ?
១៩ចូរបង្ហាញប្រាក់សម្រាប់បង់ពន្ធនោះឲ្យខ្ញុំមើលមើល៍!» ។ គេក៏យកប្រាក់មួយកាក់មកថ្វាយព្រះអង្គ ។
២០ព្រះអង្គមានព្រះបន្ទូលសួរគេថា៖ «តើលើកាក់នេះមានរូបនរណា ឈ្មោះនរណា?» ។ ២១គេទូលថា៖
«រូបនិងឈ្មោះព្រះចៅអធិរាជ» ។ ព្រះអង្គក៏មានព្រះបន្ទូលទៅគេថា៖ «អ្វីៗដែលជារបស់ព្រះចៅអធិ
រាជ ចូរថ្វាយទៅព្រះចៅអធិរាជវិញទៅ ហើយអ្វីៗដែលជារបស់ព្រះជាម្ចាស់ ចូរថ្វាយទៅព្រះជាម្ចាស់
វិញដែរ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៣០ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **១ យហ ៤,៨.៧**

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះអម្ចាស់ជាសេចក្ដីស្រឡាញ់ ។ អ្នកណាមានចិត្តស្រឡាញ់ អ្នកនោះកើតមកពីព្រះជាម្ចាស់ ហើយក៏ស្គាល់ព្រះជាម្ចាស់ដែរ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **២២,៣៤-៤០**

[៣៤]ពេលនោះ ពួកខាងគណៈផារីស៊ីប្រជុំគ្នា ព្រោះគេឮថា ព្រះយេស៊ូបានធ្វើឲ្យពួកខាងគណៈសាឌូស៊ី
ទ័លប្រាជ្ញ រកនិយាយអ្វីទៀតមិនកើត ។ [៣៥]ក្នុងចំណោមពួកគេ មានម្នាក់ជាបណ្ឌិតខាងវិន័យទូលសួរព្រះ
យេស៊ូ ក្នុងគោលបំណងល្បងលមើលព្រះអង្គថា៖ [៣៦]«លោកគ្រូ! ក្នុងគម្ពីរវិន័យ តើមានវិន័យណាសំខាន់
ជាងគេ?» ។ [៣៧]ព្រះយេស៊ូមានព្រះបន្ទូលថា៖ «“ត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នក ឲ្យអស់ពី
ចិត្តគំនិត អស់ពីស្មារតី និងអស់ពីប្រាជ្ញា” [៣៨]ហ្នឹងហើយជាវិន័យទីមួយ ដែលសំខាន់ជាងគេបំផុត ។ [៣៩]រី
ឯវិន័យទីពីរក៏សំខាន់ដូចគ្នាដែរ “គឺត្រូវស្រឡាញ់បងប្អូនឯទៀតៗ ឲ្យបានដូចស្រឡាញ់ខ្លួនឯង” ។ [៤០]វិ
ន័យទាំងពីរនេះជាឫសគល់របស់គម្ពីរវិន័យ និងគម្ពីរព្យាការីទាំងអស់» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៣១ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម មថ ២៣,៩-១០**

**អាលេលូយ៉ា! អាលេលូយ៉ា!** អ្នករាល់គ្នាមានព្រះបិតាតែមួយគត់ ដែលគង់នៅ
ស្ថានបរមសុខ ។ អ្នករាល់គ្នាមានព្រះគ្រីស្តតែមួយព្រះអង្គប៉ុណ្ណោះ ដែលជាអ្នកដឹកនាំអ្នករាល់
គ្នា ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **២៣,១-១២**

១ពេលនោះ ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់មហាជន និងពួកសាវ័កថា៖ ២«ពួកធម្មាចារ្យ តាមនិង
ពួកខាងគណៈផារីស៊ី មានភារកិច្ចបង្រៀនគម្ពីរវិន័យរបស់លោកម៉ូសេ ។ ៣អ្វីៗដែលគេបង្រៀនអ្នករាល់
គ្នា ចូរស្ដាប់ ហើយយកទៅប្រតិបត្តិតាមទៅ តែកុំយកតម្រាប់តាមអំពើ ដែលគេប្រព្រឹត្តឡើយ ដ្បិតគេ
មិនប្រតិបត្តិតាមសេចក្ដីដែលគេបង្រៀននោះទេ ។ ៤អ្នកទាំងនោះបានបង្កើតវិន័យយ៉ាងតឹងរ៉ឹងយកមក
ផ្ទុកលើមនុស្ស ហើយមិនជួយសម្រាលបន្ទុកនោះទេ សូម្បីតែបន្តិចបន្តួចក៏មិនជួយផង ។ ៥គេធ្វើកិច្ចការ
ផ្សេងៗ ដើម្បីឲ្យមនុស្សម្នាកោតសរសើរ គឺគេធ្វើក្លាក់កាន់តែធំឡើងៗ និងធ្វើខ្សែរំយោលនៅជាយអាវ
កាន់តែវែងទៅៗ ។ ៦ពួកគេចូលចិត្តកន្លែងកិត្តិយសក្នុងពិធីជប់លៀង ហើយរើសកន្លែងអង្គុយនៅមុខគេ
ក្នុងសាលាប្រជុំ ។ ៧ពួកនេះចូលចិត្តឲ្យគេឱនកាយគោរព នៅតាមផ្សារ និងឲ្យគេហៅខ្លួនថា "ព្រះគ្រូ"
។ ៨រីឯអ្នករាល់គ្នាវិញ កុំបង្គាប់គេឲ្យហៅខ្លួនថា "ព្រះគ្រូ" សោះឡើយ ដ្បិតអ្នករាល់គ្នាមាន "ព្រះ
គ្រូ" តែមួយគត់ ហើយអ្នករាល់គ្នាសុទ្ធតែជាបងប្អូននឹងគ្នា ។ ៩កុំហៅនរណាម្នាក់នៅលើផែនដីនេះថា
"ព្រះបិតា" ឲ្យសោះ ដ្បិតអ្នករាល់គ្នាមាន"ព្រះបិតា"តែមួយគត់ ដែលគង់នៅស្ថានបរមសុខ ។ ១០កុំឲ្យ
គេហៅអ្នករាល់គ្នាថា"មគ្គុទេសក៍"ឡើយ ដ្បិតមានតែព្រះគ្រីស្តមួយព្រះអង្គប៉ុណ្ណោះ ដែលជា
មគ្គុទេសក៍របស់អ្នករាល់គ្នា ។ ១១ក្នុងចំណោមអ្នករាល់គ្នា អ្នកណាមានឋានៈធំជាងគេ ត្រូវឲ្យអ្នកនោះ
បម្រើអ្នករាល់គ្នា ។ ១២អ្នកណាលើកតម្កើងខ្លួន អ្នកនោះនឹងត្រូវគេបន្ទាបចុះ ។ រីឯអ្នកដែលបន្ទាបខ្លួន
នឹងត្រូវគេលើកតម្កើងវិញ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៣២ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **មថ ២៤,៤២-៤៤**

**អាលេលូយ៉ា! អាលេលូយ៉ា!** ចូរប្រុងស្មារតីឲ្យមែនទែន ចូរត្រៀមខ្លួនជានិច្ច ដ្បិតអ្នករាល់គ្នា មិនដឹងថា បុត្រមនុស្សនឹងមកដល់នៅវេលាណាទេ! ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **២៥,១-១៣**

ព្រះយេស៊ូមានព្រះបន្ទូលជាពាក្យប្រស្នាដូចតទៅ៖ [១]«ព្រះរាជ្យនៃស្ថានបរមសុខប្រៀបបាននឹង
ស្ត្រីក្រមុំដប់នាក់ ដែលយកចង្កៀងចេញទៅទទួលស្វាមី ។ [២]ក្នុងចំណោមពួកនាង មានប្រាំនាក់ជាស្ត្រីឥត
គំនិត ប្រាំនាក់ទៀតជាស្ត្រីឈ្លាសវៃ ។ [៣]ស្ត្រីឥតគំនិតយកចង្កៀងទៅ តែមិនយកប្រេងទៅបង្ការជាមួយ
ទេ ។ [៤]រីឯស្ត្រីឈ្លាសវៃវិញ នាងបានយកចង្កៀងទៅ មានទាំងប្រេងបង្ការផង ។ [៥]ដោយស្វាមីក្រមក
ដល់ នាងទាំងដប់នាក់ងោកងុយពេក ក៏ដេកលក់ទាំងអស់គ្នាទៅ ។ [៦]លុះដល់ពាក់កណ្ដាលអធ្រាត្រ មាន
គេស្រែកឡើងថា “ស្វាមីមកដល់ហើយ! ចូរនាំគ្នារត់ទៅទទួលលោក!” ។ [៧]ស្ត្រីក្រមុំទាំងនោះក៏ក្រោក
ឡើងរៀបចំអុជចង្កៀង ។ [៨]ស្ត្រីឥតគំនិតនិយាយទៅកាន់ស្ត្រីឈ្លាសវៃថា “សុំចែកប្រេងឲ្យយើងខ្លះផង
ព្រោះចង្កៀងយើងចង់រលត់អស់ហើយ” ។ [៩]ស្ត្រីឈ្លាសវៃឆ្លើយទៅវិញថា “ទេមិនបានទេ! បើយើង
ចែកឲ្យពួកនាង ក្រែងមិនគ្រាន់សម្រាប់យើងផង សម្រាប់ពួកនាងផង ។ ចូរនាំគ្នាទៅទិញនៅផ្ទះលក់
ប្រេងទៅ!” ។

[១០]នៅពេលស្ត្រីឥតគំនិតទាំងប្រាំចេញទៅរកទិញប្រេងដុតទៅ ស្រាប់តែស្វាមីមកដល់ ឯស្ត្រីប្រាំនាក់
ដែលត្រៀមខ្លួនជាស្រេច នាំគ្នាចូលទៅក្នុងរោងការជាមួយលោក ហើយគេបិទទ្វារជិត ។ [១១]ក្រោយមក
ស្ត្រីប្រាំនាក់ទៀតមកដល់ ស្រែកហៅថា “លោកម្ចាស់ លោកម្ចាស់! សូមបើកទ្វារឲ្យយើងខ្ញុំចូលផង!”
។ [១២]ស្វាមីឆ្លើយទៅវិញថា “ខ្ញុំសុំប្រាប់ឲ្យនាងទាំងអស់គ្នាដឹងច្បាស់ថា ខ្ញុំមិនស្គាល់ពួកនាងទេ!” ។

[១៣]ដូច្នេះ ចូរអ្នករាល់គ្នាប្រុងស្មារតី ដ្បិតអ្នករាល់គ្នាពុំដឹងថា បុត្រមនុស្សនឹងមកដល់ថ្ងៃណា ពេល
ណាឡើយ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៣៣ ក្នុងរដូវធម្មតា ឆ្នាំ ក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម វវ ២២,១២**

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះអម្ចាស់នឹងមកដល់ក្នុងពេលឆាប់ៗ ទាំងយករង្វាន់មកចែកឲ្យម្នាក់ៗ តាមអំពើដែលខ្លួនបានប្រព្រឹត្ត ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **២៥,១៤-៣០**

ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់សាវ័ក អំពីពេលដែលព្រះអង្គយាងមកវិញ ។ ព្រះអង្គមានព្រះ
បន្ទូលជាប្រស្នាដូចតទៅ៖ [១៤]«ព្រះរាជ្យនៃស្ថានបរមសុខ ប្រៀបបាននឹងបុរសម្នាក់ ដែលហៀបចេញ
ដំណើរទៅស្រុកឆ្ងាយ ។ គាត់ហៅពួកអ្នកបម្រើមកប្រគល់ទ្រព្យសម្បត្តិឲ្យ ។ [១៥]គាត់ប្រគល់ប្រាក់ឲ្យអ្នក
បម្រើម្នាក់ៗ តាមសមត្ថភាពរៀងៗខ្លួន គឺឲ្យប្រាំណែន ទៅអ្នកទីមួយ ពីរណែនទៅអ្នកទីពីរ និងមួយ
ណែនទៅអ្នកទីបី រួចគាត់ចេញដំណើរទៅ ។ [១៦]អ្នកបម្រើដែលបានទទួលប្រាក់ប្រាំណែន យកប្រាក់ចេញ
ទៅរកស៊ីភ្លាម ហើយចំណេញបានប្រាំណែនទៀត ។ [១៧]អ្នកទីពីរក៏ដូច្នោះដែរ គាត់យកប្រាក់ពីរណែន
នោះទៅរកស៊ី ចំណេញបានពីរណែនទៀត ។ [១៨]រីឯអ្នកដែលទទួលប្រាក់មួយណែន បានចេញទៅ ជីកដី
កប់ប្រាក់ម្ចាស់របស់ខ្លួនទុក ។

[១៩]យូរក្រោយមក ម្ចាស់វិលត្រឡប់មកវិញ ហើយគិតបញ្ជីជាមួយអ្នកទាំងបីនោះ ។ [២០]អ្នកទទួល
ប្រាក់ប្រាំណែន យកប្រាក់ដែលចំណេញបានប្រាំណែន ចូលមកជូនម្ចាស់ ដោយពោលថា “លោកម្ចាស់!
លោកបានប្រគល់ប្រាក់ប្រាំណែនឲ្យខ្ញុំប្របាទ ឥឡូវនេះ ខ្ញុំប្របាទចំណេញបានប្រាំណែនទៀត” ។
[២១]ម្ចាស់ក៏ពោលទៅគាត់ថា “ល្អហើយ! អ្នកបម្រើដ៏ប្រសើរ មានចិត្តស្មោះត្រង់អើយ! អ្នកបានស្មោះ
ត្រង់នឹងកិច្ចការមួយដ៏តូចនេះ ខ្ញុំនឹងតាំងអ្នកឲ្យមើលខុសត្រូវលើកិច្ចការធំៗ ។ ចូរអ្នកចូលមកសប្បាយ
រួមជាមួយនឹងខ្ញុំចុះ” ។ [២២]អ្នកទទួលប្រាក់ពីរណែន ក៏យកប្រាក់ដែលចំណេញបានពីរណែនទៀតនោះ
ចូលមកដែរ ហើយជម្រាបថា “លោកម្ចាស់! លោកបានប្រគល់ប្រាក់ពីរណែនឲ្យខ្ញុំប្របាទ ឥឡូវនេះ ខ្ញុំ
ប្របាទចំណេញបានពីរណែនទៀត” ។ [២៣]ម្ចាស់ក៏ពោលទៅគាត់ថា “ល្អហើយ! អ្នកបម្រើដ៏ប្រសើរមាន
ចិត្តស្មោះត្រង់អើយ! អ្នកបានស្មោះត្រង់នឹងកិច្ចការមួយដ៏តូចនេះ ខ្ញុំនឹងតាំងអ្នកឲ្យមើលខុសត្រូវលើកិច្ច
ការធំៗ ។ ចូរអ្នកចូលមកសប្បាយរួមជាមួយនឹងខ្ញុំចុះ” ។ [២៤]បន្ទាប់មក អ្នកដែលបានទទួលប្រាក់មួយ
ណែនក៏ចូលមក ហើយជម្រាបថា “លោកម្ចាស់! ខ្ញុំប្របាទដឹងថាលោកជាមនុស្សតឹងតែងណាស់ ។

លោកតែងច្រូតយកផលពីស្រែដែលលោកមិនបានសាបព្រោះ ហើយប្រមូលយកផលពីដំណាំដែលលោក
មិនបានដាំ ។ [២៥]ខ្ញុំប្របាទបានយកប្រាក់ដែលលោកប្រគល់ឲ្យ ទៅជីកដីកប់ ព្រោះខ្ញុំប្របាទភ័យខ្លាច
ពេក ។ ឥឡូវនេះ សូមលោកម្ចាស់យកប្រាក់របស់លោកវិញចុះ" ។ [២៦]ម្ចាស់ក៏ពោលទៅអ្នកនោះថា "នែ៎
អ្នកបម្រើអាក្រក់ ខ្ជិលច្រអូសអើយ! អ្នកដឹងស្រាប់ហើយថា ខ្ញុំតែងច្រូតយកផលពីស្រែដែលខ្ញុំមិនបាន
សាបព្រោះ និងប្រមូលផលពីដំណាំដែលខ្ញុំមិនបានដាំ ។ [២៧]គួរតែអ្នកយកប្រាក់ខ្ញុំទៅចងការ កាលណាខ្ញុំ
ត្រឡប់មកវិញ ខ្ញុំនឹងទទួលប្រាក់ ទាំងដើម ទាំងការ! ។ [២៨]ចូរយកប្រាក់ពីអ្នកនេះ ប្រគល់ឲ្យអ្នកដែល
មានដប់ណែននោះទៅ [២៩]ដ្បិតអ្នកណាមានហើយ អ្នកនោះនឹងទទួលបរិបូណ៌ហូរហៀរថែមទៀត ។ រីឯ
អ្នកដែលគ្មានវិញ គេនឹងដកហូតនូវអ្វីៗដែលអ្នកនោះមានផង ។ [៣០]ចំណែកឯអ្នកបម្រើឥតបានការនេះ
ចូរយកគាត់ទៅបោលនៅទីងងឹតខាងក្រៅ ជាកន្លែងយំសោក ខឹងសង្កៀតធ្មេញនោះទៅ!" » ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៣៤ ក្នុងរដូវធម្មតា ឆ្នាំ ក

# ព្រះគ្រីស្តជាព្រះមហាក្សត្រនៃពិភពលោក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ**

**អាលេលូយ៉ា! អាលេលូយ៉ា!** សូមព្រះជាម្ចាស់ប្រទានពរដល់ព្រះរាជ្យដែលកំពុងតែមកដល់
គឺព្រះរាជ្យរបស់ព្រះបាទដាវីឌ ជាបិតារបស់យើង!
ជយោ! ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត! ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **២៥,៣១-៤៦**

ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់សាវ័ក អំពីពេលដែលព្រះអង្គយាងមកវិញ ដូចតទៅ៖ [៣១]«នៅ
ពេលបុត្រមនុស្សប្រកបដោយសិរីរុងរឿង យាងមកជាមួយពួកទេវទូត លោកនឹងគង់នៅលើបល្ល័ង្កដ៏រុង
រឿង ។ [៣២]ពេលនោះ មនុស្សគ្រប់ជាតិសាសន៍នឹងមកជុំគ្នានៅមុខលោក លោកនឹងញែកគេចេញពីគ្នា
ដូចគង្វាលញែកចៀមចេញពីពពែ [៣៣]គឺឲ្យចៀមនៅខាងស្ដាំ ពពែនៅខាងឆ្វេង ។ [៣៤]ពេលនោះ ព្រះ
មហាក្សត្រនឹងមានព្រះបន្ទូលទៅកាន់អស់អ្នកនៅខាងស្ដាំព្រះអង្គថា "អស់អ្នកដែលព្រះបិតាខ្ញុំបាន
ប្រទានពរអើយ! ចូរនាំគ្នាមកទទួលព្រះរាជ្យដែលព្រះអង្គបានរៀបទុកឲ្យអ្នករាល់គ្នា តាំងពីកំណើត
ពិភពលោកមក [៣៥]ដ្បិតកាលយើងឃ្លាន អ្នករាល់គ្នាបានឲ្យអាហារយើងបរិភោគ កាលយើងស្រេក អ្នក
រាល់គ្នាបានឲ្យទឹកយើងពិសា កាលយើងជាជនបរទេស អ្នករាល់គ្នាបានទទួលយើងឲ្យស្នាក់អាស្រ័យ
[៣៦]កាលយើងគ្មានសម្លៀកបំពាក់ អ្នករាល់គ្នាបានយកសម្លៀកបំពាក់មកឲ្យយើង កាលយើងមានជំងឺ អ្នក
រាល់គ្នាបានមកសួរសុខទុក្ខយើង ហើយកាលយើងជាប់ឃុំឃាំង អ្នករាល់គ្នាក៏បានមកសួរយើងដែរ" ។
[៣៧]ពួកអ្នកសុចរិតទូលព្រះអង្គវិញថា "បពិត្រព្រះអម្ចាស់! តើយើងខ្ញុំដែលបានឃើញព្រះអង្គឃ្លាន
ហើយយកម្ហូបអាហារមកថ្វាយព្រះអង្គសោយ ឬឃើញព្រះអង្គស្រេក ហើយយកទឹកមកថ្វាយព្រះអង្គ
សោយពីអង្កាល់? ។ [៣៨]តើយើងខ្ញុំដែលបានឃើញព្រះអង្គជាជនបរទេស ហើយទទួលព្រះអង្គឲ្យស្នាក់
អាស្រ័យ ឬឃើញព្រះអង្គគ្មានសម្លៀកបំពាក់ ហើយយកសម្លៀកបំពាក់មកថ្វាយព្រះអង្គពីអង្កាល់? ។
[៣៩]តើយើងខ្ញុំដែលបានឃើញព្រះអង្គប្រឈួន ឬជាប់ឃុំឃាំង ហើយមកសួរសុខទុក្ខព្រះអង្គពីអង្កាល់?"
។ [៤០]ព្រះមហាក្សត្រនឹងមានព្រះបន្ទូលតបទៅគេថា "យើងសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា គ្រប់
ពេលដែលអ្នករាល់គ្នាប្រព្រឹត្តអំពើទាំងនោះ ចំពោះអ្នកតូចតាចជាងគេបំផុតម្នាក់ ដែលជាបងប្អូនរបស់

យើងនេះ អ្នករាល់គ្នាក៏ដូចជាបានប្រព្រឹត្តចំពោះយើងដែរ” ។

[៤១]បន្ទាប់មក ព្រះអង្គនឹងមានព្រះបន្ទូលទៅពួកអ្នកនៅខាងឆ្វេងថា “ពួកត្រូវបណ្ដាសាអើយ! ចូរ
ថយចេញឲ្យឆ្ងាយពីយើង ហើយធ្លាក់ទៅក្នុងភ្លើងដែលឆេះអស់កល្បជានិច្ច ជាភ្លើងបម្រុងទុកសម្រាប់
ផ្ដន្ទាទោសមារសាតាំង និងបរិវាររបស់វានោះទៅ! [៤២]ដ្បិតកាលយើងឃ្លាន អ្នករាល់គ្នាពុំបានឲ្យម្ហូប
អាហារយើងបរិភោគទេ កាលយើងស្រេក អ្នករាល់គ្នាក៏ពុំបានឲ្យទឹកយើងពិសាដែរ [៤៣]កាលយើងជាជន
បរទេស អ្នករាល់គ្នាពុំបានទទួលយើងឲ្យស្នាក់អាស្រ័យឡើយ កាលយើងគ្មានសម្លៀកបំពាក់ អ្នករាល់គ្នា
ក៏ពុំបានយកសម្លៀកបំពាក់មកឲ្យយើងដែរ កាលយើងមានជំងឺ និងជាប់ឃុំឃាំង អ្នករាល់គ្នាពុំបានមក
សួរសុខទុក្ខយើងទាល់តែសោះ” ។ [៤៤]ពួកនោះនាំគ្នាទូលព្រះអង្គថា “បពិត្រព្រះអម្ចាស់! តើយើងខ្ញុំមាន
ដែលបានឃើញព្រះអង្គឃ្លាន ឃើញព្រះអង្គស្រេក ឃើញព្រះអង្គជាជនបរទេស ឃើញព្រះអង្គគ្មានស
ម្លៀកបំពាក់ ឃើញព្រះអង្គប្រឈួន ឬជាប់ឃុំឃាំង ហើយយើងខ្ញុំមិនដែលជួយព្រះអង្គសោះពី
អង្កាល់?” ។ [៤៥]ព្រះអង្គមានព្រះបន្ទូលទៅគេថា “យើងសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា គ្រប់ពេល
អ្នករាល់គ្នាមិនបានប្រព្រឹត្តអំពើទាំងនោះ ចំពោះអ្នកតូចតាចជាងគេបំផុតម្នាក់ ដែលជាបងប្អូនរបស់
យើងនេះ អ្នករាល់គ្នាក៏ដូចជាមិនបានប្រព្រឹត្តចំពោះយើងដែរ” ។ [៤៦]អ្នកទាំងនេះនឹងត្រូវទទួលទោស
អស់កល្បជានិច្ច រីឯអ្នកសុចរិតវិញ នឹងទទួលជីវិតអស់កល្បជានិច្ច» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។